# មង្គលកថា

## មង្គលទី ២




រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**



ព.ស.២៥៥៧

# មង្គលកថា

# មង្គលទី ២



រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

ព.ស.២៥៥៧

# ពុទ្ធប្បវត្តិសង្ខេប

ព្រះពុទ្ធមានព្រះនាមថាព្រះសទ្ធត្ថជាបុគ្គលប្រសើរបំផុតក្នុងលោក។ បិតាព្រះនាម សុទ្ធោទនៈ, មាតាព្រះនាម សិរិមហាមយា, ព្រះនគរឈ្មោះ កបិលពស្តុ, សព្វថ្ងៃជាប្រទេសនេប៉ាល បែកចេញពីឥណ្ឌា, ប្រសូតនៅថ្ងៃ សុក្រ១៥ កើត ខែវិសាខ ឆ្នាំ ច, ត្រកូលជាក្សត្រ សក្យវង្ស តំណពីព្រះបាទឱក្កាករាជ ប្អូនរួមបិតាព្រះនាម ព្រះនន្ទ មាតាផ្សេងគ្នា ព្រះជន្ម ១៦ ព្រះវស្សា មានអគ្គមហេសី ព្រះនាម ពិម្ពាយសោធរា ព្រះជន្ម ២៩ ព្រះវស្សា រាហុល ជាបុត្រប្រសូត និង ទ្រង់ចេញសាងផ្នួសព្រះជន្ម ២៩ ព្រះវស្សាត្រាស់ជាព្រះពុទ្ធព្រះជន្ម ៣៥ ព្រះវស្សា ព្រះនាមថា សមណៈគោតម ។

## ស្ថានទីគង់ចាំព្រះវស្សា

១-ឥសិបតនមិគទាយវ័ន, ២-៤ វត្តវេឡុវ័ន, ៥-កូដាគារសាលាមហាវ័ន ៦-មកុដបព៌តដែនមគធៈ, ៧-ឋានតាវត្តិង្ស, ៨-ភេសកឡាវ័ន ភគ្គរាជ-ជនបទ, ៩-ឃោសិតារាម, ១០-ព្រៃបាលិលេយ្យ ១១-ដង់ព្រៃជិតស្រុក សាលាលេយ្យកៈ, ១២-ក្រោមដើមស្តៅជិតស្រុកវេរញ្ជា, ១៣-ចាលិកប-ពត៌, ១៤-វត្តជេតពន ១៥- វត្តនិគ្រោធារាម, ១៦-ស្រុកអាឡវី, ១៧-វត្ត វេឡុវ័ន១៨-១៩-ចាលិកបពត៌ ២០- វេឡុវ័ន, ២១-៤៤ វត្តជេតពន, ៤៥- ស្រុកវេឡុវគ្រាម ។

ព្រះជន្ម ៨០ ព្រះវស្សា ដាក់ព្រះជន្មាយុ និងបរិព្វានក្នុងនគរ កុសិនារា នៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ក្នុងវេលាជិតភ្លឺ ។ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា ៥.០០០ ព្រះវស្សា រហូតរៀងមក ។

# ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្ដែងមង្គល




រឿងមង្គលនេះ ទេវតាមួយម៉ឺនចក្រវាឡ ប្រើពេលអស់ ១២ ឆ្នាំរកមង្គល តែរកមិនឃើញ លុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្ដែងមង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់បុគ្គលពាលជាដើម រហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់ **ទេវតាសម្រេចជាព្រះអរហន្តរាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់ប្រមាណមិនបាន ។**

# មង្គលកថា

# មង្គលទី ២

រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

**វត្តនិគ្រោធវ័ន  គល់ទទឹង**

ព.ស.២៥៥៧

-ឈ្មោះសៀវភៅ **មង្គលកថា មង្គលទី ២**

-រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

-អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ **អគ្គធីរោ គង់ សុមិត្ត**

-ចេញផ្សាយ លើកទី ១

-កាលបរិច្ឆេទ ព.ស. ២៥៥៧

- ទីកន្លែងធ្វើ វត្តនិគ្រោធវ័ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

# អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចម្រើន សិរីសួស្តី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់មិនចំពោះថាជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្តីសុខ ចម្រើន សិរីសួស្តី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្តអាគមអូមអាមផ្សេង ៗនិងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្តិស្តុកស្តម្ភ មានយសសក្តិខ្ពង់ខ្ពស់ មានគេគោរពលើកតម្កើង បរិវារ ហែហម ចោមរោម ការពារគ្រប់ជំហានជាដើម ទើបជីវិតមាននៅសិរី សួស្តីសុភមង្គល ។ ទង្វើទាំងអស់នេះ វាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,០០០ ព្រះធម្មខន្ធដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្តែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្តែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្តែងអំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តុង្គឧត្តមនៃជីវិត ។ និងជាព្រះសូត្រ ដែលព្រះអង្គសម្តែងបើកបង្ហាញដល់មនុស្សនិង

ទេវតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្តបងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តមនៃជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់ អ្នកនៅក្នុងក្រុងនគររាជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើល មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះកណ្តុរបានកាត់នូវសម្ពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ជាច់ជាអន្លើ ៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅទីផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតា ឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅបោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់ បណ្តាលឱ្យវិនាសគ ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅបោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាដកដែលកូនប្រុសរបស់ព្រាហ្មណ៍បានបោលហើយ ទាំងដែលកូន ប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្តាទ្រង់កាន់យកនូវសំពត់មួយគូរនោះ វិលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធបោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្តីថា

មកដល់យើងជាពិតប្រាដក ដូច្នេះ យើងត្រូវយកសំពត់សាដកថ្មី ៗទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណគោតម បោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្តហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយសព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកយើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ៗដែលគេបោលនៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើងឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុនមក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្នដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈានហើយប្រោសព្រាហ្មណ៍ ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វជាសរណៈ ។

នៅក្នុងបិដលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះបរមសាស្តាទ្រង់ត្រាស់ថា ៖

មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល(ភ្ញាក់ផ្អើល) ។ ជាអ្នកគ្របសង្កត់នូវយុគក្កិលេស(ក្រោធ ១ ការចងគំនុំ ១ ការមើលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅថាយុគក្កិលេស)និងយោគក្កិលេស(កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ១អវិជ្ជាយោគ ១)រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ញាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្លងផុតនូវទោសនៃការប្រកាន់មង្គលភ្ញាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្តជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុស ប៉ុន្តែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្តល់មេរៀនឱ្យគេម្តង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេអ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចចេសចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្មោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នា

មកនោះវិញទៅ  ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះធំ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេតាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្ដីដណ្ដឹងកូនស្រីអ្នកជនបទហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហករបស់អាជីវក ។ រឿងរ៉ាងមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទបានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជាអ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពពាក្យសន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បានពោលថា ផ្កាយទាំងឡាយនឹងមានប្រយោជន៍អ្វី ព្រោះការបានកូនស្រីក្រមុំជាឫក្សល្អស្រេចទៅហើយ មិនមែនទេ ? រួចហើយទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ៥៨ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វពោលថា ៖

**នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា**

**អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។**

ប្រែថា: ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្តាបទទាំងនោះ បទថា **បដិមានេន្តំ** ដោយសេចក្តីថា អ្នករង់ចាំមើល អធិប្បាយថា រវល់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា អត្ថោពាលំឧបច្ចគា ដោយសេចក្តីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្លងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រុងពារាណសីនោះ ។

បទថា អត្ថោ អត្ថស្ស នក្ខត្តំ ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា កឹករិស្សន្តិតារកា ដោយសេចក្តីថា តើដួងផ្កាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្តេចឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មង្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាបុព្វណ្ហសម័យ ( ពេលព្រឹក ) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាមជ្ឈន្តិកសម័យ ( ពេលថ្ងៃ ) សត្វទាំងនោះឈ្មោះថា **មានមជ្ឈន្តិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ ( ពេលល្ងាច ) សត្វទាំងនោះឈ្មោះថា សាយណ្ហសម័យដ៏ល្អ ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ ( ទានដែលបុគ្គលបូជា ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ ( ក្នុងពេលនោះ ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា ។**

( ក្នុងថ្ងៃនោះ ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន ។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្តែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ញែកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្ដែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ខាងចុងថា **ខេមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្សេមក្សាន្ត** ។

**សរុបមក** បើបុគ្គលណាប្រាថ្នានូវសិរីសួស្ដី សុភមង្គល ភាពសុខដុមរមនាដល់ខ្លួនដល់ក្រុមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ ទុំះសិរីសួស្ដី សុភមង្គល សេចក្ដីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសង្ឃឹមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្ដីសុខ និងការរីកចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈភាសាបាលីសេចក្ដីអធិប្បាយត្រង់ចំណុចណាមួយនោះ សូមមេត្តាខន្ដី អភ័យទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លាក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ខិតខំកសាងសន្សំព្យាយាមធ្វើសៀវ-ភៅនេះ សូមបានជាឧបនិស្ស័យដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះ តែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ៗក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្តី មិនមានសេចក្តីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរីអារ្យមេត្រីយ៍**កុំបីអាក់ខានឡើយ,ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្តីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្លើយដោយព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

**សូមអនុមោទនា !!!**

**ថ្ងៃ៧កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧**

**ភិក្ខុសីលប្បញ្ញោ នៃ សុផល្លី**

# បញ្ជីមាតិកា


| មាតិកា | មង្គលកថា | ទំព័រ |
|---|---|---|
| អារម្ភកថា | | ក |
| **មង្គលទី ២ សេពគប់បណ្ឌិត** | | ១ |
| បណ្ឌិតគឺជាអ្នកណា | | ១ |
| លក្ខណៈរបស់បណ្ឌិត | | ៤ |
| អង្គរបស់បណ្ឌិត | | ៥ |
| វិធីសង្កេតបណ្ឌិត | | ៥ |
| បឋមសខាសូត្រ | | ៧ |
| ទុតិយសខាសូត្រ | | ៩ |
| មិត្តសូត្រ | | ១១ |
| បណ្ឌិតសូត្រ | | ១២ |
| មិត្តាមិត្តជាតក | | ១៦ |
| ព្រះគាថាក្នុងកោសម្ពិក្ខន្ធកៈ | | ២២ |
| វិធីសេពគប់បណ្ឌិត | | ២៥ |
| បណ្ឌិតត្រូវមានគុណសម្បត្តិ១០ប្រការ | | ២៦ |
| បេះដូងរបស់បណ្ឌិត | | ២៨ |
| ប្រភេទរបស់បណ្ឌិត | | ២៩ |
| ផលានិសង្សក្នុងភាពជាបណ្ឌិត | | ២៩ |

**មាតិកា** **ទំព័រ**


បឋមកល្យាណមិត្តសូត្រ ... ... ... ... ... ... ... ... ... ... ៤០
បឋមកល្យាណមិត្តសូត្រ ... ... ... ... ... ... ... ... ... ៤១
បឋមកល្យាណមិត្តសូត្រ ... ... ... ... ... ... ... ... ... ... ៤៣
តួនាទីរបស់មិត្ត ... ... ... ... ... ... ... ... ... ... ... ... ... ... ៤៥
រឿងសន្តតិមហាមាត្យ ... ... ... ... ... ... ... ... ... ... ... ៤៦
សប្បុរិសធម៌៧ យ៉ាង ... ... ... ... ... ... ... ... ... ... ... ៥៨
វុឌ្ឍិធម៌ជាគ្រឿងចម្រើន៤ យ៉ាង ... ... ... ... ... ... ... ៥៩
ហិរិជាតក ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៣
បឋមផលសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ៦៥
មហាបញ្ញាវគ្គទី ៧ ... ... ... ... ... ... ... ... ... ... ... ... ៦៧
សេចក្តីសុខរបស់បណ្ឌិត ... ... ... ... ... ... ... ... ... ... ៦៩
គុណសម្បត្តិរបស់បណ្ឌិត ... ... ... ... ... ... ... ... ... ៧០
បហានាមសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ៧១
ហានិសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៧៤
ចណ្ឌាសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៧៩
គុណនៃឧបាសក ... ... ... ... ... ... ... ... ... ... ... ... ... ៨២
របៀបចំដំណើរជីវិត ... ... ... ... ... ... ... ... ... ... ... ... ៨៥
មិត្តមានសន្តានចិត្តល្អ ... ... ... ... ... ... ... ... ... ... ... ៨៩

**មាតិកា** **ទំព័រ**


លក្ខណៈរបស់មិត្តមានសន្តានល្អ៤យ៉ាង ... ... ... ... ៨២
មិត្តមានឧបការៈ៤យ៉ាង ... ... ... ... ... ... ... ... ... ... ៩៣
មិត្តរួមសុខទុក្ខ៤យ៉ាង ... ... ... ... ... ... ... ... ... ... ... ៩៦
មិត្តប្រាប់ប្រយោជន៍៤យ៉ាង ... ... ... ... ... ... ... ... ៩៨
មិត្តមានសេចក្តីឈឺឆ្អាល៤យ៉ាង ... ... ... ... ... ... ... ៩៩
ព្រះគាថាប្រារព្ធចំពោះព្រះរាធត្ថេរៈ ... ... ... ... ... ១០៨
ព្រះគាថាប្រារព្ធចំពោះភិក្ខុអស្សជិនិងបុនព្វសុកៈ ១១២
ព្រះគាថាប្រារព្ធចំពោះព្រះថេរៈឈ្មោះឆន្នត្ថេរៈ ... ១១៣
ព្រះគាថាប្រារព្ធចំពោះព្រះមហាកប្បិនត្ថេរៈ ... ... ១១៤
ព្រះគាថាប្រារព្ធចំពោះបណ្ឌិតសាមណេរ ... ... ... ១១៦
ព្រះគាថាប្រារព្ធចំពោះព្រះលកុណ្ឌកភទ្ទិយត្ថេរៈ ១១៨
ព្រះគាថាប្រារព្ធចំពោះមាតារបស់នាងកាណា ... ១១៩
ព្រះគាថាប្រារព្ធចំពោះភិក្ខុ៥០០ រូប ... ... ... ... ... ១២១
ព្រះគាថាប្រារព្ធចំពោះព្រះធម្មិកត្ថេរៈ ... ... ... ... ១២៣
ព្រះគាថាប្រារព្ធចំពោះការស្តាប់ធម៌ ... ... ... ... ១២៥
ព្រះគាថាប្រារព្ធចំពោះភិក្ខុអាគន្តុក ... ... ... ... ... ១២៧
អានិសង្សការសេពគប់បណ្ឌិត ... ... ... ... ... ... ១៣១

**មាតិកា** **ទំព័រ**

សាលសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ១៣២
ទុតិយអប្បមាទសូត្រ ... ... ... ... ... ... ... ... ... ... ១៣៥
សត្តិសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ១៥២
សារីបុត្រសូត្រ ... ... ... ... ... ... ... ... ... ... ... ... ១៦៨
កល្យាណមិត្តតាទិវគ្គទី ៨ ... ... ... ... ... ... ... ... ១៧២
រឿងនាងចូឡសុភទ្ទា ... ... ... ... ... ... ... ... ... ... ១៧៣
សង្ខេបខ្លី ៗ ... ... ... ... ... ... ... ... ... ... ... ... ... ១៨៤
លទ្ធផលនៃការសេពគប់ ... ... ... ... ... ... ... ... ... ១៨៥
មិត្តមានសន្តានចិត្តល្អ៤ប្រការ ... ... ... ... ... ... ១៨៦
សេពគប់មិត្តល្អត្រាស់ដឹងធម៌ពិត ... ... ... ... ... ... ១៨៧
មិត្តល្អបំណងឱ្យរួចចាកទុក្ខ ... ... ... ... ... ... ... ... ១៨៨
មិត្តធម៌ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១៨៨
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ ១៩១

# វត្ថុដែលវែងយូរ ៣ យ៉ាង

**១. ទីឃោ ជាគរតោ រត្តិ**

⇨. *យប់យូរសម្រាប់បុគ្គលដែលដេកមិនលក់ ។*

**២. ទីឃំ សន្តស្ស យោជនំ**

⇨. *យោជន៍ឆ្ងាយសម្រាប់បុគ្គលដែលស្បើយកម្លាំង ។*

**៣. ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ**

⇨. *សង្សារវដ្តវែងឆ្ងាយ សម្រាប់បុគ្គលពាលទាំងឡាយ ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។*

✴. *ព្រះគាថានេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រារព្ធ ចំពោះព្រះបាទបសេនទិកោសល ដែលព្រះអង្គមានព្រះទ័យស្រឡាញ់ភរិយារបស់បុរសម្នាក់ ។*

# មង្គលទី ២ សេពគប់បណ្ឌិត

*សម្ពត់ដែលវេចខ្ចប់របស់ក្រអូប វារមែងមានក្លិនក្រអូបឈ្ងុយឈ្ងប់ទៅតាមដែរ យ៉ាងណាមិញ អ្នកដែលសេពគប់បណ្ឌិតក៏ រមែងបានទទួលសេចក្តីដឹងសេចក្តីអាចនឹងសេចក្តីល្អតាមបណ្ឌិតក៏យ៉ាងនោះដែរ ។*

## បណ្ឌិតគឺជាអ្នកណា?

**បណ្ឌិត** *គឺជាមនុស្សដែលមានចិត្តផូរផង់ថ្លាជានិច្ច ធ្វើឱ្យមានការយល់ឃើញត្រូវអាចរៀបចំដំណើរជីវិតរស់នៅប្រកបដោយបញ្ញាដ៏ប្រសើរ នឹងមានសេចក្តីសុខចម្រើន ។*

- ***ជាអ្នកចេះដឹងល្អ*** *គឺដឹងថា* ***អ្វីល្អ អ្វីអាក្រក់.***
- ***ជាអ្នកដឹងត្រូវ*** *គឺដឹងថា* ***អ្វីត្រូវ អ្វីខុស.***
- ***ជាអ្នកដឹងប្រពៃ*** *គឺដឹងថា* ***អ្វីបុណ្យ អ្វីបាប ។***

**បណ្ឌិត** *អាចជាអ្នកណាក៏បាន ដូចជា អាចជាអ្នកមិនចេះអានអក្សរ អាចជាអ្នកធ្វើស្រែចំការ អាចជាអ្នកមានការសិក្សាខ្ពស់ អាចជាញាតិរបស់យើងជាដើម* ***តែមិនថាជាអ្វីក៏ដោយ ឱ្យ***

តែជាអ្នកមានចិត្តផូរផង់ថ្លាជានិច្ច នឹងចេះរៀបចំដំណើរជីវិតរស់ នៅប្រកបដោយបញ្ញា គឺមនុស្សល្អហើយ ។

មនុស្សទូទៅតែងយល់ថា អ្នកដែលរៀនរហូតបានទទួលបរិញ្ញាបត្រនោះ គឺជាបណ្ឌិត តែការពិតនោះវាគ្រាន់តែជាបណ្ឌិតផូវលោកតែប៉ុណ្ណោះទេ នៅមិនទាន់ជាបណ្ឌិតពិតទេ ព្រោះអ្នកដែលបានទទួលបរិញ្ញាបត្រនោះ ប្រសិនជាការប្រព្រឹត្តមិនល្អទេ ហើយទៅធ្វើខុស រហូតជាប់គត់ ជាប់ច្រវ៉ាក់ ខ្នោះឃ្នាបនោះមិនមែនជាបណ្ឌិតទេ ប៉ុន្តែបណ្ឌិតដែលពិតនោះ គឺជាអ្នកតាំងចិត្តលះបោលនូវអំពើអាក្រក់ មានការប្រព្រឹត្តដោយប្រពៃ ប្រកបតែសេចក្ដីល្អ សេចក្ដីទៀងត្រង់ សុចរិតអាចការពារខ្លួនឱ្យផុតពីខ្នោះឃ្នាប នឹងអាចគេចផុតអំពីនរកបាន ។

ម្យ៉ាងទៀត សត្វទាំងឡាយឯណាមួយ ជាអ្នកប្រកបដោយកុសលកម្មបថ ១០ មានការវៀរចាកការសម្លាប់សត្វជាដើម, សត្វទាំងឡាយនោះឈ្មោះថា **បណ្ឌិត** ។ មួយទៀត ព្រះពុទ្ធព្រះបច្ចេកពុទ្ធ ព្រះមហាសាវ័ក ៨០ ព្រះសាវ័ករបស់ព្រះតថាគតទាំងឡាយដទៃទៀត និងគ្រូសុនេត្រ និងអកិត្តិតាបសជាដើម ក្នុងអតីតកាលគប្បីជ្រាបថា **ជាបណ្ឌិត** ។ អ្នកប្រាជ្ញទាំងឡាយ

មានព្រះពុទ្ធជាដើម ទាំងអស់នោះលោកហៅថា **"ជាបណ្ឌិត"** ព្រោះធ្វើដំណើរទៅក្នុងប្រយោជន៍ទាំងឡាយ ដោយបញ្ញាគតិ ។ ដោយហេតុនោះក្នុងអដ្ឋកថា ទើបលោកពោលថា "ជនទាំងឡាយណាទៅ អធិប្បាយថា "ធ្វើដំណើរទៅក្នុងប្រយោជន៍ទាំងឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងសម្បរាយិកភពដោយបញ្ញាគតិ" ព្រោះហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា **បណ្ឌិត"** ។ សូម្បីក្នុងគម្ពីរសទ្ទនីតិលោកក៏ពោលទុកថា "**បឌិ** ធាតុ ប្រព្រឹត្តទៅក្នុងកិរិយាទៅ,បញ្ញាឯណារមែងទៅគឺធ្វើដំណើទៅក្នុងប្រយោជន៍ទាំងឡាយ សូម្បីដ៏ល្អិតសុខុម គឺដឹងនូវអាការៈសូម្បីមានជាដើម គឺការបៀតបៀននូវអរិយសច្ច មានសេចក្តីទុក្ខជាដើម ហេតុនោះ បញ្ញានោះ ទើបឈ្មោះថា **បណ្ឌា**, បុគ្គលណាទៅ គឺធ្វើដំណើរទៅ បានដល់ប្រព្រឹត្តទៅដោយបញ្ញាដែលមានឈ្មោះថា **បណ្ឌា** ហេតុនោះ បុគ្គលនោះទើបឈ្មោះថា **បណ្ឌិត**, បុគ្គលឯណាទៅ គឺធ្វើដំណើរទៅដោយញាណគតិ ព្រោះហេតុនោះបុគ្គលនោះ ទើបឈ្មោះថា **បណ្ឌិត"** ។

**៦. បណ្ឌិតមិនមែនអ្នកមានត្រឹមតែបរិញ្ញាបត្រទេ តែគឺជាអ្នកឧត្តមប្រសើរដោយសីល សមាធិ បញ្ញា ។**

## លក្ខណៈរបស់បណ្ឌិត

**បណ្ឌិត** គឺជាអ្នកមានចិត្តផូរផង់ជានិច្ច មានការយល់ឃើញត្រូវ អាចរៀបចំដំណើរជីវិតរស់នៅប្រកបដោយបញ្ញាឆ្លាតក្នុងការសង្កេតរកហេតុផល ព្រោះដូច្នេះហើយ ទើបមានលក្ខណៈពិសេសខ្ពស់ជាងមនុស្សទាំងឡាយ ៣ គឺ ៖

**១- ចូលចិត្តគិតល្អជានិច្ច** បានដល់ គិតឱ្យទាន គិតឱ្យអភ័យ មិនចងគំនុំព្យាបាទ គិតឃើញត្រឹមត្រូវតាមសេចក្ដីពិត ដូចជាឃើញថា បុណ្យបាបមានពិត មាតាបិតាមានគុណលើយើងពិតជាដើម ។

**២-ចូលចិត្តនិយាយល្អជានិច្ច** បានដល់ និយាយពាក្យពិត និយាយពាក្យពីរោះពិសា និយាយពាក្យមានប្រយោជន៍ និយាយដោយចិត្តមេត្តា និងនិយាយត្រឹមត្រូវតាមកាលៈទេសៈជាដើម ។

**៣-ចូលនិយាយល្អជានិច្ច** បានដល់ មាននូវមេត្តា ករុណា ប្រកបដោយសម្មាអាជីវៈ ធ្វើបុណ្យ ឱ្យទាន រក្សាសីល ធ្វើសមាធិ ចម្រើនភាវនាជានិច្ច ។

## អង្គរបស់បណ្ឌិត

១- **កតញ្ញូ** ដឹងនូវឧបការៈគុណដែលគេធ្វើដល់ខ្លួន

២- **អត្តសុទ្ធិ** ធ្វើខ្លួនឱ្យបរិសុទ្ធិចាកពីបាប

៣- **បរសុទ្ធិ** ញុំាងអ្នកដទៃឱ្យបរិសុទ្ធិចាកពីបាបដែរ

៤- **សង្គហៈ** មានការសង្គ្រោះដល់ជនទូទៅ ។

## វិធីសង្កេតបណ្ឌិត

បណ្ឌិតចូលចិត្តធ្វើរឿងដូចតទៅ ៖

១- **បណ្ឌិតចូលចិត្តដឹកនាំក្នុងផ្លូវដែលត្រូវ** ដូចជា ដឹកនាំឱ្យឈប់ជក់បារី ឈប់ផឹកស្រា ឈប់លេងល្បែងស៊ីសង ឈប់សេពគ្រឿងញៀន ដឹកនាំឱ្យសូត្រធម៌នមស្ការមុនចូលដេក ឱ្យរក្សាសីល ឱ្យតាំងចិត្តសិក្សារៀនសូត្រ ឱ្យធ្វើការរកស៊ីក្នុងផ្លូវសុចរិតជាដើម ។

២- **បណ្ឌិតចូលចិត្តធ្វើតែរឿងដែលជាធុរៈ** មិនបង្កបញ្ហាដល់អ្នកដទៃ មានរុករានធ្វើការងារតាមមុខនាទីរបស់ខ្លួន ឱ្យសម្រេចទៅដោយល្អ មិនលះបង់ការងារចោល នឹងមិនឆ្លៀតកកាយក្នុងមុខនាទីការងារអ្នកដទៃរៀរតែការបានទទួលការអង្វរ ឬដើម្បីអនុគ្រោះ

ពីអ្នកដទៃឱ្យជួយ ។

**៣- បណ្ឌិតចូលចិត្តធ្វើតែវត្ថុដែលត្រូវដែលគួរ** ដូចជាចូលចិត្តនិយាយត្រង់ទៅត្រង់មកចូលចិត្តសន្ទនាធម៌រង្កៀសចំពោះអំពើអាក្រក់ ចូលចិត្តធ្វើខ្លួនឱ្យមានប្រយោជន៍ទាំងចំពោះខ្លួនឯងនិងអ្នកដទៃជាដើម ។

**៤- បណ្ឌិតកាលត្រូវគេនិយាយដាស់តឿនដោយពាក្យល្អ មិនខឹងក្រោធ** មាននិស្ស័យកាន់យកភាពត្រឹមត្រូវ និងសេចក្តីមានប្រយោជន៍ជាទីតាំង មិនប្រកាន់ខ្លួន ហើយយល់ឃើញថាអ្នកដែលបានដាស់តឿនខ្លួន គឺជាអ្នកបានចង្អុលបង្ហាញនូវកំណប់ទ្រព្យឱ្យ ហើយខិតខំព្យាយាមកែខៃកសាងខ្លួន ឱ្យល្អឡើងតាមពាក្យណែនាំនោះ ដោយមិនទឹករង្កៀសថា អ្នកដែលដាស់តឿននឹងមានអាយុ យសស័ក្តិ ឋានៈខ្ពស់ ឬទាបជាង តែប្រសិនបើអ្នកដាស់តឿននោះ និយាយមិនសម ក៏អត់ធន់ទុកមិនក្រោធតប ហើយព្យាយាមរកឱកាសចង្អុលបង្ហាញ ពន្យល់ឱ្យយល់ចូលចិត្តជាខាងក្រោយ ទើបធ្វើចិត្តយ៉ាងត្រជាក់ចំពោះមនុស្សទូទៅ ។

**៥- បណ្ឌិតរមែងទទួលស្គាល់របៀបវិន័យ** ស្រឡាញ់

នឹងបដិបត្តិតាមវិន័យរបស់ពួកគណៈយ៉ាងតឹងរឹងបំផុត ព្រោះយល់ច្បាស់ថា ល្អ វិន័យជាគ្រឿងលើកសរសើររបស់ពួកគណៈ មានសេចក្ដីស្ងប់មិនជ្រួលច្របល់ ធ្វើឱ្យកើតសេចក្ដីសុខសប្បាយជាដើម ។

## បឋមសខាសូត្រ

នៅក្នុងបិដកលេខ ៤៧, ទំព័រ ៥៩ ព្រះអង្គទ្រង់ត្រាស់ជាមួយភិក្ខុទាំងឡាយ [***ដែលនិយាយអំពីគុណសម្បត្តិរបស់មិត្តដែលគួរសេពគប់***] ដោយមានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការ គួរសេពគប់ ។ **ប្រកបដោយអង្គ ៧ ប្រការ** តើដូចម្ដេចខ្លះ ។

- គឺមិត្តឱ្យនូវរបស់ដែលគេឱ្យបានដោយកម្រ ១
- ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ១
- អត់ធន់ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ ១
- បើកបង្ហាញសេចក្ដីកំបាំងរបស់ខ្លួនដល់គ្នា ១
- បិទសេចក្ដីកំបាំងរបស់គ្នា ១

៦. មិនលះគ្នាក្នុងគ្រាមានសេចក្ដីអន្តរាយ ១

៧. មិនមើលងាយគ្នាព្រោះអស់ភោគៈ ១ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយអង្គ ៧ ប្រការនេះឯង គួរសេពគប់ ។ មិត្តឱ្យនូវរបស់ដែលគេឱ្យបានដោយកម្រផង ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រផង មួយទៀត អត់ធន់ចំពោះពាក្យដែលពោលអាក្រក់ និងហេតុអត់ធន់បានដោយកម្រផង ប្រាប់សេចក្ដីកំបាំងរបស់ខ្លួនដល់គ្នាផង បិទសេចក្ដីកំបាំងរបស់គ្នាផង មិនលះគ្នាក្នុងគ្រាមានសេចក្ដីអន្តរាយផង មិនមើលងាយគ្នាព្រោះអស់ភោគៈផង ហេតុទាំងនេះមានក្នុងបុគ្គលណាក្នុងលោកនេះ បុគ្គលមានសភាពដូច្នោះនោះហៅថា **មិត្ត** ជនអ្នកមានប្រាថ្នានូវមិត្ត គប្បីសេពគប់ ។

## អដ្ឋកថា

បទថា ទុទ្ទទំ វត្ថុមានតម្លៃច្រើន ដែលលះបង់បានលំបាក ។ បទថា ទុក្ករំ ករោតិ សេចក្ដីថា រមែងធ្វើកិច្ចកម្មដែលធ្វើមិនបានងាយ ។ បទថា ទុក្ខមំ ខមតិ សេចក្ដីថា រមែងអត់ទ្រាំបានយ៉ាងលំបាក ដើម្បីប្រយោជន៍ដល់សម្លាញ់ ។ បទថា គុយ្ហមស្ស

អាវិករោតិ សេចក្តីថា រមែងបើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់សម្លាញ់នោះ ។ បទថា គុយ្ហមស្ស បរិគូហតិ សេចក្តីថា មិនប្រាប់សេចក្តីកំបាំង របស់សម្លាញ់នោះដល់ពួកអ្នកដទៃ ។ បទថា ខីណេន នាតិមញ្ញតិ បានដល់ កាលភោគសម្បត្តិរបស់សម្លាញ់នោះអស់ទៅហើយក៏មិនមើលងាយសម្លាញ់នោះ ព្រោះសេចក្តីសាបសូន្យអស់នោះ គឺមិនធ្វើការជាន់ឈ្លីនិងមើលងាយក្នុងខ្លួនសម្លាញ់នោះ ។

## **ទុតិយសខាសូត្រ**

នៅក្នុងបិដកលេខ ៤៧, ទំព័រ ៦០ ព្រះអង្គទ្រង់ត្រាស់សម្តែង [**អំពីគុណសម្បត្តិរបស់មិត្ត ដែលគួរសេពគប់**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្តេញបំបរបង់ចេញក៏គួរ តែសេពគប់រាប់រកចូលទៅអង្គុយជិត ។ **ប្រកបដោយអង្គ ៧ ប្រការតើដូចម្តេចខ្លះ ។**

៦.គឺភិក្ខុជាអ្នក( ធ្វើខ្លួន )ឱ្យជាទីស្រឡាញ់និងជាទីគាប់ចិត្ត១

➥. គួរគោរព ១

➥. គួរសរសើរ ១

➥. ឧស្សាហ៍ប្រៀនប្រដៅ ១

➥. អត់ធន់ចំពោះពាក្យ ១

➥. ជាអ្នកនិយាយពាក្យជ្រៅ ១

➥. មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌៧ប្រការនេះឯង បុគ្គលអ្នកស្វែងមិត្ត បើទុកជាលោកបណ្តេញបំបរបង់ចេញក៏គួរតែសេពគប់រាប់រក ចូលទៅអង្គុយជិត ។

បិយោ ច គរុ ភាវនីយោ វត្តា ច វចនក្ខមោ
គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ,
យស្មឹ ឯតានិ ឋានានិ សំវិជ្ជន្តីធ បុគ្គលេ
សោ មិត្តោ មិត្តកាមេន អត្ថកាមានុកម្បកោ
អបិ នាសិយមានេន ភជិតព្វោ តថាវិធោ ។

ភិក្ខុជាអ្នក( ធ្វើខ្លួន )ឱ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង

ជាអ្នកនិយាយពាក្យជ្រៅផង មិនដឹកនាំក្នុងហេតុដែលមិនគួរផង, ហេតុទាំងនេះមានក្នុងបុគ្គលណាក្នុងលោកនេះ បុគ្គលជាអ្នកប្រាថ្នានូវប្រយោជន៍ អ្នកធ្វើនូវសេចក្តីអនុគ្រោះមានសភាពដូច្នោះនោះ ឈ្មោះថា ជាមិត្ត បុគ្គលអ្នកមានសេចក្តីត្រូវការដោយមិត្ត ទោះបីជាលោកធ្វើឱ្យវិនាស ក៏គួរតែតាមសេពគប់ ។

## អដ្ឋកថា

បទថា វត្តា បានដល់ អ្នកឆ្លាតក្នុងពាក្យ ។

បទថា វចនក្ខមោ សេចក្តីថា ភិក្ខុរមែងអត់ធន់ពាក្យសម្តី គឺធ្វើតាមឱវាទដែលលោកឱ្យ ។ បទថា គម្ភីរំ បានដល់ ពាក្យដែលបិទបាំងជ្រាលជ្រៅដែលអាស្រ័យឈាន អាស្រ័យវិបស្សនា មគ្គផល និងនិព្វាន ។

## មិត្តសូត្រ

នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៥៦ ព្រះអង្គទ្រង់ត្រាស់ [**អំពីអង្គ ៣ របស់មិត្តពិត**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយមិត្តប្រកបដោយអង្គ៣គួរសេពគប់ ។ ប្រកបដោយអង្គ ៣ គឺអ្វីខ្លះ ។

**១- ទុទ្ទំ ទទាតិ** គឺមិត្តឱ្យវត្ថុដែលគេឱ្យបានដោយក្រ

**២- ទុករំ ករោតិ** ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ

**៣- ទុក្កមំ ខមតិ** អត់ធន់នូវហេតុដែលអត់ធន់បាន ដោយក្រ ។

ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៣នេះឯង គួរសេពគប់ ។

## បណ្ឌិតសូត្រ

នៅក្នុងបិដកលេខ ៤១,ទំព័រ ៤៥៦ ព្រះអង្គទ្រង់ត្រាស់ [**អំពីវត្ថុដែលបណ្ឌិតបញ្ញត្តទុក៣ប្រការ**]មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ។ **ហេតុ ៣ យ៉ាង** តើដូចម្តេច ។

➥. ម្នាលភិក្ខុទាំងឡាយ ទានជាគុណជាត ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១,

➥.ម្នាលភិក្ខុទាំងឡាយ បព្វជ្ជាជាគុណជាតិ ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១,

៦. មាតាបិតុបដ្ឋាន ( ការបម្រើមាតាបិតា ) ជាគុណជាតិ ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ១ ។

ម្នាលភិក្ខុទាំងឡាយហេតុ ៣ យ៉ាងនេះឯង ជាគុណជាត ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញតហើយ ។

## និគមគាថា

សទ្ធា ទានំ ឧបញ្ញត្តំ អហឹសា សញ្ញមោ ទមោ
មាតាបិតុឧបដ្ឋានំ សន្តានំ ព្រហ្មចារិនំ
សតំ ឯតានិ ឋានានិ យានិ សេវេថ បណ្ឌិតោ
អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវន្តិ ។

ទានជាគុណជាត ដែលពួកសប្បុរសបញ្ញត្តហើយ ការមិនបៀតបៀន ការសង្រួម ការទូន្មានខ្លួនជាគុណជាតដែលសប្បុរសបញ្ញត្តហើយ ការបម្រើមាតាបិតាជាគុណជាត ដែលសប្បុរសបញ្ញត្តហើយ បណ្ឌិតជាអ្នកប្រសើរ ប្រកបដោយសេចក្តីយល់ឃើញ គួរប្រតិបត្តិនូវហេតុរបស់សប្បុរសជាអ្នកស្ងប់ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ បណ្ឌិតនោះ រមែងទៅកាន់ទេវលោកជាទីក្សេម ។

## អដ្ឋកថា

បទថា **បណ្ឌិត បញ្ញត្តានិ** សេចក្តីថា ដែលបណ្ឌិតទាំងឡាយបញ្ញត្តិទុក គឺពោលទុក បានដល់ សរសើរហើយ ។

បទថា សប្បុរិសបញ្ញត្តានិ សេចក្តីថា ដែលសប្បុរសទាំងឡាយ គឺមហាបុរសទាំងឡាយ បញ្ញត្តិទុកហើយ គឺពោលទុកហើយ បានដល់ សរសើរហើយ ។

ទាំងករុណា ទាំងធម៌ដែលជាខាងដើមរបស់ករុណា ឈ្មោះ ថា **អហិំសា** ។ ការសង្រួមក្នុងសីល ឈ្មោះថា **សញ្ញមៈ** ។ ការសង្រួមឥន្ទ្រិយ ឬ ការទូន្មានខ្លួនដោយឧបោសថ ឈ្មោះថា **ទមៈ** ។ ចំណែកក្នុងបុណ្ណោវាទសូត្រ ព្រះអង្គត្រាស់ហៅខន្តីថា **ទមៈ** ។ សូម្បីបញ្ញាដែលត្រាស់ទុក ក្នុងអឡវកសូត្រក៏សមរម្យ ក្នុងព្រះសូត្រនេះដូចគ្នា ។

ការរក្សា គ្រប់គ្រង ប្រណិបត្តិមាតាបិតា ឈ្មោះថា **ការបម្រុងមាតាបិតា** ។

បទថា សន្តានំ សេចក្តីថា ក្នុងសូត្រដទៃ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវកទាំងឡាយ ឈ្មោះថា **សប្បុរស**

តែក្នុងព្រះសូត្រនេះ ទ្រង់ប្រាថ្នាយកអ្នកទំនុកបម្រុង ចិញ្ចឹមមាតាបិតា ។ ព្រោះហេតុនោះ បុគ្គលទាំងនោះឈ្មោះថា សប្បុរស ព្រោះសំដៅសេចក្ដីថា ខ្ពស់បំផុត ឈ្មោះថា ព្រហ្មចារី ព្រោះសំដៅសេចក្ដីថា ប្រព្រឹត្តប្រសើរបំផុត ។ ការបម្រុងមាតាបិតានេះ សប្បុរសទាំងឡាយបញ្ញត្តិទុកហើយ គប្បីជ្រាបសេចក្ដីក្នុងរឿងនេះ ដូចពណ៌នាមកនេះឯង ។

បទថា សតំ **ឯតានិ ឋានានិ** សេចក្ដីថា ប្រការទាំងនេះជាឋានៈគឺជាហេតុរបស់សប្បុរសទាំងឡាយ ។ បុគ្គលដែលទាំងប្រសើរទាំងដល់ព្រមដោយទស្សនៈ( សេចក្ដីឃើញ ) ព្រោះហេតុទាំង ៣ ស្ថាននេះឯង គប្បីជ្រាបថា ជាអរិយៈ និងដល់ព្រមដោយសេចក្ដីឃើញក្នុងព្រះសូត្រនេះ មិនមែនព្រះពុទ្ធជាដើមនិង មិនមែនព្រះសោតាបន្ន ។

ន័យមួយទៀត គប្បីជ្រាបអត្ថាធិប្បាយនៃព្រះគាថានេះដោយអំណាចនៃការបម្រុងមាតាបិតាយ៉ាងនេះថា ហេតុរបស់សប្បុរសទាំងឡាយ បានដល់ឧត្តមបុរសទាំងឡាយនេះ គឺការបម្រុងមាតា១ ការបម្រុងបិតា១ ឈ្មោះថា ឋានៈទាំងនេះរបស់

សប្បុរសទាំងឡាយ ។ ពិតមែន អ្នកបម្រើមាតាបិតាប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ហៅថា ជាអរិយៈ និងជល់ព្រមដោយ ទស្សនៈ ក្នុងព្រះសូត្រនេះ ។

បទថា លោកំ ជត សិវំ សេចក្តីថា អ្នកនោះរមែង ទៅកាន់ទេវលោកដែលជាដែនក្សេម ។

# មិត្តាមិត្តជាតក

នៅក្នុងព្រះអដ្ឋកថាលេខ ៦០, ទំព័រ ២០៣ ព្រះអង្គទ្រង់ត្រាស់នូវព្រះជាតកមួយ [**ដែលនិយាយអំពីលក្ខណៈរបស់អ្នកជាមិត្តនិងអ្នកមិនមែនមិត្ត**] ដោយមានសេចក្តីថា ៖

ព្រះសាស្តាកាលស្តេចទ្រង់គង់នៅក្នុងវត្តជេតវ័ន មហាវិហារ ទ្រង់ប្រារព្ធអាមាត្យអ្នកប្រព្រឹត្តប្រយោជន៍របស់ព្រះបាទកោសល ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យចាប់ផ្តើមថា គានិកម្មានិ កុព្វានំ ដូច្នេះ ។

បានឮថា អាមាត្យនោះបានមានឧបការៈចំពោះព្រះរាជាជាច្រើន ព្រះរាជាក៏បានប្រទានសក្ការរាប់រកគេយ៉ាងក្រៃលែងពួក

អាមាត្យដ៏សេសអត់ទ្រាំមើលមិនបាន ទើបនាំគ្នាទូលព្រះញ្ញង់ថា បពិត្រព្រះអង្គដ៏ចម្រើនអាមាត្យឈ្មោះឯណោះនឹងធ្វើសេចក្តីវិនាស ដល់ព្រះអង្គ ព្រះរាជាទ្រង់កំណត់ពិចារណាមើលអាមាត្យនោះក៏ មិនឃើញទោសតិចតួច ទ្រង់ព្រះតម្រិះថា យើងមិនឃើញទោស តិចតួចរបស់អាមាត្យនេះធ្វើយ៉ាងណាហ្ន៎ យើងទើបនឹងអាចដឹង ថា អាមាត្យនេះជាមិត្ត ឬមិនមែនមិត្ត ទ្រង់គិតថា វៀរព្រះតថាគត ចេញហើយអ្នកដទៃមិនអាចដឹងបញ្ហានេះបានយើងនឹងទៅទូលសួរ លុះមសោយព្រះក្រយាហារព្រឹកស្រេចហើយ ក៏ចូលទៅគាល់ព្រះ សាស្តាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្តេចហ្ន៎ ទើប នឹងអាចដឹងថា អ្នកណាជាមិត្ត ឬមិនមែនមិត្តរបស់ខ្លួន ។

លំដាប់នោះ ព្រះសាស្តាត្រាស់ចំពោះព្រះរាជាថា មហា-បពិត្រ សូម្បីបណ្ឌិតក្នុងកាលមុនក៏គិតបញ្ហានេះ ហើយសួរពួក បណ្ឌិត ដឹងបានដោយពួកបណ្ឌិតទាំងនោះប្រាប់ វៀរពួកដែល ជាមិនមែនជាមិត្តចេញ សេពគប់តែមិត្តប៉ុណោះ ព្រះរាជាទូល អារាធនាឱ្យទ្រង់សម្តែងរឿងរ៉ាវ ព្រះរាជាទ្រង់នាំអតីតនិទានមក សម្តែងដូចតទៅនេះ ៖

ក្នុងអតីតកាលកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីព្រះពោធិសត្វសោយព្រះជាតិជាអាមាត្យទូន្មានអត្ថធម៌ចំពោះព្រះរាជា គ្រានោះក្នុងព្រះនគរពាណសីមានអាមាត្យម្នាក់ ប្រព្រឹត្តប្រយោជន៍ចំពោះព្រះរាជា ពួកអាមាត្យដ៏សេសនាំគ្នាញុះញង់ព្រះរាជា ព្រះរាជាទ្រង់មិនឃើញទោសរបស់អាមាត្យនោះ ទ្រង់ព្រះតម្រិះថា ធ្វើដូចម្ដេចហ្ន៎ យើងទើបនឹងអាចដឹងថា អាមាត្យនេះជាមិត្តឬមិនមែនមិត្ត កាលនឹងត្រាស់សួរព្រះមហាសត្វបានត្រាស់ព្រះគាថា បណ្ឌិតអ្នកមានប្រាជ្ញាឃើញ ឬឮពួកជនកំពុងធ្វើនូវអំពើអ្វី ៗគប្បីដឹងថា ជាអមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្ដេច ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុរសអ្នកជាបណ្ឌិតមានបញ្ញាឃើញបុរសអ្នកធ្វើការងារអ្វី ៗ ដោយចក្ខុបានស្ដាប់រឿងនោះដោយត្រចៀកគប្បីដឹងថា អ្នកនេះមិនមែនមិត្តរបស់យើង វិញ្ញូជនគប្បីព្យាយាមយ៉ាងណា ដើម្បីស្គាល់អ្នកនោះ ។

លំដាប់នោះព្រះមហាសត្វកាលនឹងត្រាស់ប្រាប់លក្ខណៈរបស់អ្នកដែលមិនមែនមិត្តដល់ព្រះរាជាបានត្រាស់ព្រះគាថាថា ៖

បុគ្គលជាសត្រូវឃើញបុគ្គលនោះហើយមិនញញឹម១ មិនទទួលត្រេកអរនឹងសម្ដីបុគ្គលនោះ១ មិនឱ្យភ្នែកដល់បុគ្គលនោះ ១ ប្រព្រឹត្តទទឹងទាស់ ១ ។

បុគ្គលដែលអែបអបនឹងពួកសត្រូវរបស់បុគ្គលនោះ ១ មិនសេពគប់នឹងពួកមិត្តរបស់បុគ្គលនោះ ១ រារាំងពួកជនអ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១ ។

មិនប្រាប់សេចក្ដីកំបាំងដល់បុគ្គលនោះ ១ មិនលាក់សេចក្ដីកំបាំងរបស់បុគ្គលនោះ ១ មិនសរសើរការងាររបស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញារបស់បុគ្គលនោះ ១ ។

ត្រេកអរនឹងសេចក្ដីវិនាសរបស់បុគ្គលនោះ ១ មិនត្រេកអរនឹងសេចក្ដីចម្រើនរបស់បុគ្គលនោះ ១ បានភោជនចំឡែក មិននឹកនាដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលអំពីរបស់នោះថាឱមិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

បណ្ឌិតឃើញឬឮហើយ ស្គាល់ថាជាអមិត្តបានដោយអាការទាំង១៦ នេះ ដែលតម្កល់នៅក្នុងអមិត្តដោយប្រការដូច្នេះ ។

ព្រះមហាសត្វត្រាស់ព្រះគាថា ៥គាថាទាំងនេះហើយដែល

ព្រះរាជាត្រាស់សួរដល់លក្ខណៈរបស់មិត្ត ដោយព្រះគាថានេះទៀតថា ៖

**បណ្ឌិត** អ្នកមានប្រាជ្ញាឃើញឬឮពួកជនកំពុងធ្វើនូវការងារអ្វី ៗគប្បីដឹងថាជាមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្តេច ។

(ព្រះមហាសត្វ) ទើបត្រាស់គាថាថា ៖

បុគ្គលជាមិត្តតែងនឹករលឹកដល់មិត្តដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្តដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្តនោះមិត្ត ១ ទទួលរីករាយដោយវាចា ១ ។

គប់រកនឹងពួកមិត្តរបស់មិត្តនោះ ១ មិនសេពគប់នឹងពួកអមិត្តរបស់មិត្តនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជនដែលនិយាយសរសើរ ១

ប្រាប់សេចក្តីកំបាំងដល់មិត្តនោះ ១ បិទបាំងសេចក្តីកំបាំងរបស់មិត្តនោះ ១ សរសើរការងាររបស់មិត្តនោះ ១ សរសើរប្រាជ្ញារបស់មិត្តនោះ ១ ។

ត្រេកអរនឹងសេចក្តីចម្រើនរបស់មិត្តនោះ១ មិនត្រេកអរនឹងសេចក្តីវិនាសរបស់មិត្តនោះ១ បានភោជនចំឡែកតែងនឹកនា

ដល់មិត្តនោះ១ អនុគ្រោះមិត្តនោះអំពីរបស់នោះថា ឱមិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាមិត្តបានដោយ អាការទាំង១៦នេះ ដែលតម្កល់នៅក្នុងមិត្តដោយបការៈដូច្នេះ ។

ព្រះរាជា មានព្រះទ័យសរសើរពាក្យរបស់ព្រះមហាសត្វ បានព្រះរាជទានយសដ៏ធំក្រៃលែងដល់ព្រះមហាសត្វហើយ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកហើយត្រាស់ ថា មហាបពិត្រ បញ្ហានេះបានតាំងឡើងសូម្បីក្នុងកាលមុនយ៉ាង នេះ បណ្ឌិតទាំងឡាយពោលដល់បញ្ហានេះថា អ្នកដែលមិនមែន មិត្តនិងអ្នកដែលជាមិត្តនឹងគប្បីដឹងបានដោយអាការ ៣២ ទាំងនេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាព្រះ អានន្ទ ចំណែកអាមាត្យដែលជាបណ្ឌិត បានមកជាយើងតថាគត នេះឯង ។

## ព្រះគាថាក្នុងកោសម្ពិក្ខន្ធកៈ

[វិន័យបិដកភាគ ៨,ទំព័រ៣៤៥]

សចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។

បើបុគ្គលបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះអាចគ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរ មានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ ។

នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលមិនបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្ដេចលះបង់ដែនដែលខ្លួនឈ្នះហើយ ត្រាច់ទៅតែម្នាក់ឯង ពុំនោះសោត ប្រៀបដូចជាស្ដេចដំរីដ៏ប្រសើរត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។

ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា

ឯកោ ចរេ ន ច បាបានិ កយិរា

អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

កាលដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយតាគុណទេ[១],

ម្យ៉ាងទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរ មានសេចក្ដីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

---

១. អដ្ឋកថាធម្មបទថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថា សហាយតាគុណ ។

## **អដ្ឋកថា**

គាថាថា សចេ លភេថ និបកំ សហាយំ (បើបុគ្គលបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងគុណនៃសម្លាញ់ ដែលជាបណ្ឌិត និងទោសនៃសម្លាញ់ដែលជាពាល ។

បាទគាថាថា **អភិភុយ្យ សព្វានិ បរិស្សយានិ** បុគ្គលនោះអាចគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងពួងបាន មានសេចក្ដីថា គប្បីញាំញីអន្តរាយដែលប្រាកដ និងអន្តរាយដែលលាក់កំបាំងចេញ មានចិត្តរីករាយជាមួយនឹងសម្លាញ់នោះ មានសតិត្រាច់ទៅ ។

ប្រើនបទថា **រាជាវ រដ្ឋំ វិជិតំ** (ប្រៀបដូចជាស្ដេច)លះបង់នូវដែនដែលខ្លួនឈ្នះហើយ មានសេចក្ដីថា ព្រះរាជាទ្រង់ព្រះនាមថា **មហាជនក** និងព្រះមហារាជា ទ្រង់ព្រះនាមថា **អរិន្ទមៈ** ទ្រង់លះព្រំដែន គឺដែនដីជាទីត្រេកអររបស់ព្រះអង្គចេញ ត្រាច់ទៅតែម្នាក់ឯងយ៉ាងណា គប្បីត្រាច់ទៅ ដូច្នោះ ។

ពីរបទថា **មាតង្គរញ្ញេវ នាគោ** (ដំរីដ៏ប្រសើរក្នុងព្រៃ) មានសេចក្ដីថា ដូចជាដំរីដ៏ប្រសើរលះហ្វូង ត្រាច់ទៅក្នុងព្រៃ ។

សត្វមានប្រមោយ ហៅថា ដំរី ។

ពាក្យថា ឆាគ នេះ ជាឈ្មោះនៃអ្នកដ៏ប្រសើរ ។ មានពាក្យអធិប្បាយថា ប្រៀបដូចជាដំរីដ៏ប្រសើរដែលចិញ្ចឹមមាតាត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ។ ទាំងមិនបានធ្វើបាបទាំងឡាយយ៉ាងណាមួយទៀត ដំរីបារិលេយ្យកៈ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ទាំងមិនបានធ្វើបាបទាំងឡាយយ៉ាងណា បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯង ទាំងមិនគប្បីធ្វើបាបទាំងឡាយក៏យ៉ាងនោះដែរ ។

## វិធីសេពគប់បណ្ឌិត

១- ឧស្សាហ៍ព្យាយាមទៅរកលោក ឱ្យបានញឹកញាប់ដោយការបម្រើលោកជាដើម,

២- ឧស្សាហ៍ព្យាយាមចូលទៅអង្គុយជិត ដោយសាកសួរនៅសេចក្ដីសង្ស័យផ្សេង ៗរបស់ខ្លួន,

៣- មានសេចក្ដីសប្បាយចិត្តចេះគោរពកោតក្រែងដល់លោក

៤- ស្ដាប់ពាក្យណែនាំ ស្ដាប់ពាក្យនិយាយរបស់លោក

៥- ចាំធម៌ដែលបានស្ដាប់នោះទុក

៦- ពិចារណាសេចក្តីនៃធម៌នោះទុកឱ្យល្អ

៧- ព្យាយាមប្រព្រឹត្តបដិបត្តិតាមធម៌ដែលបានស្តាប់នោះ ។

## បណ្ឌិតត្រូវមានគុណសម្បត្តិ ១០ ប្រការ

បណ្ឌិតក្រៅអំពីជាអ្នកមានបញ្ញា មានគុណធម៌ខ្ពង់ខ្ពស់ និងការប្រព្រឹត្តល្អទៅតាមផ្លូវកាយ វាចា ចិត្ត ដឹងនូវប្រយោជន៍បច្ចុប្បន្ន បរលោក និងប្រយោជន៍យ៉ាងក្រៃលែង គឺព្រះនិព្វានហើយ ត្រូវមានគុណសម្បត្តិ ១០ ប្រការទៀតគឺ ៖

**១-ធីរោ** មានបញ្ញាជាគ្រឿងចងចាំឆ្លាតវាងវៃចេះចាំធម៌ច្រើន អាចដោះស្រាយនូវបញ្ហាបានគ្រប់យ៉ាង មិនមានទើសទាក់ វិនិច្ឆ័យបានយ៉ាងត្រឹមត្រូវល្អ,

**២-បញ្ញោ** មានបញ្ញាទាំងផ្នែកលោកីយ៍ និងលោកុត្តរមានបញ្ញាជ្រាវជ្រៅ ចាក់ធ្លុះក្នុងអត្ថនៃធម៌របស់ព្រះមានព្រះភាគគ្មានចន្លោះ

**៣- ពហុស្សុតោ** ជាពហុស្សូតទាំងផ្នែកបរិយត្តិធម៌ បដិបត្តិធម៌ និងបដិវេធធម៌,

**៤- ធោរយ្ហោ** ជាអ្នកមាំមួននៅក្នុងគន្ថធុរៈនិងវិបស្សនាធុរៈ គឺសិក្សាទាំងផ្នែកការអប់រំ ទាំងផ្នែកបដិបត្តិដើម្បីកម្ចាត់បង់នូវ

កិលេសឱ្យចេញពីសន្តាន,

**៥_ សីលវា** ជាអ្នកមានសីលល្អបរិសុទ្ធ មិនដាច់ធ្លុះធ្លាយ ពពាល ពព្រុះ ដូចជាគោដែលមានសម្បុរផ្សេងៗនោះទេ

**៦_ វតវន្តោ** ជាអ្នកទ្រទ្រង់នូវធុតង្គគុណ ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោសចំពោះបច្ច័យទាំងឡាយ ។

**៧_ អរិយោ** ជាអ្នកឃ្លាតឆ្ងាយអំពីកិលេសទាំងឡាយ មាន លោភៈ ទោសៈ និងមោហៈជាដើម

**៨_ សុមេធោ** ជាអ្នកប្រកបដោយបញ្ញាទាំង៤ ***គឺសុត្តមយ-បញ្ញា*** បញ្ញាកើតអំពីការស្តាប់, ***ចិន្តាមយបញ្ញា*** បញ្ញាកើតអំពីការ គិត ***ភាវនាមយបញ្ញា*** បញ្ញាកើតអំពីការចម្រើន អប់រំនៅក្នុង កុសលធម៌, និង***អភិសមយបញ្ញា*** បញ្ញាដ៏ក្រៃលែង អាចត្រាស់ ដឹងនូវសច្ចធម៌បាន,

**៩_ តាទិសោ** ជាអ្នកជ្រះថ្លានៅក្នុងព្រះរតនត្រ័យមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងជាអ្នកមាំមួនក្នុងទាន សីល ភាវនា,

**១០_ សប្បុរិសោ** ជាសប្បុរសគឺមានកាយ វាចា ចិត្តស្ងប់ ចាកអកុសលធម៌ទាំងឡាយ ។

# បេះដូងរបស់បណ្ឌិត

អ្នកណាក៏ចង់ឆ្លាតវាងវៃ ចង់ក្លាយជាបណ្ឌិតដែរ ដើម្បីក្លាយជាបណ្ឌិត ជាអ្នកបេះដឹង ត្រូវបំពេញកត្តាដូចខាងក្រោម ៖

**១- សុ** គឺសុត្ត ប្រែថា **ស្តាប់** បានដល់ស្តាប់ធម៌ក្តី ស្តាប់គ្រូពន្យល់ក្តី គឺស្តាប់ដោយយកចិត្តទុកដាក់ជាទីបំផុត មិនឱ្យចិត្តរវើរវាយទៅកាន់ទីផ្សេង ៗ ។

**២- ចិ** គឺចិន្តា ប្រែថា **គិតពិចារណារកហេតុផលដើមទង** ដូចជាថា ផលនេះកើតចេញពីណា ហេតុអ្វីបានជាក្លាយទៅជាអីចឹងជាដើម ។

**៣- បុ** គឺបុច្ឆា ប្រែថា សួរនូវអ្វីដែលខ្លួនឆ្ងល់ មិនទាន់អស់សង្ស័យ ។

**៤- លិ** គឺលិខិត ប្រែថា សរសេរកត់ត្រានូវអ្វីដែលខ្លួនចាំនោះ ។

➢. កាលបើស្តាប់មិនយល់ ត្រូវគិតរកហេតុផល គិតមិនឃើញ ត្រូវសួរដើម្បីឱ្យអស់សេចក្តីសង្ស័យ កាលអស់សេចក្តីសង្ស័យហើយ ត្រូវសរសេរទុកនៅក្នុងសៀវភៅឱ្យល្អ ។

## ប្រភេទរបស់បណ្ឌិត

បណ្ឌិតមាន ២ ប្រភេទគឺ ៖

**១- បណ្ឌិតខាងក្រៅ** គឺបុគ្គលទូទៅមិនថា អ្នកណាក៏ដោយ ដែលជាអ្នកប្រព្រឹត្តល្អ មានគុណធម៌ចេះរៀបចំដំណើរជីវិតដោយបញ្ញា ។

**២- បណ្ឌិតខាងក្នុង** គឺខ្លួនយើងនៅពេលដែលគិតល្អ និយាយល្អនិងការធ្វើល្អនោះឯង ដូច្នេះការសេពគប់បណ្ឌិតខាងក្នុងក៏គឺការព្យាមហ្វឹកហាត់ខ្លួន ឱ្យជាអ្នកមានចិត្តផូរផង់ថ្លា មានសតិរលឹកដល់ការគិតល្អ ៗ ដើម្បីប្រយោជន៍ដល់ខ្លួនឯងនិងអ្នកដទៃ ដែលធ្វើបានដោយការឧស្សាហ៍ ព្យាយាមធ្វើទាន រក្សាសីល និងធ្វើសមាធិជានិច្ច ។

## ផលានិសង្សក្នុងភាពជាបណ្ឌិត

បុគ្គលដែលបានអប់រំខ្លួន ដោយស្ថិតនៅក្នុងសេចក្ដីល្អរហូតដល់បានក្លាយទៅជាបណ្ឌិតនោះ រមែងមានអានិសង្សផងដែរ សម្រាប់ខ្លួនឯង មិនមែនមានតែអ្នកដែលចូរមកសេពគប់នោះទេ,

ដូចជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់អនុគ្រោះមុនគេ( **បឋមំ អនុ-កម្បន្តិ** ) ព្រះសម្មាសម្ពុទ្ធតែងចូលទៅជិតមុនគេ ( **បឋមំ ឧបសំក-មន្តិ** ) ព្រះសម្មាសម្ពុទ្ធតែងសម្តែងធម៌ឱ្យស្តាប់មុនគេ, ( **បឋមំ ធម្មទេសនំ** ) ព្រះសម្មាសម្ពុទ្ធតែងចូលទៅទទួលទានមុនបុគ្គលដែលជាអ្នកមិនមានទូវសទ្ធា ជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ, ( **បឋមំ បដិគណ្ហន្តិ** ) និងបុគ្គលនោះបន្ទាប់អំពីបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់សុគតិសួគ៌ ទេវលោក ( **សគ្គលោកំ ឧបបជ្ជតិ** ) ។

## សីហសូត្រ

នៅក្នុងបិដកលេខ ៤៧, ទំព័រ ១៤៥ ព្រះអង្គទ្រង់ត្រាស់ជាមួយសីហសេនាបតី [**ដែលនិយាយអំពីសេនាបតី**] ដោយមានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ សីហសេបតី( សេនាបតីឈ្មោះសីហៈ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះ

សេនាបតីអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចនឹងពន្យល់នូវផលនៃទានដែលបុគ្គលឃើញដោយខ្លួនឯងបានដែរឬ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ បើដូច្នោះតថាគតនឹងត្រឡប់សួរក្នុងរឿងនុ៎ះវិញ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយនូវរឿងនោះយ៉ាងនោះចុះ ។ ម្នាលសីហៈអ្នកសំគាល់នូវរឿងនោះដូចម្ដេច ។ ក្នុងលោកនេះមានបុរសពីរនាក់ បុរសម្នាក់មិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ។ ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្ដេច ។ ព្រះអរហាត្តទាំងឡាយកាលអនុគ្រោះ តើគួរនឹងអនុ-គ្រោះបុរសណាមុន ( អនុគ្រោះ )បុរសដែលមិនមែនសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញជាអ្នកជេរប្រទេចឬ( អនុគ្រោះ )បុរសដែលមានសទ្ធាជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ។

**សី.** បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចព្រះអរហាត្តទាំងឡាយកាលអនុគ្រោះនឹងអនុគ្រោះបុរសនោះមុន ដូចម្ដេច ។ បពិត្រព្រះ

អង្គដ៏ចម្រើន បុរសណាមានសទ្ធាជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ព្រះអរហន្តទាំងឡាយកាលអនុគ្រោះ គួរអនុគ្រោះបុរសនោះឯងមុន ។

**ភ.**ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលចូលទៅរក តើគួរចូលរកបុរសណាមុន ( ចូលទៅរក ) បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ( ចូលទៅរក )បុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ។

**សី.** បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចព្រះអរហន្តទាំងឡាយកាលចូលទៅរកនឹងចូលទៅរកបុរសនោះមុនដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ព្រះអរហន្តទាំងឡាយ កាលចូលទៅរកគួរចូលទៅរកបុរសនោះឯងមុន ។

**ភ.** ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលទទួលយក( ទាន ) គួរទទួលយក( ទាន )

របស់បុរសណាមុន ( ទទួលយកទាន )របស់បុរសដែលមិនមាន សទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ ( ទទួលយកទាន )របស់បុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ។

**សី.** បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចព្រះអរហត្តទាំងឡាយកាលទទួលយក( ទាន ) នឹងទទួលយក( ទាន )របស់បុរសនោះមុន ដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធាជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ព្រះអរហត្តទាំងឡាយ កាលទទួលយក( ទាន ) គួរទទួលយក( ទាន )របស់បុរសនោះឯងមុន ។

**ភ.** ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហត្តទាំងឡាយកាលសំដែងធម៌ តើគួរសំដែងដល់បុរសណាមុន ( សំដែង )ដល់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចឬ( សំដែង )ដល់បុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ។

សី. បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេចព្រះអរហត្តទាំងឡាយ កាលសំដែងធម៌ នឹងសំដែងដល់បុរសនោះមុនដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ព្រះអរហត្តទាំងឡាយ កាលសំដែងធម៌ គួរសំដែងដល់បុរសនោះឯងមុន ។

ភ. ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ កិត្តិស័ព្ទដ៏ពីរោះរបស់បុរសណាហ្ន៎ គប្បីខ្ចរខ្ចាយទៅ ( កិត្តិស័ព្ទ ) របស់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ( ខ្ចរខ្ចាយទៅ ) ឬ ( កិត្តិស័ព្ទ ) របស់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ ( ខ្ចរខ្ចាយទៅ ) ។

សី. បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច កិត្តិស័ព្ទដ៏ពីរោះរបស់បុរសនោះនឹងខ្ចរខ្ចាយទៅដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរ

ក្នុងការឱ្យទានរឿយ ៗ កិត្តិស័ព្ទរបស់បុរសនោះឯង គួរនឹងខ្ចរខ្ចាយទៅបាន ។

**ភ.** ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្ដេច ។ បុរសដូចម្ដេចហ្ន៎ គប្បីចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្ដី ព្រាហ្មណបរិស័ទក្ដី គហបតីបរិស័ទក្ដី សមណបរិស័ទក្ដី ជាអ្នកក្លៀវក្លា មិនញញើតញញើម គប្បីចូលទៅរកបរិស័ទនោះបាន បុរសណាមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬបុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ (គប្បីចូលទៅរកបរិស័ទនោះបាន) ។

**សី.** បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសនោះនឹងចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិសទ្យក្ដី ព្រាហ្មណបរិសទ្យក្ដី គហបតិបរិសទ្យក្ដី សមណបរិសទ្យក្ដី ជាអ្នកក្លៀវក្លា មិនញញើតញញើម នឹងចូលទៅរកបរិសទ្យនោះ ដូចម្ដេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ បុរសនោះគប្បីចូលទៅរកបរិសទ្យ

ណា ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើមគប្បីចូលទៅរកបរិសទ្យនោះ ដូចម្តេចបាន ។

**ភ.** ម្នាលសីហៈ អ្នកសំគាល់នូវរឿងនោះដូចម្តេច ។ បុរសដូចម្តេចហ៎ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីទៅកើតក្នុងសុគតិ សួគ៌ ទេវលោកបាន បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬបុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ (គប្បីទៅកើតក្នុងសុគតិ សួគ៌ ទេវលោក) ។

**សី.** បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោកដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមានសទ្ធាជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឱ្យទានរឿយ ៗ បុរសនោះលុះបែកធាយរាងកាយស្លាប់ទៅគប្បីទៅកើតក្នុងសុគតិ សួគ៌ ទេវលោកបាន ។

បពិត្រព្រះអង្គដ៏ចម្រើន ផលនៃទានដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯងទាំង ៦ នេះ ព្រះដ៏មានព្រះភាគសំដែងហើយ ខ្ញុំព្រះអង្គមិនបានដល់នូវសេចក្ដីជឿព្រះដ៏មានព្រះភាគ ក្នុងហេតុនុ៎ះទេ ខ្ញុំព្រះអង្គក៏ចុនដឹងច្បាស់នូវផលនៃទានទាំងនោះដែរ ។

៤. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហត្តទាំងឡាយ កាលចូលទៅរកជាម្ចាស់ទាន ព្រះអរហត្តទាំងឡាយ កាលអនុគ្រោះ រមែងអនុគ្រោះនូវខ្ញុំព្រះអង្គមុន ។

៤. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហត្តទាំងឡាយ រមែងចូលទៅរកខ្ញុំព្រះអង្គមុន ។

៤. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហត្តទាំងឡាយ កាលទទួលយកទាន រមែងទទួលយកទានរបស់ខ្ញុំព្រះអង្គមុន ។

៤. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហត្តទាំងឡាយ កាលសំដែងធម៌ រមែងសំដែងដល់ខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជា

ម្ចាស់ទាន កិត្តិស័ព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ ខ្ចរខ្ចាយទៅថា សីហ-
សេនាបតី ជាទាយក ជាអ្នកធ្វើ ជាអ្នកបម្រើសង្ឃ ។

៤.បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ចូលទៅរកបរិសទ្យណា ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ខ្ញុំព្រះអង្គជាអ្នកក្លៀវក្លា មិនញញើតញញើម រមែងចូលទៅរកបរិសទ្យនោះបាន ។

បពិត្រព្រះអង្គដ៏ចម្រើន ផលនៃទានដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯងទាំង ៦ នេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ខ្ញុំព្រះអង្គមិនដល់នូវសេចក្តីជឿព្រះដ៏មានព្រះភាគ ក្នុងហេតុនុ៎ះទេ ខ្ញុំព្រះអង្គក៏បានដឹងច្បាស់នូវផលនៃទានទាំងនុ៎ះដែរ ចំណែកដែល ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវផលនៃទានណានឹងខ្ញុំព្រះអង្គ យ៉ាងនេះថា ម្នាលសីហៈបុគ្គលជាទាយក ជាម្ចាស់ទាន លុះបែក ធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកើតក្នុងសុគត សួគ៌ ទេវ-លោក ខ្ញុំព្រះអង្គមិនបានដឹងច្បាស់នូវផលនៃទាននោះទេ ឥឡូវ ខ្ញុំព្រះអង្គដល់នូវសេចក្តីជឿព្រះដ៏មានព្រះភាគ ត្រង់ផលនៃទាននុ៎ះ ។

**ភ.** ម្នាលសីហៈ ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ ម្នាលសីហៈ

ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ ម្នាលសីហៈ បុគ្គលជាទាយក ជាម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។

## អដ្ឋកថា

បទថា មច្ឆរី បានដល់ បុគ្គលដែលប្រកបដោយសេចក្ដីកំណាញ់ ៥ យ៉ាង ។

បទថា កទរិយោ សេចក្ដីថា បុគ្គលដែលមានសេចក្ដីកំណាញ់ស្វិត រមែងហាមសូម្បីកាលជនពួកដទៃអ្នកនឹងឱ្យទាន ។

បទថា អនុប្បទានរតោ សេចក្ដីថាកាលនឹងឱ្យទានរឿយ ៗ ក៏រមែងត្រេកអរ ។

បទថា អនុកម្បន្តា សេចក្ដីថា អ្នកអនុគ្រោះដោយគិតយ៉ាងនេះថា ថ្ងៃនេះយើងនឹងអនុគ្រោះអ្នកណា ពួកយើងនឹងគប្បីទទួលទេយ្យធម៌របស់អ្នកណា ឬ ពួកយើងនឹងគប្បីសម្ដែងធម៌ដល់អ្នកណា ។

## ឯកធម្មបេយ្យាលទី ៧ បឋមកល្យាណមិត្តសូត្រ

នៅក្នុងបិដកលេខ ៣៧, ទំព័រ ៧០ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពី[**កល្យាណមិត្តមានឧបការៈច្រើនដល់អរិយមគ្គ**] មានសេចក្តីថា ៖

**សាវត្ថីនិទាន** ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ មានឧបការៈច្រើន ដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យកើតឡើង ។ ធម៌ ១ តើដូចម្តេច ។ **គឺការមានមិត្តល្អ** ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះ ជាទីសង្ឃឹមរបស់ភិក្ខុដែលជាអ្នកមានមិត្តល្អ ភិក្ខុនោះនឹងចំរើន អរិយមគ្គប្រកបដោយអង្គ ៨ នឹងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលមានមិត្តល្អ រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង តើដូចម្តេច ។

១. ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងចំរើនសេចក្តីឃើញត្រូវ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យ

សេចក្ដីនឿយណាយ អាស្រ័យសេចក្ដីរលត់ បង្អោនទៅក្នុងការលះ (ចម្រើននូវ**សម្មាសង្កប្បៈ** សេចក្ដីត្រិះរិះត្រូវ, ចម្រើននូវ**សម្មាវាចា** សម្ដីត្រូវ, ចម្រើននូវ**សម្មាកម្មន្ត** ការងារត្រូវ, ចម្រើននូវ**សម្មា-អាជីវៈ** ចិញ្ចឹមជីវិតត្រូវ, ចម្រើននូវ**សម្មាវាយាម** សេចក្ដីព្យា-យាមត្រូវ, ចម្រើននូវ**សម្មាសតិ** សេចក្ដីរលឹកត្រូវ, ចម្រើននូវ**សម្មាសមាធិ** សេចក្ដីដម្កល់ចិត្តក្នុងអារម្មណ៍ដ៏ត្រូវ) រមែងចំរើនសេចក្ដីតាំងចិត្តត្រូវ អាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីនឿយណាយ អាស្រ័យសេចក្ដីរលត់ បង្អោនទៅក្នុងការលះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាអ្នកមានមិត្តល្អ រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គ ប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ដោយប្រការយ៉ាងនេះឯង ។

## សុរិយបេយ្យាលទី ៦ បឋមកល្យាណមិត្តសូត្រ

នៅក្នុងបិដកលេខ៣៧,ទំព័រ៦៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្ដែងអំពី[**មិត្តល្អជានិមិត្តនៃអរិយមគ្គ**]មានសេចក្ដីថា ៖

**សាវត្ថីនិទាន** ។ ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ

នេះជាប្រធាន នេះជាបុព្វនិមិត្ត ( គ្រឿងកំណត់មុន ) នៃព្រះអាទិត្យ ដែលរះឡើង ។ ម្នាលភិក្ខុទាំងឡាយ **ការមានមិត្តល្អ** នេះជាប្រធាន នេះជាបុព្វនិមិត្តប្រព្រឹត្តទៅដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យកើតឡើងដល់ភិក្ខុ ដោយប្រការយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះជាទីសង្ឃឹមរបស់ភិក្ខុដែលមានមិត្តល្អ ភិក្ខុនោះនឹងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ នឹងធ្វើអរិយមគ្គប្រកបដោយអង្គឱ្យច្រើនឡើង ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលមានមិត្តល្អ រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងចំរើនសេចក្តីឃើញត្រូវដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីនឿយណាយ អាស្រ័យសេចក្តីរលត់បង្អោនទៅក្នុងការលះ ( ចម្រើននូវសម្មាសង្កប្បៈ... ចម្រើននូវសម្មាវាចា... ចម្រើននូវសម្មាកម្មន្ត... ចម្រើននូវសម្មាអាជីវៈ... ចម្រើននូវសម្មាវាយាម...ចម្រើននូវសម្មាសតិ...ចម្រើននូវសម្មាសមាធិ... ) រមែងចំរើនសេចក្តីតាំងចិត្តត្រូវអាស្រ័យសេចក្តីស្ងប់

ស្ងាត់ អាស្រ័យសេចក្តីនឿយណាយ អាស្រ័យសេចក្តីរលត់ បង្អោនទៅក្នុងការលះ ។

ម្នាលភិក្ខុទាំងឡាយ **ភិក្ខុដែលមានមិត្តល្អ** រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើងដោយប្រការយ៉ាងនេះឯង ។

## នាហន្តឯកធម្មបេយ្យាលទី ៨ បឋមកល្យាណមិត្តសូត្រ

នៅក្នុងបិដកលេខ៣៧,ទំព័រ៦៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងអំពី [**កល្យាណមិត្តជាហេតុឱ្យកើតអរិយមគ្គ**]មានសេចក្តីថា ៖

**សាវត្ថីនិទាន** ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញនូវធម៌ដទៃសូម្បីមួយ ដែលជាហេតុឱ្យអរិយមគ្គប្រកបដោយអង្គ៨ មិនទាន់កើតឡើង ឱ្យកើតឡើងបានក្តី ឱ្យអរិយមគ្គប្រកបដោយអង្គ ៨ ដែលកើតឡើងហើយ ដល់នូវការពេញបរិបូណ៌ដោយភាវនាក្តី ។ ម្នាលភិក្ខុទាំងឡាយ (តថាគតពិចារណាមិនឃើញធម៌ដទៃ) ដូចជាការមានមិត្តល្អនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយដំណើរនេះជាទីសង្ឃឹមរបស់ភិក្ខុដែលមានមិត្តល្អ

ភិក្ខុនោះនឹងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ នឹងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ។

ម្នាលភិក្ខុទាំងឡាយ **ចុះភិក្ខុដែលមានមិត្តល្អ** រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង តើដូចមេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងចំរើនសេចក្ដីឃើញត្រូវ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីនឿយណាយ អាស្រ័យសេចក្ដីរលត់ បង្អោនទៅក្នុងការលះ (ចម្រើននូវសម្មាសង្កប្បៈ... ចម្រើននូវសម្មាវាចា... ចម្រើននូវសម្មាកម្មន្ត... ចម្រើននូវសម្មាអាជីវៈ... ចម្រើននូវសម្មាវាយាម... ចម្រើននូវសម្មាសតិ... ចម្រើននូវសម្មាសមាធិ...) រមែងចំរើនសេចក្ដីតាំងចិត្តត្រូវអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីនឿយណាយ អាស្រ័យសេចក្ដីរលត់ បង្អោនទៅក្នុងការលះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាអ្នកមានមិត្តល្អ រមែងចំរើនអរិយមគ្គប្រកបដោយអង្គ ៨ រមែងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ដោយប្រការយ៉ាងនេះឯង ។

# តួនាទីរបស់មិត្ត

ក្នុងសិង្គាលកសូត្រ ព្រះអង្គត្រាស់ពីតួនាទីរបស់មិត្ត ចំពោះសិង្គាលកមាណពថា ម្នាលគហបតិបុត្ត មិត្តអាមាត្យជាទិសខាងជើងកុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ៥ យ៉ាងគឺ ៖

១- ទានេន ដោយការឱ្យរបស់

២- បិយវជ្ជេន ដោយការនិយាយតែពាក្យគាប់ចិត្ត

៣- អត្ថចរិយាយ ដោយការប្រព្រឹត្តឱ្យជាប្រយោជន៍

៤- សមានត្តតាយ ដោយការប្រព្រឹត្តខ្លួនស្មើ

៥- អវិសំវាទនតាយ ដោយការមិនកុហកបញ្ឆោត ។

ម្នាលគហបតិបុត្ត មិត្តអាមាត្យ ជាទិសខាងជើងកុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងគឺ ៖

១- បមត្តំ រក្ខន្តិ រក្សាមិត្តដែលធ្វេសប្រហែស

២- បមត្តស្ស សាបតេយ្យំ រក្ខន្តិ ជួយថែទាំទ្រព្យសម្បត្តិរបស់មិត្ត ដែលធ្វេសប្រហែស

៣- ភីតស្ស សរណំ ហោន្តិ ជាទីពឹងរបស់មិត្តដែលមានភ័យ

៤- អាបទាសុ ន វិជហន្តិ មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ

៥- អបរបជំបិស្ស បដិបូជេន្តិ រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ។

ម្នាលគហបតិបុត្ត មិត្តអាមាត្យ ជាទិសខាងជើងដែលកុលបុត្តត្រូវប្រតិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន៥ យ៉ាងនេះ ទិសខាងជើងនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

## រឿងសន្តតិមហាមាត្យ

នៅក្នុងអដ្ឋកថាលេខ ៤២, ទំព័រ ១១៣ ព្រះអង្គទ្រង់នូវរឿងរបស់សន្តតិមហាអាមាត្យ ទាក់ទងទៅនឹងការធ្វើតួនាទីរបស់មិត្ត ដោយមានសេចក្តីថា ៖

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ

សន្តតិមហាមាត្យ ត្រាស់ព្រះធម៌ទេសនានេះថា “អលង្កតោ ចេបិ សមញ្ចរេយ្យ” ជាដើម ។

[សន្តតិមហាមាត្យបានគ្រងរាជសម្បត្តិ ៧ ថ្ងៃ]

សេចក្តីពិស្តារថា ក្នុងកាលគ្រាមួយ សន្តតិមហាមាត្យនោះ បង្ក្រាបបច្ចន្តជនបទ របស់ព្រះបាទបសេនទិកោសលដែលកំរើក ឱ្យស្ងប់ហើយត្រឡប់មក ។

តមក ព្រះរាជាទ្រង់ពេញព្រះទ័យ ប្រទានរាជសម្បត្តិឱ្យ ៧ ថ្ងៃ បានប្រទានស្ត្រីអ្នកឆ្លាតក្នុងការរាំ និងការច្រៀងម្នាក់ ដល់គេ ។ គេជាអ្នកស្រវឹងសុរាអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ហើយឡើងកាន់កដំរីមួយ ដ៏ប្រសើរទៅកាន់កំពង់ងូតទឹក ឃើញព្រះសាស្តាកំពុងស្តេចចូល ទៅបិណ្ឌបាតត្រង់ចន្លោះទ្វារ នៅលើកដំរីមួយដ៏ប្រសើរទុំះឯង កម្មេចផង់សិរសះថ្វាយបង្គំហើយ ។

ព្រះសាស្តាទ្រង់ធ្វើការញញឹម ព្រះអានន្ទទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ? ជាហេតុឱ្យទ្រង់ធ្វើការញញឹម ឱ្យប្រាកដ”កាលទឹងត្រាស់ប្រាប់ហេតុនៃការញញឹមទើបត្រាស់ថា

"អានន្ទ លោកចូរមើលសន្តតិមហាមាត្យ,ក្នុងថ្ងៃនេះឯង គេទាំងប្រដាប់ដោយអាភរណៈដែលប្រកបដោយបទ ៤ ហើយ អង្គុយលើអាកាស ៧ ជួរដើមត្នោត នឹងបរិនិព្វាន" ។

មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ដែលកំពុងត្រាស់នឹងព្រះថេរៈ ។

**(មនុស្ស ២ ពួកមានសេចក្តីគិតផ្សេងគ្នា)**

បណ្តាមហាជនទាំងនោះពួកមិច្ឆាទិដ្ឋិ គិតថា "លោកទាំងឡាយ ចូរមើលកិរិយារបស់ព្រះសមណគោតម, ព្រះសមណ-គោតមនោះ រមែងនិយាយត្រឹមតែមាត់ប៉ុណ្ណោះ, បានឮថា ក្នុងថ្ងៃនេះ សន្តតិមហាមាត្យនោះ ស្រវឹងសុរាយ៉ាងនោះ តែងខ្លួនទៅតាមប្រក្រតី ស្តាប់ព្រះធម៌ក្នុងសំណាក់របស់ព្រះសមណគោតម នោះដោយមុសាវាទ" ។

ពួកសម្មាទិដ្ឋិ គិតគ្នាថា "គួរអស្ចារ្យ ព្រះពុទ្ធទាំងឡាយមានអានុភាពច្រើន, ក្នុងថ្ងៃនេះយើងទាំងឡាយនឹងបានមើលការនិមន្តយ៉ាងសង្ហាររបស់ព្រះពុទ្ធ និង ការនិមន្តយ៉ាងសង្ហាររបស់សន្តិមហាមាត្យ" ។

ចំណែកសន្តិមហាមាត្យ លេងទឹករហូតដល់ថ្ងៃហើយទៅកាន់ឧទ្យាន អង្គុយលើផែនដីរោងផឹក ។

(ស្រីរបាំកើតរោគខ្យល់ស្លាប់)

ចំណែកស្រីនោះ ចុះទៅត្រង់កណ្តាលលោតរាំ ផ្តើមទើងសម្តែងការរបាំនិងការច្រៀង,កាលនាងសម្តែងការរាំ ការច្រៀងនៅក្នុងថ្ងៃនោះ ខ្យល់មានពិសប្រៀបដូចសស្ត្រាកើតឡើងហើយខាងក្នុងពោះ បានកាត់សាច់ហទយៈហើយ ព្រោះសេចក្តីដែលនាងជាអ្នកមានអាហារតិចអស់ ៧ ថ្ងៃ ដើម្បីសម្តែងសេចក្តីភូតភរនៃសរីរៈ ។ ក្នុងភ្លាមនោះឯង នាងមានមាត់ហានិងភ្នែកលឿងបានធ្វើមរណកាលហើយ ។

(មានសេចក្តីសោកព្រោះភរិយាស្លាប់)

សន្តិមហាមាត្យ ពោលថា "លោកទាំងឡាយចូរត្រួតមើលនាងនោះ" ក្នុងខណៈត្រឹមតែថាពាក្យដែលជនទាំងឡាយពោលថា "ស្រីនោះស្លាប់ហើយ នាយ" ដូច្នេះ ត្រូវសេចក្តីសោកយ៉ាងខ្លាំងក្លាគ្របសង្កត់ហើយ ។ ក្នុងខណៈនោះឯង សុរាដែលលោកផឹករហូតដល់អស់ ៧ ថ្ងៃ បានដល់សេចក្តីវិនាសហើយ ដូចជាតំណក់

ទឹកលើក្បៀនក្នុងវេលាក្តៅដូច្នោះ ។ លោកគិតថា "អ្នកដទៃ វៀរព្រះតថាគតចេញ នឹងមិនអាចដើម្បីនឹងញ៉ាំងសេចក្តីសោករបស់យើងនេះឱ្យរលត់បានឡើយ" មានពលកាយហែហមហើយ ទៅកាន់សំណាក់របស់ព្រះអង្គ ក្នុងវេលាល្ងាចថ្វាយបង្គំហើយក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោកបែបនេះកើតឡើងដល់ខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គមកហើយ ក៏ដោយសំដៅថា ព្រះអង្គនឹងអាចដើម្បីនឹងរលត់សេចក្តីសោក របស់ខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គមកហើយ ក៏ដោយសំដៅថា ព្រះអង្គអាចដើម្បីនឹងរលត់ សេចក្តីសោករបស់ខ្ញុំព្រះអង្គនោះបាន, សូមព្រះអង្គចូរទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គចុះ" ។

## [ព្រះសាស្តារម្ងាប់សេចក្តីសោករបស់មនុស្សបាន]

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងសន្តិមហាមាត្យថា "លោកមកកាន់សំណាក់របស់តថាគត អ្នកដែលអាចដើម្បីរំលត់សេចក្តីសោកបាន ពិតប្រាកដ, ហើយកាលដែលពិត ទឹកភ្នែកដែលហូរចេញរបស់អ្នកស្រែកយំ ក្នុងវេលាដែលស្រីនេះស្លាប់ដោយហេតុនេះនុ៎ះឯង ច្រើនជាងទឹករបស់មហាសមុទ្រទាំង ៤" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

"កិលេសគ្រឿងកង្វល់ណា មាននៅក្នុងកាលមុន លោកចូរញុំាងកិលេសគ្រឿងកង្វល់នោះ ឱ្យស្ងួតហួតហែងទៅ កិលេស គ្រឿងកង្វល់ ចូរកុំមានដល់លោកក្នុងខាងកាលក្រោយ, បើលោកនឹងមិនគោងកាន់យកខន្ធ ត្រង់កណ្ដាលនឹងជាអ្នកស្ងប់រម្ងាប់ ត្រាច់ទៅ" ។ ក្នុងកាលចប់ព្រះគាថា សន្តតិមហាមាត្យសម្រេចព្រះអរហត្តហើយ ពិចារណាមើលអាយុសង្ខាររបស់ខ្លួនជ្រាបថា ការប្រព្រឹត្តទៅមិនបាននៃអាយុសង្ខារនោះហើយ ទើបក្រាបទូលព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុញ្ញាត ការបរិនិព្វានដល់ខ្ញុំព្រះអង្គចុះ" ។

ព្រះសាស្ដា សូម្បីទ្រង់ជ្រាបកម្មដែលលោកធ្វើហើយ ក៏ទ្រង់កំណត់ថា "ពួកមិច្ឆាទិដ្ឋិប្រជុំគ្នាដើម្បីសង្កត់សង្កិន (យើង) ដោយមុសាវាទនឹងមិនបានឱកាស ពួកសម្មាទិដ្ឋិប្រជុំគ្នាដោយសំដៅថា ពួកយើងនឹងមើលការយាងរបស់ព្រះពុទ្ធនិងការមករបស់សន្តតិមហាមាត្យ ស្ដាប់កម្មដែលសន្តតិមហាមាត្យនេះធ្វើហើយ នឹងធ្វើសេចក្ដីអើពើក្នុងបុណ្យទាំងឡាយ" ដូច្នេះហើយទើបត្រាស់ថា "បើដូច្នោះ លោកចូរប្រាប់កម្មដែលលោកធ្វើហើយ

ដល់យើង, ក៏កាលនឹងប្រាប់ ចូរកុំឈរលើផែនដីប្រាប់ ចូរឈរលើអាកាសអស់៧ ជួរដើមត្នោត ហើយទើបប្រាប់" ។ សម្តេងឥទ្ធិបាដិហារ្យក្នុងអាកាស សន្តតិមហាមាត្យនោះ ទូលទទួលថា "ល្អណាស់ ព្រះអង្គ" ដូច្នេះហើយ ទើបថ្វាយបង្គំព្រះសាស្តា ហើយ ឡើងទៅកាន់អាកាសមួយជួរដើមត្នោត ចុះមកថ្វាយបង្គំព្រះសាស្តាទៀតឡើងទៅអង្គុយដោយបល្ល័ង្កលើអាកាស ៧ តំណដើមត្នោតតាមលំដាប់ហើយទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ស្តាប់បុព្វកម្មរបស់ខ្ញុំព្រះអង្គ" ( ដូចតទៅនេះ ) ៖

បុព្វកម្មរបស់សន្តតិមហាមាត្យក្នុងកប្បទី៩១ ពីកប្បនេះគ្រាព្រះពុទ្ធទ្រង់ព្រះនាមថា វិបស្សី ខ្ញុំព្រះអង្គកើតក្នុងត្រកូលមួយ ក្នុងពន្ធុមតីនគរ ហើយគិតថា អ្វីហ្ន៎ ? ជាកម្មដែលមិនធ្វើការកាត់បង់ឬបៀតបៀន នូវជនពួកដទៃ ដូច្នេះហើយ កាលពិចារណា ទើបឃើញកម្មគឺ ការស្រែកប្រកាសក្នុងបុណ្យទាំងឡាយ ចាប់តាំងពីកាលនោះ តែងកម្មនោះហើយបបួលមហាជនត្រាច់ ស្រែកប្រកាសថា 'ពួកលោកចូរធ្វើបុណ្យទាំងឡាយ, ចូរសមាទានឧបោសថ ក្នុងថ្ងៃឧបោសថទាំងឡាយ, ចូរថ្វាយទាន,

ចូរស្តាប់ធម៌, ឈ្មោះថា រតនៈយ៉ាងដទៃដូចជាពុទ្ធរតនៈជាដើម មិនមាន, ពួកលោកចូរធ្វើសក្ការៈរតនៈទាំង ៣ ចុះ" ។

## [ផលរបស់ការបបួលមហាជនបំពេញកុសល]

ព្រះរាជាអ្នកជំទ្រង់ព្រះនាមថា ពន្ធុមៈ ជាព្រះពុទ្ធបិតាទ្រង់ស្តាប់សំឡេងរបស់ខ្ញុំព្រះអង្គនោះ បង្គាប់ឱ្យហៅខ្ញុំព្រះអង្គមកគាល់ហើយ ត្រាស់សួរថា ម្នាលអ្នក ឯងដើរធ្វើអ្វី ? កាលខ្ញុំព្រះអង្គទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គដើរប្រកាសគុណរតនៈទាំង ៣ បបួលមហាជនទាំងឡាយឱ្យធ្វើបុណ្យទាំងឡាយ ។ ទើបត្រាស់សួរថា អ្នកឯងអង្គុយលើអ្វីត្រាច់ទៅ ? កាលខ្ញុំព្រះអង្គទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គដើរទៅ ទើបត្រាស់ថា ម្នាលអ្នក អ្នកឯងមិនគួរដើម្បីដើរទៅយ៉ាងនោះ, ចូរប្រដាប់កម្រងផ្កាឈើនេះហើយ អង្គុយលើខ្នងសេះដើរទៅចុះ ដូច្នេះហើយ ក៏ព្រះរាជទានកម្រងផ្កាឈើ ដូចនឹងក្អួងកែវមុក្តា ទាំងបានព្រះរាជទានសេះដែលទូន្មានហើយដល់ខ្ញុំព្រះអង្គ ។

តមកព្រះរាជាបង្គាប់ឱ្យខ្ញុំព្រះអង្គ អ្នកកំពុងត្រាច់ប្រកាសទៅយ៉ាងនោះឯង ដោយគ្រឿងបរិហារដែលព្រះរាជាព្រះរាជទាន

មកគាល់ហើយត្រាស់សួរទៀតថា ម្នាលអ្នក អ្នកឯងត្រាច់ធ្វើអ្វី ? កាល ខ្ញុំព្រះអង្គទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មយ៉ាងនោះឯង ទើបត្រាស់ថា ម្នាលអ្នក សូម្បីសេះក៏មិនសមគួរដល់អ្នកឯង អ្នកឯងចូរអង្គុយលើរថនេះត្រាច់ទៅចុះ ហើយបានព្រះរាជទានរថដែលទឹមដោយសេះសិន្ធព ៤ ។ សូម្បីក្នុងគ្រាទី ៣ ព្រះរាជាទ្រង់ស្ដាប់សំឡេងរបស់ខ្ញុំព្រះអង្គហើយ បន្ទាប់ឱ្យរកត្រាស់សួរថា ម្នាលអ្នក អ្នកឯងត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មនោះឯង ទើបត្រាស់ថា នែអ្នក សូម្បីរថក៏មិនសមគួរដល់អ្នកឯង ហើយព្រះរាជទានភោគៈជាច្រើននិងគ្រឿងប្រដាប់ធំ ទាំងបានព្រះរាជទានដំរីខ្សែមួយដល់ខ្ញុំព្រះអង្គ ។ ខ្ញុំព្រះអង្គនោះ ប្រដាប់ដោយអាភរណៈគ្រប់យ៉ាងអង្គុយលើកដំរី បានធ្វើកម្មរបស់អ្នកស្រែកប្រកាសធម៌អស់ ៨ ម៉ឺនឆ្នាំ ក្លិនចន្ទន៍សាយចេញពីកាយរបស់ខ្ញុំព្រះអង្គនោះ ក្លិនឧប្បលសាយ ចេញពីមាត់ រហូតដល់អស់កាលមានប្រមាណប៉ុណ្ណោះនេះជាកម្មដែលខ្ញុំព្រះអង្គធ្វើហើយ” ។

## [ការបរិនិព្វានរបស់សន្តតិមហាមាត្យ]

សន្តតិមហាមាត្យនោះ ក្រាបទូលបុព្វកម្មរបស់ខ្លួនយ៉ាងនោះហើយ អង្គុយលើអាកាស ចូលតេជោធាតុបរិនិព្វានហើយ ។ អណ្តាតភ្លើងកើតឡើងក្នុងសរីរៈឆេះសាច់និងលោហិតហើយ ។ ធាតុទាំងឡាយដូចផ្កាម្លិះនៅសល់នៅហើយ ។

ព្រះសាស្តាទ្រង់ត្រដាងសំពត់ស ។ ធាតុទាំងឡាយក៏ធ្លាក់ចុះលើសំពត់សនោះ ។

ព្រះសាស្តា ទ្រង់បញ្ចុះធាតុទាំងនោះហើយបង្គាប់ឱ្យសាងសថូបទុកត្រង់ផ្លូវធំបែកជា ៤ ដោយទ្រង់ប្រាថ្នាថា "មហាជនថ្វាយបង្គំហើយនឹងជាអ្នកមានចំណែកនៃបុណ្យ" ។ សន្តតិមហាមាត្យគួរហៅថា សមណៈឬព្រាហ្មណ៍ ពួកភិក្ខុសន្ទនាគ្នាក្នុងសាសាធម្មសភាថា "ម្នាលអ្នកមានអាយុ សន្តតិមហាមាត្យសម្រេចព្រះអរហត្តក្នុងវេលាចប់ព្រះគាថា ៗ គង់នៅលើអាកាសបរិនិព្វានហើយ, ការហៅបុគ្គលរបស់តថាគតសូម្បីថា សមណៈគួរឬហ្ន៎ ? ឬហៅលោកថាព្រាហ្មណ៍ ទើបនឹងគួរ" ។

ព្រះសាស្ដាស្ដេចមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកលោកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ? កាលភិក្ខុទាំងឡាយទូលថា "ពួកខ្ញុំព្រះអង្គ អង្គុយប្រជុំគ្នាដោយកថាឈ្មោះនេះ" ទើបត្រាស់ថា "ភិក្ខុទាំងឡាយការហៅបុត្ររបស់តថាគតសូម្បីថាសមណៈ ក៏គួរ,ហៅថា ព្រាហ្មណ៍ ក៏គួរដូចគ្នា" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថាថា ៖

អលង្កតោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលទៀង ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់បោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះហៅថាព្រាហ្មណ៍ក៏បាន ថាជាសមណៈក៏បាន ថាជាភិក្ខុក៏បាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អលង្កតោ** បានដល់ ប្រដាប់ដោយសំពត់និងអាភរណៈ ។ បណ្ឌិតគប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ថ្វីបើថាបុគ្គលនោះ នៅប្រដាប់ដោយគ្រឿងអលង្ការមានសំពត់ជាដើមក៏ដោយ ប៉ុន្តែជាអ្នកប្រព្រឹត្តស្មើដោយកាយជាដើម, ឈ្មោះថាជាអ្នកស្ងប់ ព្រោះការស្ងប់រម្ងាប់នៃរាគៈជាដើម, ឈ្មោះថា ជាអ្នកទូន្មាន ព្រោះទូន្មានឥន្ទ្រិយ, ឈ្មោះថាជាបុគ្គលទៀង ព្រោះទៀងក្នុងមគ្គទាំង ៤, ឈ្មោះថា ព្រហ្មចារី ព្រោះប្រព្រឹត្តដ៏ប្រសើរ, ឈ្មោះថា ដាក់អាជ្ញាក្នុងសត្វគ្រប់ជំពូក ព្រោះជាអ្នកដាក់ចុះនូវអាជ្ញាផ្លូវកាយជាដើម, បុគ្គលនោះគឺអ្នកបែបនោះ ដែលគេគួរហៅថា ព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបណ្តែតហើយក៏បាន, ថាសមណៈ ព្រោះជាអ្នកមានបាបស្ងប់ហើយក៏បាន, ថាភិក្ខុ ព្រោះជាអ្នកមានកិលេសទម្លាយហើយ ក៏បានដោយពិត ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

## សប្បុរិសធម៌ ៧ យ៉ាង

ធម៌របស់សប្បុរស ហៅថា **សប្បុរិសធម៌** មាន៧យ៉ាងគឺ ៖

**១-ធម្មញ្ញុតា** ភាពជាអ្នកស្គាល់ហេតុ ដូចស្គាល់ថា **នេះជាហេតុនៃសេចក្ដីសុខ នេះជាហេតុនៃសេចក្ដីទុក្ខ** ជាដើម ។

**២-អត្ថញ្ញុតា** ភាពជាអ្នកស្គាល់ផល ដូចស្គាល់ថា **សេចក្ដីសុខ ជាផលកើតអំពីហេតុនេះ ហេតុនោះ** ជាដើម ។

**៣-អត្តញ្ញុតា** ភាពជាអ្នកស្គាល់ខ្លួនថា **អាត្មាអញនេះមានជាតិ ត្រកូល យសស័ក្តិ បរិវារ សេចក្ដីចេះដឹង និងគុណធម៌ ដែលមានក្នុងខ្លួនត្រឹមតែប៉ុណ្ណោះ ហើយប្រព្រឹត្តតាមគួរដល់ឋានៈរបស់ខ្លួន** ។

**៤- មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុង**ការបរិភោគ** ជាដើម ។

**៥-កាលញ្ញុតា** ភាពជាអ្នកស្គាល់វេលាដែលគួរនឹងប្រកបកិច្ចការនោះ ៗ ។

**៦-បរិសញ្ញុតា** ភាពជាអ្នកស្គាល់ប្រជុំជននិងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះថា **ពួកនេះកាលចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះ ៗ ត្រូវនិយាយយ៉ាងនេះ ៗ ។**

**៧-បុគ្គលបរោបរញ្ញុតា** ភាពជាអ្នកស្គាល់បុគ្គលថា អ្នកនេះជាមនុស្សល្អ គួរគប់រក, **អ្នកនេះជាមនុស្សមិនល្អ មិនគួរគប់រកជាដើម ។**

## ហិរិជាតក

(ទូន្មានបរិវារឱ្យស្គាល់ដល់លក្ខណៈនៃមិត្តសម្លាញ់)

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីបច្ចន្តគ្រាមដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម៌ទេសនានេះមានពាក្យផ្ដើមថា **ហិរិន្តរន្តំ** ដូច្នេះ ។

រឿងទាំងពីរគឺរឿងបច្ចុប្បន្ននិងរឿងក្នុងអតីត មានពិស្ដារហើយក្នុងជាតកខាងចុងនៃនវមវគ្គ ឯកនិបាត ។ តែក្នុងជាតកនេះកាលបើមានអ្នកមកប្រាប់ដល់ពារាណសីសេដ្ឋីថា "មនុស្សរបស់សេដ្ឋីអ្នកបច្ចន្តគ្រាម ត្រូវបន្ទំយកទ្រព្យ មិនជាម្ចាស់របស់ ៗ ដែលជារបស់ខ្លួន នាំគ្នាគេចជៀសទៅហើយ" ពារាណសីសេដ្ឋី ទើប

ពោលថា ធម្មតាបុគ្គលអ្នកមិនធ្វើកិច្ចដែលនឹងគប្បីធ្វើដល់អ្នកមកកាន់សំណាក់របស់ខ្លួន រមែងមិនបានបុគ្គលអ្នកធ្វើតបជំនួសដូចគ្នា ហើយបានពោលគាថាទាំងនេះថា អ្នកណាអស់សេចក្ដីខ្មាស ស្អប់ខ្ពើម សេចក្ដីមានមេត្តាពោលថា យើងជាមិត្តសម្លាញ់របស់លោក តែមិនបានអើពើធ្វើការងារដែលល្អជាង បណ្ឌិតស្គាល់អ្នកនោះបានល្អជាងអ្នកនេះ មិនមែនមិត្តសម្លាញ់របស់យើង ។

ព្រោះថាបុគ្គលធ្វើយ៉ាងណា ក៏គប្បីពោលយ៉ាងនោះ មិនធ្វើយ៉ាងណា ក៏មិនគប្បីពោលយ៉ាងនោះ បណ្ឌិតទាំងឡាយស្គាល់បុគ្គលនោះថា អ្នកមិនធ្វើឱ្យសមនឹងការនិយាយ តែបែរជានិយាយថា យើងជាមិត្តសម្លាញ់របស់លោក ។

អ្នកណាមិនប្រមាទនៅគ្រប់ខណៈ ប្រាថ្នាសេចក្ដីបែកបាក់ ធ្លាប់តែចាប់សេចក្ដីខុស អ្នកនោះមិនឈ្មោះថា ជាមិត្ត ចំណែកអ្នកណាដែលអ្នកដទៃញុះញង់បែកគ្នាមិនបាន មិនរង្កៀសក្នុងមិត្តដេកនៅស្រួលមិនមានភ័យ ដូចបុត្រដេកអែបមាតាដូច្នោះ អ្នកនោះរាប់ថា ជាមិត្តពិត ។

កុលបុត្រអ្នកមើលឃើញផលនិងអានិសង្ស កាលនាំធុរៈ

នាទីរបស់កូនអ្នកប្រុសទៅនៅ រមែងធ្វើហេតុ គឺការធ្វើសេចក្ដីបាមោជ្ជ និងសេចក្ដីសុខដែលនាំមកនូវសេចក្ដីសរសើរ ឱ្យកើតមានឡើង ។

បុគ្គលបានផឹក រសដែលកើតពីវិវេករសនៃសេចក្ដីស្ងប់និងរសគឺធម្មបីតិ រមែងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ជាអ្នកអស់បាប ។

បណ្ដាបទទាំងនោះ បទថា ហិរិន្តរន្តំ បានដល់ ឈានកន្លងសេចក្ដីខ្មាស ។ បទថា **វិជិគុច្ឆមានំ** បានដល់ អ្នកស្អប់ការបម្រើនមេត្តា ។

បទថា តវាហមស្មិ សេចក្ដីថា និយាយតែពាក្យម្យ៉ាងប៉ុណ្ណោះថា យើងជាមិត្តរបស់លោក ។ បទថា សេយ្យានិ កម្មានិ សេចក្ដីថា អ្នកមិនអើពើ គឺមិនធ្វើកម្មដែលខ្ពស់បំផុត ដែលសមគួរដល់ពាក្យនិយាយថា នឹងឱ្យនឹងធ្វើ ។

បទថា នេសោ មមំ សេចក្ដីថា គប្បីដឹងច្បាស់បុគ្គលបែបនោះថានុ៎ះមិនមែនមិត្តរបស់យើង ។ បទថា បាមោជ្ជករណំ ឋានំ បានដល់ ទាន សីល ភាវនា និងសេចក្ដីជាមិត្តនឹងបណ្ឌិតអ្នកជា

កល្យាណមិត្ត ។ តែក្នុងទីនេះ លោកពោលសំដៅយកចំពោះសេចក្ដីជាមិត្តដែលមានប្រការដូចពោលហើយ ។ ពិតមែនសេចក្ដីជាមិត្តនឹងបណ្ឌិតអ្នកជាកល្យាណមិត្ត ។ រមែងនាំមកនូវបាមោជ្ជទាំងនាំមកនូវសេចក្ដីសរសើរ លោកហៅថា សេចក្ដីសុខដូច្នេះក៏មានព្រោះជាហេតុនៃសុខផ្លូវកាយនិងផ្លូវចិត្ត ក្នុងលោកនេះនិងលោកខាងមុខ ។ ព្រោះដូច្នោះ កុលបុត្រអ្នកឃើញផលនិងអានិសង្សនេះឈ្មោះថា អ្នកមានផលានិសង្ស កាលនាំធុរៈនាទីរបស់កូនអ្នកប្រុសទាំង ៤ យ៉ាងគឺ ទាន សីល ភាវនានិងមិត្តភាពដែលកូន អ្នកប្រុសទាំងឡាយនឹងគប្បីនាំ រមែងញ៉ាំងហេតុគ្រឿងធ្វើសេចក្ដីបា-មោជ្ជពោលមិត្តភាពនេះ និង សុខដែលជាហេតុនាំមកនូវសេចក្ដីសរសើរឱ្យចុះគឺឱ្យចម្រើន លោកសម្ដែងថា មិនទម្លាយមិត្តភាពឱ្យបែកចាកពីបណ្ឌិតទាំងឡាយ ។ បទថា បវិវេក្ករសំ បានដល់រសនៃកាយវិវេក ចិត្តវិវេក និងឧបធិវិវេក គឺរសនៃសេចក្ដីសោមនស្សដែលអាស្រ័យវិវេកទាំងនោះកើតឡើង ។ បទថា ឧបសមស្ស ច បានដល់ សោមនស្សដែលបានហើយ ព្រោះសេចក្ដីស្ងប់រម្ងាប់កិលេស ។ បទថា និទ្ទរោ ហោតិ និប្បាបោ សេចក្ដីថាឈ្មោះថា

ជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ព្រោះមិនមានសេចក្ដីខ្វល់ខ្វាយដោយអំណាចរបស់កិលេសទាំងពួង ឈ្មោះថាជាអ្នកមិនមានបាបព្រោះមិនមានកិលេស ។

បទថា ធម្មបីតិរសំ សេចក្ដីថាផឹករសពោលគឺធម្មបីតិ បានដល់បីតិដែលកើតពីវិមុត្តិ ។

ព្រះពោធិសត្វសូត្រនេត់ ការស្អប់ខ្ពើមនឹងបាបមិត្តទើបកាន់យកកំពូលនៃទេសនា ដោយឱ្យសម្រេចព្រះអមតមហានិព្វានដោយរសនៃវិវេកដោយប្រការដូច្នេះ ។ ព្រះសាស្ដាគ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្ដែងហើយ ទើបប្រជុំជាតកថា សេដ្ឋីអ្នកបច្ចន្តគ្រាមក្នុងគ្រានោះបានជាសេដ្ឋីអ្នកបច្ចន្តគ្រាមនេះឯង ចំណែកពារាណសីសេដ្ឋីក្នុងគ្រានោះបានជាយើងតថាគត ដូច្នេះឯង ។

## ទុក្ខ "ធម៌ជាគ្រឿងចម្រើន ៤ យ៉ាង"

ការរីកលូតលាស់ ជាតម្រូវការរបស់មនុស្សគ្រប់គ្នា ។ ការរីកចម្រើននោះ ចាំបាច់ត្រូវអាស្រ័យហេតុដូចខាងក្រោម ៖

**១-សប្បុរិសូបសំសេវ** សេពគប់សប្បុរស គឺលោកប្រព្រឹត្ត

ល្អដោយកាយវាចាចិត្ត, មានសទ្ធា មានសីល មានសេចក្ដីអៀន ខ្មាសបាប ខ្លាចបាប ជាអ្នកបានឮ បានស្ដាប់ច្រើន ជាអ្នកមាន ព្យាយាម ជាអ្នកមានសេចក្ដីខ្ជាប់ខ្ជួន ជាអ្នកមានបញ្ញាមិនគិតដើម្បី បៀតបៀនខ្លួនឯង និងអ្នកដទៃមានសេចក្ដីយល់ឃើញត្រូវថា ធ្វើ ល្អ បានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ។

**២- សទ្ធម្មស្សវនៈ** ស្ដាប់ពាក្យប្រដៅរបស់លោកដោយ គោរព ដោយយកចិត្តទុកដាក់ជាទីបំផុត ដើម្បីឱ្យក្លាយទៅជាមនុស្ស ម្នាក់ដែលល្អ មានប្រយោជន៍ មានទីពឹងសម្រាប់ខ្លួនទៅអនាគត ។

**៣- យោនិសោមនសិការៈ** ត្រិះរិះឱ្យស្គាល់របស់ល្អ ឬ អាក្រក់ដោយឧបាយដែលត្រូវតាមសេចក្ដីពិតរបស់វត្ថុ ឬរឿងរ៉ាវ នៅក្នុងលោកដោយល្អ មិនធ្វេសប្រហែស ។

**៤- ធម្មានុធម្មប្បដិបត្តិ** ប្រតិបត្តិសមគួរដល់ធម៌ដែលបាន ត្រិះរិះឃើញហើយ ដើម្បីដុសខាត់ចិត្តឱ្យប្រព្រឹត្តទៅនៅក្នុងកុសល ធម៌ សេចក្ដីល្អ របូតអស់ទៅនៃអាសវៈកិលេសទាំងឡាយ បាន ដល់អមតៈពោលគឺព្រះនិព្វាន ដែលជាបរមសុខ តាមព្រះអរិយ បុគ្គលទាំងឡាយ ។

៦. អ្នកត្រូវការព្យាយាមស្វែងរកសេចក្ដីចម្រើន ដោយខ្លួនឯងផ្ទាល់ ត្រូវគោរពប្រតិបត្តិតាមគោលធម៌ខាងលើនេះចុះ ទុំះសេចក្ដីចម្រើននឹងកើតមានជាមិនខាន ។

## បឋមផលសូត្រ ទុតិយផលសូត្រ តតិយផលសូត្រ និង ចតុផលសូត្រ

នៅក្នុងបិដកលេខ ៣៩, ទំព័រ ២២២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី [*បុគ្គលដែលបានចម្រើនធម៌ ៤ ប្រការដើម្បីមែងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល, សកទាគាមិផល, អនាគាមិផល, អរហត្តផល*] ដោយមានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយធម៌ ៤ ប្រការនេះ ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ **ធម៌ ៤ ប្រការតើដូចម្ដេចខ្លះ ?**

១-សប្បុរិសសំសេវោ គឺការសេពគប់សប្បុរស ។

២-សទ្ធម្មស្សវនំ ការស្ដាប់ធម៌របស់សប្បុរស ។

៣-យោនិសោមនសិការោ ការធ្វើទុកក្នុងចិត្តដោយឧបាយ

៤–ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង៤ នេះឯង ដែលបុគ្គលបាន ចម្រើនហើយ ធ្វើឱ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

➥. ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបាន ចម្រើនហើយ ធ្វើឱ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល[១] ។

➥. តែងប្រព្រឹត្តទៅ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល[២] ។

➥. តែងប្រព្រឹត្តទៅ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល[៣] ។

➥. តែងប្រព្រឹត្តទៅ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល[៤] ។

---

១. បឋមផលសូត្រ, ១. ទុតិយផលសូត្រ, ១. តតិយសូត្រ, ១. ចតុត្ថផលសូត្រ ។

➢. តែងប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា ។
➢. តែងប្រព្រឹត្តទៅដើម្បីចម្រើនប្រាជ្ញា ។
➢. តែងប្រព្រឹត្តទៅដើម្បីធ្វើប្រាជ្ញាឱ្យធំទូលាយ ។

## មហាបញ្ញាវគ្គទី ៧

នៅក្នុងបិដលលេខ ៣៩, ទំព័រ ២២៤ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្ដែងនូវមហាបញ្ញាសូត្រ, បុថុបញ្ញាសូត្រ, វិបុលបញ្ញាសូត្រ, គម្ពីរបញ្ញាសូត្រ, អប្បមត្តបញ្ញាសូត្រ, ភូរិបញ្ញាសូត្រ, ពាហុលបញ្ញាសូត្រ, សីឃបញ្ញាសូត្រ លហុបញ្ញាសូត្រ, ហាសបញ្ញាសូត្រ, ជវនបញ្ញាសូត្រ, តិក្ខបញ្ញាសូត្រ, និព្វេធិកបញ្ញាសូត្រ, ដោយមានសេចក្ដីសរុបថា ៖

**✯. ធម៌ ៤ ៖**

➢. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាច្រើន ។
➢. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ក្រាស់ ។
➢. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ធំទូលាយ ។
➢. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ជ្រៅ ។
➢. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាប្រមាណមិនបាន ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដូចជាផែនដី ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ច្រើន ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាឆាប់ ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញារហ័ស ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏រីករាយ ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាជាទីស្ទុះទៅ ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ក្លៀវក្លា ។

➥. តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏មោះមុត ។

**✲. ធម៌ ៤ ដូចម្ដេចខ្លះ ?**

១-សប្បុរិសសំសេវោ គឺការសេពគប់សប្បុរស ។

២-សទ្ធម្មស្សវនំ ការស្ដាប់ធម៌របស់សប្បុរស ។

៣-យោនិសោមនសិការោ ការធ្វើទុកក្នុងចិត្តដោយឧបាយ

៤-ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង៤ នេះឯង ដែលបុគ្គលបាន ចម្រើនហើយ ធ្វើឱ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីប្រាជ្ញាដ៏មោះមុត ។

## សេចក្តីសុខរបស់បណ្ឌិត

៦. **ម្នាលភិក្ខុទាំងឡាយ** ជនជាបណ្ឌិតនោះ បើអំណើះកាលយូរអង្វែងទៅម្តង ៗ ក៏មកកាន់អត្តភាពជាមនុស្សក្នុងកាលជាខាងក្រោយតែងកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាលខ្លះ ត្រកូលព្រាហ្មណ៍មហាសាលខ្លះ ត្រកូលគហបតីមហាសាលខ្លះ ជាត្រកូលស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានប្រាក់ មាសច្រើន មានគ្រឿងឧបករណ៍ច្រើន មានធញ្ញជាតជាទ្រព្យច្រើន ។

៦. **មួយទៀត** ជនជាបណ្ឌិតនោះមានរូបល្អ គួរពិតពិលរមិលមើលគួរជ្រះថ្លា ប្រកបដោយសម្បុរល្អដ៏ក្រៃលែងជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីនៅអាស្រ័យនិងគ្រឿងប្រទីប ។

៦. **ជនជាបណ្ឌិតនោះ** តែងប្រព្រឹត្តសុចរិតដោយកាយប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ។ លុះជនជាបណ្ឌិតនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិត ដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ហើយដល់បែកធ្លាយរាងកាយ

ស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

ម្នាលភិក្ខុទាំងឡាយ ដូចអ្នកលេងល្បែងភ្នាល់បាននូវគំនរទ្រព្យសម្បត្តិច្រើន ដោយការឈ្នះជាជប្បុងប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយត្រង់ហេតុដែលអ្នកលេងល្បែងភ្នាល់នោះ បាននូវគំនរទ្រព្យសម្បត្តិច្រើន ដោយជប្បុងប៉ុណ្ណោះនោះ ឈ្មោះថា ជាការឈ្នះតែបន្តិចបន្តួចទេ ។ ចំណែកខាងជនជាបណ្ឌិតនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោនេះឯង ទើបឈ្មោះថា ការឈ្នះធំជាងនោះទៅទៀត ។

**ម្នាលភិក្ខុទាំងឡាយ** នេះឈ្មោះថា បណ្ឌិតភូមិ ដ៏បរិបូណ៌គ្រប់គ្រាន់ ។

## គុណសម្បត្តិរបស់បណ្ឌិត

បណ្ឌិតមានគុណមានចំណុចល្អ ៗច្រើនប្រការណាស់ តែបើយើងសរុបឱ្យខ្លី ៗមកមាន៣ ប្រការ គឺ ជាបុគ្គលមានការប្រព្រឹត្តល្អទៅតាមផ្លូវកាយដូចមិនសម្លាប់ជីវិតសត្វដទៃ មិនលួចទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ ។ មិននិយាយ

ពាក្យកុហកបោកប្រាស់អ្នកដទៃ, មិននិយាយពាក្យអាក្រក់, មិននិយាយពាក្យញុះញង់បុគ្គលដទៃឱ្យបែកបាក់គ្នា,មិននិយាយពាក្យរោយរាយឥតប្រយោជន៍ ។ មិនសម្លឹងរំពៃទ្រព្យរបស់អ្នកដទៃ, មិនមានគំនុំគំគួនអ្នកដទៃ,និងមិនមានសេចក្ដីយល់ខុសបាកកម្មផល ។ មិនតែប៉ុណ្ណោះបណ្ឌិតគឺជាបុគ្គលចេះតម្កល់ខ្លួនទុកនៅក្នុងសេចក្ដីល្អ ដូចជាមានព្រះសូត្រនិងរឿងខាងក្រោម ។

## មហានាមសូត្រ

នៅក្នុងបិដកលេខ ៣៩, ទំព័រ ១៨៧ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងអំពី [**សម្បត្តិរបស់ឧបាសក**] ដោយប្រារព្ធចំពោះព្រះមហានាម មានសេចក្ដីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុក្នុងដែនសក្កៈ ។ គ្រានោះឯងមហានាមសក្កៈចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះមហា-នាមសក្កៈគង់ក្នុងទីសមគួរហើយ ទើបទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាឧបាសក តើដោយ

ហេតុដូចម្តេច ។ ម្នាលមហានាម បុគ្គលជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះហេតុឯណា ។ ម្នាលមហានាម បុគ្គលដែលឈ្មោះថា **ឧបាសក** ព្រោះហេតុនេះឯង ។

( មហានាម ). បពិត្រព្រះអង្គដ៏ចម្រើន **ចុះឧបាសក បរិបូណ៌ដោយសីល** តើដោយហេតុដូចម្តេច ។

( ព្រះអង្គ ). ម្នាលមហានាម ឧបាសកជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការផឹកទឹកស្រវឹង គឺសុរានឹងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ដោយហេតុឯណា ។ ម្នាលមហានាម ឧបាសកបរិបូណ៌ដោយសីល ដោយហេតុយ៉ាងនេះឯង ។

ម. បពិត្រព្រះអង្គដ៏ចម្រើន **ចុះឧបាសក បរិបូណ៌ដោយសទ្ធា** តើដោយហេតុដូចម្តេច ។

៣. ម្នាលមហានាម ឧបាសកក្នុងសាសនានេះជាអ្នកមានសទ្ធា ជឿនូវសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគនោះ ( ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានឹង

ចរណៈ ទ្រង់មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដូចជានាយសារថី ទ្រង់ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងអរិយសច្ចៈ៤ទ្រង់ខ្ជាក់ចោលនូវត្រៃភពលែងវិលត្រឡប់មកកើតទៀត) ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។ ម្នាលមហានាម ឧបាសកបរិបូណ៌ដោយសទ្ធាដោយហេតុយ៉ាងនេះឯង ។

ម. បពិត្រព្រះអង្គដ៏ចម្រើន **ចុះឧបាសក បរិបូណ៌ដោយចាគៈ** តើដោយហេតុដូចម្តេច ។

ព. ម្នាលមហានាម ឧបាសកក្នុងសាសនានេះ ជាអ្នកមានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ តែងមានចាគៈ មានបាតដៃលាងចាំឱ្យ ត្រេកអរក្នុងការលះ គួរគេសូមបាន ត្រេកអរក្នុងការឱ្យនឹងការចែករំលែក ។ ម្នាលមហានាម ឧបាសកបរិបូណ៌ដោយចាគៈដោយហេតុយ៉ាងនេះឯង ។

ម. បពិត្រព្រះអង្គដ៏ចម្រើន **ចុះឧបាសក បរិបូណ៌ដោយ**

**ប្រាជ្ញា** តើដោយហេតុដូចម្តេច ។

**៣.** ម្នាលមហានាម ឧបាសកក្នុងសាសនានេះ មានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវសេចក្តីចំរើន នឹងវិនាស ជាប្រាជ្ញាប្រសើរមោះមុតប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។ ម្នាលមហានាម ឧបាសកបរិបូណ៌ដោយប្រាជ្ញា ដោយហេតុយ៉ាងនេះឯង ។

## **ហានិសូត្រ**

នៅក្នុងបិដកលេខ៤៧, ទំព័រ៤៦ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពី [**ធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យនិងមិនសាបសូន្យរបស់ឧបាសក៧** ប្រការ] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ឧបាសក ។ **៧ យ៉ាង** តើអ្វីខ្លះ ។

**១–ភិក្ខុទស្សនំ ហាបេតិ** ឧបាសកញុំាងការឃើញនូវភិក្ខុឱ្យសាបសូន្យ ។

២-សទ្ធម្មស្សវនំ បមជ្ជតិ (ឧបាសក)ប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម ។

៣-អធិសីលេ ន សិក្ខតិ (ឧបាសក)មិនសិក្សាក្នុងអធិសីល ។

៤-អប្បសាទពហុលោ ហោតិ ភិក្ខុស្សុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច (ឧបាសក)ជាអ្នកមិនមានសេចក្តីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្តាល ។

៥-ឧបារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី (ឧបាសក) ជាអ្នកមានចិត្តរិះគន់ ស្វែងរកទោសក្នុងការស្តាប់ធម៌ ។

៦-ឥតោ ពហិទ្ធា ទក្ខិណេយ្យំគវេសតិ (ឧបាសក) ជាអ្នកស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ។

៧-តត្ថ ច បុព្វការំ ករោតិ (ឧបាសក)ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានេះ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសាបសូន្យដល់ឧបាសក ។

៦. ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ឧបាសក ។

១-ភិក្ខុទស្សនំ នហាបេតិ ឧបាសកមិនញុំាងការឃើញនូវភិក្ខុឱ្យសាបសូន្យ ។

២- សទ្ធម្មស្សវនំ នប្បមជ្ជតិ ( ឧបាសក )មិនប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម ។

៣-អធិសីលេសិក្ខតិ( ឧបាសក )សិក្សាក្នុងអធិសីល ។

៤- បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច ( ឧបាសក )ជាអ្នកមានសេចក្តីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្តាល ។

៥- អនុបារម្ភចិត្តោ ធម្មំ សុណាតិ នរន្ធគវេសី ឧបាសកជាអ្នកមានចិត្តមិនរិះគន់ស្វែងរកទោសក្នុងការស្តាប់ធម៌ ។

៦-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ( ឧបាសក ) ជាអ្នកមិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ។

៧-ឥធ ច បុព្វការំ ករោតិ ( ឧបាសក )ធ្វើបុព្វការៈ

ក្នុងទក្ខិណេយ្យបុគ្គលខាងក្នុងសាសនានេះ ។

៦. ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ឧបាសក ។

ឧបាសកណាញុំាងការឃើញនូវពួកភិក្ខុ ដែលខូនចំរើនហើយឱ្យសាបសូន្យ ១ ប្រហែសនឹងការស្តាប់នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្តីមិនជ្រះថ្លាក្នុងពួកភិក្ខុចម្រើនឡើងដោយក្រៃលែង ១ មានចិត្តរិះគន់ប្រាថ្នាស្តាប់ព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលដទៃខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលនោះ ១ ។

៦. ឧបាសកកាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ រមែងសាបសូន្យចាកព្រះសទ្ធម្ម ។

ឧបាសកណា មិនញុំាងការឃើញនូវពួកភិក្ខុ ដែលខូនចំរើនហើយ ឱ្យសាបសូន្យ ១ មិនប្រហែសនឹងការស្តាប់នូវអរិយធម៌ទាំងឡាយ ១ សិក្សាក្នុងអធិសីល ១ មានសេចក្តីជ្រះថ្លាក្នុងពួកភិក្ខុចម្រើន ឡើងដោយក្រៃលែង ១ មិនមានចិត្តរិះគន់ប្រាថ្នាស្តាប់

ព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្នុងសាសនានេះ ១ ឧបាសកតែងធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ។

២. ឧបាសកកាលសេពនូវបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

ជនដែលមាននាមបញ្ញត្តិថា "**ឧបាសក**"នោះ ដោយហេតុដែលបានចូលទៅជិត ដល់នូវព្រះរតនត្រ័យជាទីពឹងទីរឭក ដូចពុទ្ធភាសិត ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងចំពោះមហា-នាមសក្យរាជថា "ម្នាលមហានាម គ្រហស្ថឯណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា ឧបាសក បើស្ត្រីហៅថា "**ឧបាសិកា**" ។

មួយ៉ាងទៀត មានបាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ជនឯណា ចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះ ឈ្មោះថា **ឧបាសក** ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ច ដោយរូបកាយនោះទេ គឺលោកសង្គ្រោះយក នាមកាយជាប្រមាណ, សូម្បីជននោះ ស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅក្នុងគុណព្រះរតនត្រ័យជានិច្ច, ចិត្តនោះឱនទៅតោងយកគុណព្រះរតនត្រ័យ ជាទីពឹងទីរឭកជានិច្ចហើយ ជននោះឈ្មោះថា បានចូលទៅអង្គុយជិតព្រះរតនត្រ័យជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា "ឧបាសក, ឧបាសិកា" ឡើយ ។

## ចណ្ឌាលសូត្រ

នៅក្នុងបិដកលេខ ៤៥, ទំព័រ ១៥៥ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី [**ធម៌សម្រាប់ឧបាសកល្អ និងឧបាសកអាក្រក់**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង

ឈ្មោះថា ចណ្ឌាឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។ **ធម៌ ៥ យ៉ាង** តើដូចម្ដេច ។

១- អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ

២- ទុស្សីលោ ហោតិ ឧបាសកទ្រុស្តសីល ។

៣- កោតុហលមង្គលិកោ ហោតិ ឧបាសកប្រកប ដោយមង្គលភ្ញាក់ផ្អើល ។

៤- មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថា កម្ម ជាកុសល និង អកុសលឱ្យផលឡើយ ។

៥- ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើនូវទានដល់ទក្ខិណេយ្យបុគ្គល ខាងក្រៅព្រះពុទ្ធសាសនានេះ ។

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង នេះឯង ឈ្មោះថា ចណ្ឌាឧបាសកផង ( គឺឧបាសកដូចជាមនុស្ស

ចណ្ឌាល ) ឈ្មោះថា មលឧបាសកផង ( គឺឧបាសកមានធម៌ជាមន្ទិលសៅហ្មង ) ឈ្មោះថា បដិកិដ្ឋឧបាសកផង ( គឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀល ) ។

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។

១- សទ្ធោ ហោតិ ឧបាសកមានសេចក្ដីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

២- សីលវា ហោតិ ឧបាសកមានសីល ។

៣- ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤- កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថាកម្មជាកុសល និងអកុសលឱ្យផល មិនប្រកាន់ជឿថា មង្គល មានឫក្សពារវេលាជាដើមឱ្យផលឡើយ ។

៥- ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច

បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទាន តែក្នុងទក្ខិណេយ្យបុគ្គលក្នុងព្រះពុទ្ធសាសនានេះ ។

ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង (គឺឧបាសកដូចជារតនៈវត្ថុមានកែវជាដើម) ឈ្មោះថា បទុមឧបាសកផង (គឺឧបាសកដូចជាផ្កាឈូកមានពណ៌ក្រហម) ឈ្មោះថា បុណ្ឌរីក ឧបាសកផង (គឺបាសកដូចជាផ្កាឈូកមានពណ៌ស) ។

## គុណនៃឧបាសក

ធម៌សំរាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើតឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា **គុណ** ។ គុណនេះជារបស់ឧបាសក ឧបាសិកា ហៅថា “**ឧបាសកគុណ**” មាន ១០ យ៉ាងគឺ ៖

**១.**សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ ឧបាសកអ្នករួមសេចក្តីសុខទុក្ខមួយអន្លើដោយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្តីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្តីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

២-កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ ឧបាសកមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ។

៣- ធម្មោ អធិបតេយ្យោ ហោតិ ឧបាសកមានធម៌ជាអធិបតី គឺថាបើប្រព្រឹត្តធ្វើអ្វី ៗ រមែងកាន់យកធម៌ជាធំ ជាទីតាំងជាទីអាងមាំមិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤-យថាថាមេន សំវិភាគរតោ វ ហោតិ ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួនគឺធ្វើទានតាមសមគួរដល់ទ្រព្យតិច ឬច្រើន បើមានតិច ក៏ធ្វើតិចបើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្ដានចិត្តឡើយ ។

៥-ជិនសាសនំ ជានិតុញ្ច វាយមតិ ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈគឺពាក្យប្រៀនប្រដៅពាក្យបណ្ដាំនៃព្រះជិនស្រី ។

៦-សម្មាទិដ្ឋិកោ វ ហោតិឧបាសកជាសម្មាទិដ្ឋិគឺ មានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

**៧- អបគតោ កោតុហលមង្គលិកោ** វ ហោតិ ឧបាសក ប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារ វេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល ។

**៨- ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសក បើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏មិនលះបង់ព្រះរតនត្រ័យហើយត្រឡប់ទៅកាន់យកមនុស្សដទៃ ជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួន ថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

**៩- សមគ្គារាមោ** វ ហោតិ ឧបាសកមានសេចក្ដីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

**១០- សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនិងធ្វើចិត្តឧបាសក ឧបាសិកា អ្នកប្រព្រឹត្តឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

# រៀបចំដំណើរជីវិត

មនុស្សយើងនេះ ដែលនឹងអាចមានូវសេចក្ដីសុខយ៉ាងពិតប្រាកដទៅបាននោះ គឺ ត្រូវមានដំណើរជីវិតយ៉ាងត្រឹមត្រូវពោល គឺត្រូវបដិបត្តិឱ្យបានត្រឹមត្រូវចំពោះជីវិតរបស់ខ្លួនទាំងផ្នែកសង្គមមនុស្សសត្វទាំងផ្នែកវត្ថុ ទាំងផ្នែកធម្មជាតិ ។

ដំណើរជីវិតរបស់មនុស្សយើង គឺ ការងារផ្សេង ៗដែលសម្ដែងចេញតាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ និងដែលមិនបានសម្ដែងចេញមកខាងក្រៅ តែធ្វើការខាងក្នុងដែលជាការរបស់ចិត្តខ្លះនិយាយឱ្យងាយមក **គឺការធ្វើការនិយាយនិងការគិត ។** បុគ្គលដែលធ្វើកម្មទាំង ៣ យ៉ាង នេះបានត្រឹមត្រូវល្អ រមែងមានដំណើរជីវិតប្រព្រឹត្តទៅបានយ៉ាងប្រពៃ ។ **ចេះធ្វើ ចេះនិយាយ ចេះគិត ជីវិតរុងរឿង ។**

ដំណើរជីវិតមួយផ្នែកទៀត គឺការទទួលដឹងអារម្មណ៍និងការសោយរសនៃអារម្មណ៍តាមទ្វារទាំង ៦ ។ បើការទទួលនូវអារម្មណ៍ប្រព្រឹត្តទៅដោយការស្រឡាញ់ ឬស្អប់ នេះជាប្រភពនៃបញ្ហា តែបើទទួលដោយបញ្ញាដឹងតាមសេចក្ដីពិត ឬ ដឹងទៅតាមហេតុផល

ដំណើរជីវិតរមែងរួចផុតពីបញ្ហាប្រព្រឹត្ត ទៅដោយសេចក្ដីសុខស្ងប់ ។

ផ្នែកមួយផ្សេងទៀតនៃដំណើរជីវិត គឺការចូលទៅទាក់ទងជាមួយរបស់ទាំងឡាយ ដើម្បីកាន់យកនូវប្រយោជន៍អំពីរបស់នោះ ។ **ការសេពគប់ ការបរិភោគ ការមើល ការអាន និងការស្ដាប់ជាដើម** នេះគឺជាដំណើរជីវិត ដែលមានទំនាក់ទំនងជាមួយសង្គមមនុស្សសត្វនិងវត្ថុ ។ ការគប់រកក្ដី ការបរិភោគក្ដី ការប្រើប្រាស់ក្ដី បើមិនអាស្រ័យការឆ្លាតទេ វាអាចធ្វើឱ្យជីវិតលិចលង់ទៅបាន តែបើឆ្លាតដំណើរជីវិតនិងដល់គោលដៅ ។ ទឹកអាចធ្វើឱ្យទូកដល់គោលដៅ តែក៏អាចឱ្យទូកលិចបានដែរ ។

**សមុទ្រតែងមានរលក ជីវិតតែងមានបញ្ហា តែបញ្ហាអាចដោះស្រាយនូវបញ្ហាបាន** ម្យ៉ាងទៀត អ្នកមានបញ្ញា រមែងរៀបចំដំណើរជីវិតឱ្យគេចផុតពីបញ្ហា ហើយបានជួបប្រសព្វនូវផលសម្រេចក្នុងដំណើរជីវិតរបស់ខ្លួន រស់នៅដោយប្រាសចាកទុក្ខកង្វល់ ។

ដំណើរជីវិតដ៏ត្រឹមត្រូវ នឹង បានសម្រេចនូវផលល្អនោះ

រមែងមានការប្រព្រឹត្តទៅដោយច្រើនផ្នែក ពោលដោយសរុបគឺ

**១- ក្នុងផ្នែកនៃការធ្វើកម្ម** បានដល់ ការពូកែគិត ការពូកែនិយាយ និងការពូកែធ្វើ ទាំងដែលជាសុចរិតទៀតផង ។

**២- ក្នុងផ្នែកនៃការទទួលដឹង** បានដល់ ការពូកែមើល ការពូកែស្តាប់ជាដើម ។

**៣- ក្នុងផ្នែកទំនាក់ទំនងដ៏ប្រសើរជាមួយអ្វីៗ ដែលនៅជុំវិញខ្លួន** បានដល់ ការពូកែបរិភោគ ការពូកែប្រើប្រាស់ និងការពូកែសេពគប់ ឬ គប់រក ។

ពាក្យថា **ការពូកែ**ក្នុងទីនេះគឺសំដៅដល់ភាពឆ្លាត ឈ្លាសប្រព្រឹត្តទៅជាកុសល និងច្រើនដោយសតិសម្បជញ្ញៈ ។

**១- មានបញ្ញាសម្រាប់ដោះស្រាយនូវបញ្ហា** និងចេះរៀបចំដំណើរជីវិតបញ្ចៀសពីបញ្ហា ។

មនុស្សឆ្លាត គឺ មនុស្សដែលចេះជួយខ្លួនឯងឱ្យរួចពីបាបកម្ម ។

ការបដិបត្តិត្រឹមត្រូវនៅក្នុងផ្នែកផ្សេង ៗ នៃដំណើរជីវិតធ្វើឱ្យជីវិតមានដំណើររៀបរយល្អនិងមានរស្មីថ្លា ។ សេចក្តីល្អជា

រស្មីនៃជីវិត ។

បណ្ដាការបដិបត្តិត្រឹមត្រូវនៅក្នុងផ្នែកផ្សេង ៗ នៃជីវិតនេះ អាចនិយាយសរុបបួមបានថា ការពូកែគិត ។ ការពូកែគិតនេះជាសម្បត្តិមួយដ៏សំខាន់ក្រៃលែងក្នុងដំណើរ ។

**ការពូកែគិត** គ្រប់គ្រងនូវការបដិបត្តិឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវគ្រប់ផ្នែកទាំងអស់ ។

ពាក្យថា **ការពូកែគិត** បានដល់ **គំនិតល្អ ឆ្លាតនិងត្រឹមត្រូវ** ម្ល៉ោះហើយអ្វី ៗ ដែលប្រព្រឹត្តទៅតាមគំនិតដូច្នេះ ក៏រមែងរៀបរយរាបសា ល្អត្រឹមត្រូវទៅផងដែរ ។

ការពូកែគិត ឬការចេះគិត មានការប្រកបដោយវិធីគិតផ្សេង ៗច្រើនបែប ច្រើនយ៉ាង ។ ការហ្វឹកហាត់អប់រំចម្រើននូវគំនិតឱ្យពូកែគិត គឺជាការហ្វឹកហាត់កសាងខ្លួនឯង ។

***ការពូកែគិត គឺជាយោនិសោមនសិការ*** *ប្រែថា* ***ចេះធ្វើទុកក្នុងចិត្តដោយល្អត្រូវទៅតាមហេតុផល ។***

(ជំនួយសតិ ភាគ ៩/១)

# មិត្តមានសន្ដានចិត្តល្អ

*នៅក្នុងបិដកលេខ ១៩, ទំព័រ ៨ ព្រះអង្គទ្រង់ត្រាស់នូវ* **សិង្គាលកសូត្រ** *(កថាពោលអំពីមិត្ត) ដោយប្រារព្ធទៅលើកូនគហបតីឈ្មោះសិង្គាលកៈ[១]ដែលតែងតែក្រោកឡើងអំពីព្រឹកមានសំពត់ស្លៀកជណ្ដប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះប្រណម្យអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើតខាងត្បូង ខាងលិច ខាងជើង ខាងក្រោមនិងទិសខាងលើ ។ លំដាប់នោះឯងព្រះមានព្រះភាគ ស្ដេចទ្រង់ស្បង់និងបាត្រចីវរក្នុងបុព្វណ្ហសម័យហើយស្ដេចចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគទ្រង់ទតឃើញសិង្គាលកគហបតិបុត្ត ក្រោកឡើងអំពីព្រឹកមានសំពត់ស្លៀក ជណ្ដប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះកំពុងផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរសិង្គាលក គហបតិបុត្តដូច្នេះ*

---

*[១] ហៅថាសិគាលកៈ ក៏មាន ដូចគ្នានិងពាក្យថា មហឹសៈ និង មហិសៈ សិរីសបៈ និងសិរិសបៈជាដើម ឃើញថា ហៅបានដូចគ្នាទាំងពីរយ៉ាង ។*

ថា" នែគហបតិបុត្ត ហេតុអ្វីទើបអ្នកក្រោកអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើតជាដើម ។ សិង្គាលកគហបតិបុត្ត ក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចំរើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណភាព បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា "ហៃបា អ្នកត្រូវតែថ្វាយបង្គំទិសទាំងឡាយ" បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ ធ្វើសក្ការៈ គោរពរាប់អាន បូជានូវពាក្យរបស់បិតាបានជាក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយដ៏ច្រើន គឺទិសខាងកើត ។ល ។ ទិសខាងលើ" ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "នែគហបតិបុត្ត ក្នុងវិន័យរបស់ព្រះអរិយៈគេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាង ដូច្នេះទេ" ។ សិង្គាលកគហបតិបុត្តក្រាបបង្គំទូលសួរថា "បពិត្រព្រះអង្គ ដ៏ចំរើនចំណែកក្នុងអរិយវិន័យ គេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន បើក្នុងវិន័យរបស់ព្រះអរិយៈ គេគប្បីថ្វាយបង្គំចំពោះទិសទាំង ៦ យ៉ាងណា សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គ ដូច្នោះចុះ" ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "នែគហបតិបុត្ត បើដូច្នោះ អ្នកចូរស្តាប់ចុះ ចូរកំណត់ទុកក្នុងចិត្តឱ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់" ។ សិង្គាលកគហបតិបុត្ត ក៏ទទួលស្តាប់ព្រះពុទ្ធដីកា ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា "ម្នាលគហបតិបុត្ត អរិយសាវកលះបង់នូវកម្មកិលេស (អំពើដ៏សៅហ្មង) ៤ ប្រការផង មិនធ្វើនូវបាបកម្ម (អំពើអាក្រក់) ព្រោះហេតុ ៤ យ៉ាងផង មិនសេពនូវអបាយមុខ (គឺប្រធាននៃសេចក្តីវិនាស) នៃភោគៈ៦ យ៉ាងផង អរិយសាវកនោះ លោកវៀរចាកបាបធម៌ទាំង ១៤ យ៉ាងនេះ ឈ្មោះថា ជាអ្នកបិទបាំងទិសទាំង ៦ ប្រតិបត្តិដើម្បីជំនះក្នុងលោកទាំងពីរ គឺលោកនេះក៏អរិយសាវកនោះបានប្រារព្ធ គឺថាបានពេញចិត្តហើយ លោកខាងមុខក៏ពេញចិត្តទៀត ។ លុះអរិយសាវកនោះទម្លាយរាងកាយទៅ រមែងកើតក្នុងមនុស្សសុគតិ សួគ៌ ទេវលោក, (រហូតដល់ព្រះអង្គបានសម្តែងអំពីមិត្ត ដែលមានសន្តានចិត្តល្អ គួរសេពគប់ ដែលមានសេចក្តីដូចតទៅ) ៖

## លក្ខណៈរបស់មិត្តមានសន្តានល្អ ៤ យ៉ាង

ចត្តារោមេ គហបតិបុត្ត មិត្តា សុហទា វេទិតព្វា ឧបការកោ មិត្តោ សុហទោ វេទិតព្វោ សមានសុខទុក្ខោ មិត្តោសុហទោវេទិតព្វោអត្ថក្ខាយី មិត្តោសុហទោវេទិតព្វោ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ ។

*ម្នាលគហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថាជា មិត្តមានសន្តានល្អ គឺ ៖*

១- ឧបការកោ មិត្តោ សុហទោ វេទិតព្វោ *មិត្តមានឧបការៈអ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ។*

២- សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ *មិត្តរួមសុខទុក្ខអ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ។*

៣- អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ *មិត្តប្រាប់ប្រយោជន៍អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ។*

៤- អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ *មិត្តមានសេចក្តីឈឺឆ្អាលអ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ។*

## មិត្តមានឧបការៈ ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ ឧបការកោ មិត្តោ សុហទោ វេទិតព្វោ *ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ៖*

១- បមត្តំ រក្ខតិ *រក្សាមិត្តដែលធ្វេសប្រហែស ។ អដ្ឋកថាបទថា* បមត្តំ រក្ខតិ *( រក្សាមិត្តដែលធ្វេសប្រហែស ) មានសេចក្តីថា មិត្តមានឧបការៈ កាលបើឃើញមិត្តផឹកទឹកស្រវឹង ហើយដេកត្រង់កណ្តាលផ្ទះ ត្រង់ទីជិតទ្វារ ឬដេកនៅតាមផ្លូវក៏គិតថា បើមិត្តរបស់អញដេកលក់យ៉ាងនេះ អាចថានឹងមានអ្នកណាម្នាក់មកលួចយកសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្តប់យកទៅបាន ដូច្នេះហើយមកអង្គុយជិតមិត្តនោះ ពេលមិត្តក្រោកឡើង ក៏នាំយកទៅ ។*

២- បមត្តស្ស សាបតេយ្យំ រក្ខតិ *រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ។ អដ្ឋកថាបទថា* បមត្តស្ស សាបតេយ្យំ

*( រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស )* មានសេចក្តីថា មិត្តមានឧបការៈគិតថា សម្ភារៈរបស់អញបានចេញទៅខាងក្រៅ ឬផឹកទឹកស្រវឹង រីឯផ្ទះមិនមានអ្នកនៅចាំ អាចជានឹងមានអ្នកដទៃចូលមកលួចរបស់ណានីមួយយកទៅ ដូច្នេះក៏ចូលទៅកាន់ផ្ទះមិត្ត ហើយជួយថែទ្រព្យសម្បត្តិ ។

**៣- ភីតស្ស បដិសរណំ ហោតិ** ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ ។ *អដ្ឋកថា* បទថា **ភីតស្ស** *( ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ )* មានសេចក្តីថា កាលបើភ័យណាមួយកើតឡើង មិត្តមានឧបការៈនិយាយថា កុំភ័យអី មានខ្ញុំនៅហើយ អ្នកខ្លាចធ្វើអ្វី ហើយក៏កម្ចាត់បង់នូវភ័យនោះចេញ ទៅជាទីពឹងពំនាក់បាន ។

**៤-ឧប្បន្នេសុ កិច្ចេសុ ករណីយេសុ តទ្ទិគុណំ ភោគំ អនុប្បទេតិ** កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ។ *អដ្ឋកថា* បទថា **តទ្ទិគុណំ ភោគំ** *( កាលបើកិច្ចដែលត្រូវធ្វើកើតឡើង*

ហើយតែងជួយផ្តល់ភោគៈជាទ្វិគុណជាទ្រព្យ ដែលមិត្តត្រូវការនោះ) មានសេចក្តីថា កាលបើកិច្ចដែលគួរធ្វើកើតឡើងហើយ មិត្តមានឧបការៈបានឃើញមិត្តមករកខ្លួន ហើយសួរថា មានរឿងអ្វីបានជាអ្នកមក ?

មិត្តរបស់ខ្លួនប្រាប់ថា មានការងារក្នុងរាជត្រកូល ។ មិត្តមានឧបការៈសួរថា តើអ្នកត្រូវការអ្វី ?

**មិត្តរបស់ខ្លួនប្រាប់ថា ខ្ញុំត្រូវការ ១ កហាបណៈ ។ មិត្តមានឧបការៈនិយាយថា ធម្មតាការងារក្នុងនគរ នឹងមិនអាចសម្រេចដោយកហាបណៈ១ទេ អ្នកចូរយក ២ កហាបណៈចុះ រួចក៏បានឱ្យ២កហាបណៈដូចដែលបាននិយាយមែន ។**

ឥមេហិ ខោ គហបតិបុត ចតូហិ ឋានេហិ សមា-ឆសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តមានឧបការៈជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

## មិត្តរួមសុខទុក្ខ ៤ យ៉ាង

ចត្តូហិ ខោ គហបតិបុត្ត ឋានេហិ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ៖

១- គុយ្ហមស្ស អាចិក្ខតិ ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ។ *អដ្ឋកថា* បទថា គុយ្ហមស្ស អាចិក្ខតិ ( ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត )មានសេចក្តីថា មិនប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនដល់អ្នកដទៃ ប្រាប់ដល់មិត្តតែប៉ុណ្ណោះ ។

២- គុយ្ហមស្ស បរិគុយ្ហតិ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ។ *អដ្ឋកថា* បទថា គុយ្ហមស្ស បរិគុយ្ហតិ (ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ) មានសេចក្តីថា មិត្តរួមសុខ រួមទុក្ខ រមែងរក្សានូវអាថ៌កំបាំង ដែលមិត្តបាននិយាយប្រាប់ មិនឱ្យមនុស្សដទៃដឹង ។

៣- អាបទាសុ ន វិជហាតិ មិនបោះបង់គ្នា ក្នុងគ្រាមានវិបត្តិ ។ *អដ្ឋកថា* អាបទាសុ ន វិជហាតិ (មិនបោះបង់

គ្នាក្នុងគ្រាមានវិបត្តិ ) មានសេចក្ដីថា កាលបើភ័យកើតឡើង មិត្ត រួមសុខរួមទុក្ខ រមែងមិនបោះបង់គ្នាចោលឡើយ ។

**៤-ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ** សូម្បីជីវិតក៏ ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្ដូរជីវិត ) ។ អដ្ឋកថា **បទថា ជីវិតំបិស្ស អត្ថាយ** ( សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បី ប្រយោជន៍ដល់មិត្ត ) មានសេចក្ដីថា សូម្បីតែជីវិតក៏មិត្តរួមសុខ រួមទុក្ខហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្តបានដែរ ។ មិត្តរួម សុខរួមទុក្ខនោះ ធ្វើការងាររបស់មិត្ត ឱ្យទាល់តែបានសម្រេចដោយ មិនគិតដល់ជីវិតរបស់ខ្លួនឡើយ ។

**ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ សមា-ណសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ** ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

# មិត្តប្រាប់ប្រយោជន៍ ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ៖

១- បាបា និវារេតិ ហាមមិត្តឱ្យឃ្លាតចាកអំពើអាក្រក់ ។ អដ្ឋកថា បទថា បាបា និវារេតិ ( ហាមមិត្តឱ្យឃ្លាតចាកអំពើអាក្រក់ ) មានសេចក្ដីថា មិត្តប្រាប់ប្រយោជន៍ រមែងហាមថា កាលបើខ្ញុំឃើញហើយ អ្នកមិនគួរធ្វើយ៉ាងនេះទេ អ្នកចូរកុំធ្វើនូវវេរាទាំង ៥ និងអកុសលកម្មបថ ១០ ឡើយ ។

២- កល្យាណេ និវេសេតិ ដឹកនាំឱ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ។ អដ្ឋកថាបទថា កល្យាណេ និវេសេតិ ( ដឹកនាំឱ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ) មានសេចកីថា មិត្តប្រាប់ប្រយោជន៍ រមែងឱ្យតាំងនៅក្នុងសេចក្ដីល្អយ៉ាងនេះថា អ្នកចូរធ្វើនូវអំពើល្អ ចូរតាំងនៅក្នុងព្រះសរណគមន៍ ៣ ក្នុងសីល ៥ ក្នុងកុសលកម្មបថ ១០ ចូរឱ្យទាន ធ្វើបុណ្យ ស្ដាប់នូវព្រះធម៌ ដូច្នេះ ។

៣- អស្សុតំ សាវេតិ ឱ្យបានឮពាក្យដែលមិនធ្លាប់បាន ឮ ។ *អដ្ឋកថា* បទថា អស្សុតំ សាវេតិ ( ឱ្យបានឮពាក្យដែលមិនធ្លាប់បានឮ ) គឺឱ្យស្តាប់នូវពាក្យដែលមានន័យ ជ្រាលជ្រៅនាំឱ្យមានប្រាជ្ញា ដែលមិនធ្លាប់បានឮ ។

៤- សគ្គស្ស មគ្គំ អាចិក្ខតិ ប្រាប់ផ្លូវឋានសួគ៌ ។ *អដ្ឋកថា* បទថា សគ្គស្ស មគ្គំ អាចិក្ខតិ ( ប្រាប់ផ្លូវឋានសួគ៌ ) មានសេចក្តីថា មិត្តប្រាប់ប្រយោជន៍ រមែងប្រាប់ផ្លូវឋានសួគ៌យ៉ាងនេះថា ជនទាំងឡាយធ្វើកម្មនេះ រមែងកើតក្នុងឋានសួគ៌ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុកម្ប-កោ មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អអ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

## មិត្តមានសេចក្តីឈឺឆ្អាល ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុកម្បកោ មិត្តោសុហទោវេទិតព្វោ ម្នាលគហបតិបុត្តមិត្ត មានសេចក្តីឈឺឆ្អាលជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន៤ យ៉ាងគឺ ៖

**១–** *អភវេនស្ស ន នន្ទតិ ជួយព្រួយចិត្ត ពីព្រោះមិត្ត បានសេចក្តីវិនាស ។ អដ្ឋកថា បទថា អភវេនស្ស ន នន្ទតិ (ជួយព្រួយចិត្ត ពីព្រោះមិត្តបានសេចក្តីវិនាស)* មានសេចក្តីថា *មិត្តមានសេចក្តីឈឺឆ្អាលកាលបានឃើញឬបានឮថាសេចក្តីវិនាស នៃបុត្តភរិយា ឬជនបរិវារ ព្រោះហេតុតែការបាត់បង់គឺសេចក្តីមិនចម្រើនរបស់មិត្តយ៉ាងនោះ រមែងមិនពេញចិត្ត គឺមិនសប្បាយចិត្តឡើយ ។*

**២–** *ភវេនស្ស នន្ទតិ ជួយត្រេកអរ ព្រោះមិត្តបាន សេចក្តីចម្រើន ។ អដ្ឋកថា បទថា ភវេនស្ស នន្ទតិ (ជួយ ត្រេកអរ ព្រោះមិត្តបានសេចក្តីចម្រើន)* មានសេចកីថា *មិត្តមាន សេចក្តីឈឺឆ្អាល បានឃើញ បានឮអំពីសេចក្តីចម្រើននៃស្រូវ សន្ទូងជាដើម ឬការបាននូវភាពជាធំ ព្រោះសេចក្តីចម្រើន របស់មិត្តមានសភាពបែបនោះ រមែងសប្បាយរីករាយ ។*

**៣–** *អវណ្ណំភណមានំ និវារេតិ ទទឹងទាស់នឹងមនុស្ស ដែលពោលទោសមិត្ត ។ អដ្ឋកថា បទថា អវណ្ណំ ភណមានំ និវារេតិ (ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត)* មាន

សេចក្ដីថា កាលបើមានមនុស្សនិយាយថា អ្នកនុ៎ះមានរូបអាក្រក់ មិនគួរជ្រះថ្លា មានជាតិថោកទាប ឬជាអ្នកទ្រុស្ដសីលដូច្នេះ ។ មិត្តមានសេចក្ដីឈឺឆ្អាល រមែងហាមអ្នកដទៃដែលពោលតិះដៀល មិត្តរបស់ខ្លួន ដោយពាក្យទាំងឡាយជាដើមថា សូមអ្នកកុំនិយាយយ៉ាងនេះមិត្តរបស់ខ្ញុំមានរូបល្អគួរឱ្យជ្រះថ្លា មានជាតិល្អ និងដល់ព្រមដោយសីល ។

**៤- វណ្ណំ ភណមានំ បសំសតិ** សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ។ *អដ្ឋកថា* **បទថា វណ្ណំ ភណមានំ បសំសតិ** (សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត) មានសេចក្ដីថា កាលបើមានអ្នកនិយាយថា មនុស្សឈ្មោះនោះ មានរូបល្អ គួរឱ្យជ្រះថ្លា មានជាតិល្អ ដល់ព្រមដោយសីល មិត្តមានសេចក្ដីឈឺឆ្អាល រមែងសរសើរមនុស្សដទៃដែលពោលសរសើរមិត្តរបស់ខ្លួនថា អ្នកនិយាយយ៉ាងនេះល្អហើយ ត្រឹមត្រូវហើយ អ្នកនោះពិតជាមានរូបល្អគួរឱ្យជ្រះថ្លាមានជាតិល្អនិងដល់ព្រមដោយសីលមែន ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុកម្ប-កោ មិត្តោ សុហទោ វេទិតព្វោតិ ម្នាលគហបតិបុត្ត មិត្តមានសេចក្ដីឈឺឆ្អាលជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ៕

## និគមគាថា

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា ព្រះមានព្រះភាគទ្រង់បានសម្ដែងសេចក្ដីនេះ លុះព្រះសុគតជាសាស្ដាត្រាស់សេចក្ដីនេះហើយ ទើបទ្រង់សម្ដែងពាក្យជាគាថាព័ន្ធតទៅទៀតថា ៖

ឧបការោច យោ មិត្តោ សុខទុក្ខោ ច យោ សខា
អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ ។
ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
សក្កច្ចំ បយិរុបាសេយ្យ មាតា បុត្តំវ ឱរសំ ។

មិត្តដែលមានឧបការៈ សំឡាញ់ដែលរួមសុខទុក្ខមិត្តដែលប្រាប់ប្រយោជន៍មិត្តដែលមានសេចក្ដីឈឺឆ្អាល ៕ បណ្ឌិតស្គាល់

ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថា ជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាលដូចជាមាតានិងបុត្តដែលកើតពីទ្រូង ។

បណ្ឌិតោ សីលសម្បន្នោ ជលំ អគ្គីវ ភាសតិ
ភោគេ សំហរមានស្ស ភមរស្សេវ ឥរីយតោ ។

អ្នកប្រាជ្ញបរិបូណ៌ដោយសីលតែងរុងរឿងដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឱ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។

ភោគា សន្និចយំ យន្តិ វម្មិកោវុបចីយតិ
ឯវំ ភោគេ សមាហរិត្វា អលមត្តោ កុលេ គិហី ។
ចតុធា វិភជេ ភោគេ ស វេ មិត្តានិ គន្ថតិ
ឯកេន ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ
ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតីតិ ។

ភោគៈទាំងឡាយតែងដល់នូវការកពូនជាគំនរដូចជាដំបូកដែលកណ្ដៀរកពូនដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូលបានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាង( តាំងខ្លួន ) កុលបុត្រ

ដែលចែកភោគៈទាំងឡាយជា ៤ ចំណែកសម្រាប់គឺបរិភោគៈ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតំម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ ( ទៅខាងមុខ ) កុលបុត្រនោះទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន ១ ។

បទថា ជលំ អគ្គីវ ភាសិតំ ( បណ្ឌិតបរិបូណ៌ដោយសីល តែងរុងរឿងដូចជាភ្លើងដែលភ្លឺដូច្នោះដែរ ) មានសេចក្តីថារមែងរុងរឿងដូចជាភ្លើងដែលភ្លឺនៅលើកំពូលភ្នំ ក្នុងវេលាយប់ ។

បទថា ភោគេ សំហរមានស្ស ( កាលបុគ្គលសន្សំទ្រព្យ ) មានសេចក្តីថា កាលបុគ្គលមិនបៀតបៀនខ្លួនឯងខ្លះ អ្នកដទៃខ្លះ សន្សំភោគៈដោយធម៌ ដោយស្មើ គឺធ្វើឱ្យជាគំនរ ។

បទថា ភមរស្សេវ ឥរិយតោ ( ដូចជាឃ្មុំធ្វើជាសម្បុកមាន សេចក្តីថា ធ្វើភោគៈឱ្យជាគំនរធំដោយលំដាប់ ដូចជាឃ្មុំដែលមិនបំផ្លាញពណ៌ និងក្លិនរបស់ផ្កាឈើ នាំយកកេសរ ដោយចុងចំពុះខ្លះ ដោយស្លាបទាំងពីរខ្លះ ហើយធ្វើសម្បុក តាំងពីគ្មានអ្វីសោះ រហូតក្លាយជាផ្ចិតដ៏ធំដោយលំដាប់ ។

បទថា ភោគាសន្និចយំយន្តិ ( ភោគៈទាំងឡាយតែង

ដល់នូវការពូនជាគំនរ ) មានសេចក្ដីថា ភោគៈទាំងឡាយ របស់បុគ្គលនោះ រមែងដល់នូវការកពូនជាគំនរយ៉ាងណា គឺ ដូចជាដំបូកដែលកណ្ដៀរកពូនឡើយដោយលំដាប់ ។ ព្រោះហេតុនោះទើបលោកពោលថា ដូចជាដំបូកដែលកណ្ដៀរកពូនឡើង អធិប្បាយថាភោគៈទាំងឡាយ រមែងដល់នូវការកពូនជាគំនរ ដូចជាដំបូកដែលកណ្ដៀរកពូនឡើងដូច្នោះ ។

បទថា សមាហរិត្វា ប្រែថា ប្រមូលរួបរួមហើយ ។

បទថា អលមត្តោ ( អ្នកមានអាង ) មានសេចក្ដីថា គ្រហស្ថអ្នកមានសភាពសមគួរ ឬជាអ្នកអាច ឬថាជាអ្នកប្រាជ្ញាដើម្បីគ្រប់គ្រងផ្ទះ ។ ឥឡូវនេះ កាលដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រទាននូវឱវាទ ដល់អ្នកតាំងនៅក្នុងការគ្រប់គ្រងផ្ទះទើប ត្រាស់នូវព្រះតម្រាស់ជាដើមថា ចតុធាវិភជេភោគេ ( អ្នកគ្រប់គ្រងផ្ទះគប្បីបែងចែកភោគៈជា ៤ ចំណែក ) ដូច្នេះ ។

ក្នុងបទទាំងឡាយនោះ បទថា សវេ មិត្តានិ គន្ថតិ ( បុគ្គលនោះឯងរមែងចងមិត្តបាន ) មានសេចក្ដីថា បុគ្គលជាអ្នកគ្រប់គ្រងផ្ទះនោះ កាលបែងចែកភោគៈយ៉ាងនេះឈ្មោះថា រមែង

ចងមិត្តទុកបានគឺចងរឹតនូវមិត្តភាពមិនឱ្យបែកចេញពីគ្នា ។ បុគ្គលអ្នកមានភោគៈ រមែងអាចរក្សានូវមិត្តបាន ពួកជនដទៃមិនអាចរក្សាបានឡើយ ។

បទថា **ឯកេន ភោគេ ភុញ្ជេយ្យ** ប្រែថា គប្បីបរិភោគទាំងឡាយ ១ ចំណែក ។

បទថា **ទ្វីហិ កម្មំ បយោជយេ** (ប្រកបការងារ ២ ចំណែក)មានសេចក្ដីថា គប្បីប្រកបដោយការងារទាំងឡាយមានកសិកម្មនិងពាណិជ្ជកម្មជាដើម ដោយទ្រព្យ២ ចំណែក ។

បទថា **ចតុត្ថញ្ច និធាបេយ្យ** (តម្កល់ទុក) គឺគប្បីតម្កល់ទុកនូវទ្រព្យចំណែកទី ៤ ។

បទថា **អាបទាសុ ភវិស្សតិ** (ក្រែងមានអន្តរាយទាំងឡាយ)មានសេចក្ដីថា ព្រោះការងារនោះមិនមែនចេះតែសម្រេចបានដោយលាភហូតទេ ជួនកាលអន្តរាយកើតឡើងដោយអំណាចរាជភ័យជាដើម ។ ដូច្នេះ ភោគៈគប្បីមានក្នុងកាលអន្តរាយទាំងឡាយកើតឡើងយ៉ាងនេះ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលអ្នកគ្រប់គ្រងផ្ទះគប្បីតម្កល់ទុកនូវទ្រព្យ ១ ចំណែកដូច្នេះ ។

ក្នុងចំណែកទាំងឡាយ៤ នេះ គប្បីតម្កល់ទុកនូវចំណែកណាមួយសម្រាប់បំពេញកុសលផង គឺក្នុងចំណែកដែលលោកពោលក្នុងបទថា ភោគេ កុញ្ជេយ្យ គួរកាន់យកអំពីចំណែកនោះបរិច្ចាគទានដល់ភិក្ខុទាំងឡាយខ្លះ ដល់មនុស្សកំព្រានិងអ្នកដើរផ្លូវឥតជាដើមខ្លះ គួរឱ្យវង្វាន់ដល់ជាងតម្បាញ និងជាងកាត់សក់ជាដើមខ្លះ ។

ដោយកថាមគ្គត្រឹមប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់ប្រទាននូវឱវាទដើម្បីឱ្យវៀរចាកធម៌ដែលវៀរ និងដើម្បីសេពនូវធម៌ដែលគួរសេពថា ម្នាលគហបតិបុត្ត អរិយសាវកលះបង់នូវអកុសលដោយហេតុទាំងឡាយ ៤ វៀរចាកនូវផ្លូវនៃសេចក្ដីវិនាសភោគៈដោយហេតុទាំងឡាយ ៦ សេពគប់មិត្ត ១៦ ពួកស្ថិតនៅក្នុងការគ្រប់គ្រងផ្ទះ ធ្វើការចិញ្ចឹមភរិយា រមែងចិញ្ចឹមជីវិតប្រកបដោយធម៌ នឹងរមែងរុងរឿងដូចជាគំនរភ្លើងក្នុងរវាងទេវតា និងមនុស្សទាំងឡាយ ឥឡូវនេះ ដើម្បីនឹងសម្ដែងអំពីទិស ៦ ដែលគួរគោរពទើបត្រាស់នូវព្រះតម្រាស់ជាដើមថា ម្នាលគហបតិបុត្ត អរិយសាវកបិទបាំងទិសទាំង ៦ ដូច្នេះ ។

## ព្រះគាថាប្រារព្ធចំពោះព្រះរាធត្ថេរៈ

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ

និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ

តាទិសំភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

*បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឱ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ( ព្រោះថា )កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា និធីនំ បានដល់ ឆ្នាំងនៃកំណប់ទ្រព្យ ដែលពេញដោយមាសប្រាក់ជាដើម ដែលគេកប់រក្សាទុកក្នុងទីនោះ ៗ ។*

*បទថា បវត្តារំ គឺដូចអ្នកធ្វើសេចក្តីអនុគ្រោះចំពោះមនុស្សទុគ៌តដែលរស់នៅដោយលំបាក ហើយបបួលថា លោកចូរមក*

យើងនឹងប្រាប់ឧបាយ ដែលជាគ្រឿងចិញ្ចឹមជីវិត ដោយស្រួលដល់លោក ដូច្នេះ ហើយនាំទៅកាន់ទីតាំងនៃកំណប់ទ្រព្យហើយលាតចង្អុលដៃចេញប្រាប់ថា អ្នកចូរកាន់យកទ្រព្យនេះ ចិញ្ចឹមជីវិតតាមសប្បាយចុះ ។

វិនិច្ឆ័យក្នុងបទថា វជ្ជទស្សិនំ ភិក្ខុអ្នកចង្អុលទោសមាន ២ ពួក គឺភិក្ខុអ្នកស្វែងរកទោស ដោយគិតដូច្នេះថា យើងនឹងផ្ចាញ់ផ្ចាល់ភិក្ខុនោះដោយកម្មមិនសមគួរ ឬដោយការភ្លាំងភ្លាត់កណ្ដាលជំនុំសង្ឃ ១ ពួក ភិក្ខុអ្នកតាំងនៅដោយភាវៈរបស់ខ្លួនជាអ្នកឃ្លាំមើលទោសនោះ ៗ ដើម្បីប្រយោជន៍នឹងឱ្យដឹងនូវហេតុដែលមិនទាន់ដឹង ដើម្បីត្រូវការឱ្យកាន់យកនូវហេតុដែលដឹងហើយ ព្រោះជាអ្នកប្រាថ្នានូវសេចក្ដីចម្រើននៃគុណមានសីលជាដើមដល់បុគ្គលនោះ ៗ ១ពយកភិក្ខុពួកក្រោយនេះព្រះដ៏មានព្រះភាគទ្រង់បំណងយកក្នុងបទថា វជ្ជទស្សិនំ នេះ ។

មនុស្សទុគ៌តត្រូវអ្នកដទៃគំរាមក្ដី វាយតប់ក្ដី ហើយចង្អុលប្រាប់កំណប់ទ្រព្យថា ឯងចូរកាន់យកកំណប់ទ្រព្យនេះចុះ រមែង

មិនញ៉ាំងសេចក្ដីក្រោធឱ្យកើតឡើង មានតែសេចក្ដីត្រេកអររីករាយប៉ុណ្ណោះយ៉ាងណា កាលបុគ្គលបែបនោះឃើញមារយាទមិនសមគួរក្ដី ការភ្លាំងភ្លាត់ក្ដី ហើយប្រាប់អ្នកទទួលនូវការប្រាប់នោះ មិនគួរធ្វើសេចក្ដីក្រោធឱ្យកើតឡើង ដល់អ្នកប្រាប់នោះឡើយ គួរជាអ្នកត្រេកអរតែម្យ៉ាងប៉ុណ្ណោះ យ៉ាងណា គប្បីបវារណាថា បពិត្រលោកម្ចាស់ដ៏ចម្រើន កម្មដ៏ធំនេះដែលអ្នកតាំងនៅក្នុងឋានៈជាអាចារ្យ ជាឧបជ្ឈាយ៍របស់ខ្ញុំ ហើយទូន្មានប្រៀនប្រដៅខ្ញុំ ខ្ញុំត្រេកអរខ្លាំងណាស់ តទៅលោកម្ចាស់គប្បីទូន្មានខ្ញុំទៀតដូច្នេះ ។

បទថា **និគ្គយ្ហវាទី** សេចក្ដីថា ក៏អាចារ្យពួកខ្លះលោកឃើញមារយាទ ដែលមិនសមគួរ ឬការភ្លាំងភ្លាត់របស់ពួកសិស្សមានសទ្ធិវិហារិកជាដើម ហើយមិនអាចដើម្បីនឹងនិយាយ ព្រោះខ្លាចថា សិស្សនេះបម្រើយើងដោយកិច្ចវត្តមានការឱ្យទឹកខ្ពុរព្រះឱស្ឋជាដើមដល់យើងដោយគោរព ប្រសិនបើយើងនឹងស្ដីបន្ទោសលោកសោត លោកនឹងមិនបម្រើយើង ការសាបសូន្យនឹងមានដល់យើងដោយអាការយ៉ាងនេះដូច្នេះហើយ មិនពោលសង្កត់សង្កិនទេ បុគ្គល

នោះឈ្មោះថា អ្នកកោយនូវទោស ដែលដូចជាសំរាមក្នុងព្រះសាសនានេះ ។

ចំណែកអាចារ្យណា កាលឃើញទោសបែបនោះហើយ គំរាមកំហែង ផ្ដន្ទាទោស ដាក់ទណ្ឌកម្ម នាំចេញចាកវិហារតាមសមគួរដល់ទោសឱ្យសិក្សា អាចារ្យបែបនេះឈ្មោះថា អ្នកមានប្រក្រតីពោលពាក្យសង្កត់សង្កិន តួយ៉ាងដូចជាព្រះសម្មាសម្ពុទ្ធ ។ សមដូចពាក្យ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទ តថាគតនឹងសង្កត់សង្កិន ម្នាលអានន្ទ តថាគតនឹងសរសើរបុគ្គលណាជាសារៈ បុគ្គលនោះនឹងតាំងនៅបាន ។

បទថា មេធាវី គឺអ្នកប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ។

បទថា តាទិសំ ជាដើមសេចក្ដីថាបុគ្គលគប្បីសេពគប់ គឺគប្បីចូលទៅអង្គុយជិតបណ្ឌិតមានសភាពបែបនោះ ព្រោះកាលដែលអន្តេវាសិកសេពគប់អាចារ្យដូច្នោះ គុណដ៏ប្រសើរវិសេសរមែងមានទោសដ៏លាមក រមែងមិនមាន គឺមានតែសេចក្ដីចម្រើនម្យ៉ាងប៉ុណ្ណោះ សេចក្ដីសាបសូន្យមិនមានឡើយ ។

## ព្រះគាថាប្រារព្ធចំពោះភិក្ខុអស្សជិនិងបុនព្វសុកៈ

ឱវទេយ្យា នុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។

*បណ្ឌិតគួរទូន្មានប្រៀនប្រដៅគួរហាមឃាត់នូវជនទាំងឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។*

### អធិប្បាយគាថា

*បណ្ដាបទទាំងនោះបទថា ឱវទេយ្យ សេចក្ដីថា កាលរឿងកើតឡើងហើយ ទើបពោល ឈ្មោះថា **ឱវាទ** កាលរឿងមិនទាន់កើតឡើង សម្ដែងនូវទោសដែលមិនទាន់មកដល់ ដោយអំណាចនៃពាក្យ មានពាក្យដូច្នេះជាដើមថា ទោសនឹងគប្បីមានដល់អ្នកដូច្នេះឈ្មោះថា **អនុសាសនី** ( ប្រៀនប្រដៅ )ពោលចំពោះមុខឈ្មោះថា **ឱវាទ** ( ទូន្មាន )បញ្ជូនទូតសាសន៍( បណ្ដាំទៅ )ក្នុងទីកំបាំងមុខឈ្មោះថា**អនុសាសនី**សូម្បីពោលតែមួយលើកឈ្មោះថា **ឱវាទ** ពោលរឿយ ៗឈ្មោះថា **អនុសាសនី** ម្យ៉ាងទៀតកំពុងឱ្យ*

ឱវាទនុ៎ះឯង ឈ្មោះថា **អនុសាសនី** គប្បីទូន្មានប្រៀនប្រដៅយ៉ាង នេះ ដោយប្រការដូច្នេះ ។

បទថា អសព្ភា សេចក្ដីថា គប្បីហាមឃាត់ចាកអកុសល-ធម៌ គប្បីឱ្យតាំងនៅក្នុងកុសលធម៌ ។

បទថា សតំ សេចក្ដីថា បុគ្គលបែបនេះនោះ រមែងជាទីស្រឡាញ់នៃសប្បុរសទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម ប៉ុន្តែមិនជាទីស្រឡាញ់នៃពួកបុគ្គល ដែលមិនឃើញធម៌មានបរលោកទៅប្រាសហើយ មានចក្ខុសំឡឹងមើលតែអាមិស បួសដើម្បីចិញ្ចឹមជីវិតតែម្យ៉ាងប៉ុណ្ណោះ ពួកអសប្បុរស រមែងចាក់ដោយលំពែងគឺមាត់យ៉ាងនេះថា លោកជាអាចារ្យឬជាឧបជ្ឈាយ៍របស់ពួកយើង ឬលោកមិនមែនជាអាចារ្យមិនមែនជាឧបជ្ឈាយ៍របស់ពួកយើងឬ ?ហេតុដូចម្ដេចបានជាលោកប្រៀនប្រដៅពួកយើង ?

## ព្រះគាថាត្រាស់ព្រួចំពោះព្រះថេរៈឈ្មោះឆន្នត្ថេរៈ

ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ

ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

## អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានោះថា ជនអ្នកត្រេកអរក្នុង អកុសលធម៌ មានកាយទុច្ចរិតជាដើម ឈ្មោះថា បាបមិត្ត បុគ្គលអ្នកដឹកនាំក្នុងហេតុដែលមិនសមគួរ មានការកាត់នូវទីតជាដើមក្ដី ឬការស្វែងរកមិនសមគួរ ២១ យ៉ាងក្ដី ឈ្មោះថា បុរសថោកទាប ។ មួយទៀត ជនទាំងពីរជំពូកនោះ ឈ្មោះថា បាបមិត្តផង ឈ្មោះថាជាបុរសថោកទាបផងបុគ្គលមិនគួរគប់គេគឺមិនគួរចូលទៅអង្គុយជិតបុគ្គលទាំងនោះ ។ ចំណែកបុគ្គលដែលល្អផ្ទុយគ្នា ឈ្មោះថាទាំងកល្យាណមិត្ត ទាំងសប្បុរសបុគ្គលគួរសេពគប់ គឺការអង្គុយជិតលោកទាំងនោះ ។

## ព្រះគាថាប្រារព្ធចំពោះព្រះមហាកប្បិនត្ថេរៈ

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

បណ្ឌិតដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ធម្មបីតិ សេចក្ដីថា អ្នកឆ្អែតក្នុងធម៌ អធិប្បាយថា អ្នកផឹកនូវធម៌ ។ ដែលឈ្មោះថា ព្រះធម៌នោះមិនមាននរណាផឹកបានដូចជាផឹកបបរយាគូជាដើម ដោយភាជនៈនោះទេក៏បុគ្គលណាពាល់ត្រូវនូវលោកុត្តរធម៌ ៩ យ៉ាង ដោយនាមកាយធ្វើឱ្យច្បាស់ដោយសភាពជាអារម្មណ៍ ចាក់ធ្លុះរហូតដល់អរិយសច្ច មានទុក្ខសច្ចជាដើម ដោយកិច្ច មានការចាក់ធ្លុះធម៌ដោយការកំណត់ដឹងជាដើម ឈ្មោះថា រមែងផឹកនូវធម៌ ។

ពាក្យថា សុខំ សេតិ នេះ ត្រឹមតែជាដើមសេចក្ដីនៃធម៌ទេសនាប៉ុណ្ណោះ អធិប្បាយថា រមែងនៅជាសុខក្នុងឥរិយាបថទាំង ៤ ។

បទថា វិប្បសន្នេន គឺមិនកករល្អក់ បានដល់ មិនមានឧបកិលេស ។

បទថា អរិយប្បវេទិតេ សេចក្ដីថា ក្នុងពោធិបក្ខិយធម៌ទាំងឡាយ មានសតិប្បដ្ឋាន ៤ ជាដើម ដែលព្រះអរិយទាំងឡាយ មានព្រះពុទ្ធជាដើមទ្រង់ប្រកាសហើយ ។

ពីរបទថា សទា រមតិ សេចក្ដីថា បណ្ឌិតអ្នកមានបីតិក្នុងធម៌បែបនោះមានចិត្តផូរផង់ ប្រកបដោយភាពជាបណ្ឌិត រមែងត្រេកអរគឺរមែងត្រេកអរ យ៉ាងក្រៃលែងគ្រប់កាល ។

## ព្រះគាថាប្រារព្ធចំពោះបណ្ឌិតសាមណេរ

ឧទកញ្ហិ នយន្តិ នេត្តិកា

ឧសុការា នមយន្តិ តេជនំ

ទារុំ នមយន្តិ តច្ឆកា

អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ ( ឱ្យត្រង់ ) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន ( ដូច្នោះដែរ ) ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះបទថា ឧទកំ ជាដើម សេចក្ដីថា ជនទាំងឡាយជីកនូវទីទួលលើផែនដី លប់រណ្ដៅឱ្យពេញហើយ ធ្វើជាប្រឡាយ ឬតម្កល់ឈើ ធ្វើជាស្នូក ហើយតែងបង្ហូរទឹក ទៅកាន់ទីដែលខ្លួនប្រាថ្នា ព្រោះដូច្នោះទើបឈ្មោះថា អ្នកបង្ហូរទឹក ។

បទថា តេជនំ បានដល់ កូនសរ ។

មានព្រះពុទ្ធាធិប្បាយត្រាស់ទុកដូច្នេះថា ៖

ពួកអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅតាមការពេញចិត្តរបស់ខ្លួនបាន សូម្បីជាងព្រួញ ក៏តែងពត់ព្រួញឱ្យត្រង់ ចំណែកជាង (ឈូស) កាលនឹងឈូសឈើដើម្បីជាប្រយោជន៍ដល់ទព្វសម្ភារៈ មានខ្នងកង់ជាដើម តែងពត់ឈើគឺធ្វើឱ្យត្រង់ ឬកោងតាមការពេញចិត្តរបស់ខ្លួន ។ បណ្ឌិតទាំងឡាយធ្វើហេតុមានប្រមាណប៉ុណ្ណោះ ឱ្យជាអារម្មណ៍យ៉ាងនោះហើយ ញ៉ាំងមគ្គមានសោតាបត្តិមគ្គជាដើមឱ្យកើតឡើង ឈ្មោះថា ទូន្មានខ្លួន ប៉ុន្តែ កាលសម្រេចព្រះអរហត្តហើយ រមែងចាត់ថា ទូន្មានខ្លួនបានជាស្ថាពរ ។

## ព្រះគាថាប្រារព្ធចំពោះព្រះលកុណ្ឌកភទ្ទិយត្ថេរៈ

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សម្មិញ្ជន្តិ បណ្ឌិតា ។

*ភ្នំថ្មតាន់មិនរំកើប ព្រោះខ្យល់ ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំកើបព្រោះពាក្យតិះដៀលនឹងពាក្យសរសើរ ( ជាដើម ) ដូច្នោះឯង ។*

## អធិប្បាយគាថា

*បណ្ដាបទទាំងនោះ ក្នុងបទថា និន្ទាបសំសាសុ នេះ ព្រះដ៏មានព្រះភាគត្រាស់សំដៅយកលោកធម៌តែ ២ បទ ក៏ពិតមែនហើយព្រោះដូច្នោះ គប្បីជ្រាបសេចក្ដីដោយអំណាចនៃលោកធម៌សូម្បីទាំង ៨ ។*

*អធិប្បាយថា ដូចភ្នំថ្មតាន់ មិនមានប្រហោង រមែងមិនកម្រើក គឺរមែងមិនរញ្ជួយ មិនញាប់ញ័រដោយសារខ្យល់ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម យ៉ាងណា កាលលោកធម៌សូម្បីទាំង ៨ គ្របសង្កត់ បណ្ឌិតទាំងឡាយ រមែងមិន*

កម្រើក គឺមិនរញ្ជួយ មិនញាប់ញ័រដោយអំណាចនៃសេចក្តីថ្កុំថ្កើង ថ្លាក់ ឬដោយអំណាចនៃសេចក្តីត្រេកអរជូរចេះដែរ ។

## ព្រះគាថាប្រារព្ធចំពោះមាតារបស់នាងកាណា

យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួនយ៉ាងនេះ ។

## អធិប្បាយគាថា

អន្លង់ទឹកឯណា សូម្បីសេនាទាំង ៤ ពួក[១] ឆ្លងមិនរលកមិនរញ្ជួយ អន្លង់ទឹកបែបនេះឈ្មោះថា រហទោ ក្នុងព្រះគាថានោះ ។

ទីលមហាសមុទ្រដែលមានជម្រៅដល់៨៤,០០០យោជន៍

១-បានដល់ ចតុរង្គសេនា គឺពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង បាលីថា ហត្ថិ អស្សរ រថ បត្តិកំ ។

ដោយអាការទាំងពួង ឈ្មោះថា អន្លង់ទឹក ពិតណាស់ ទឹកក្នុងទី ប្រមាណ ៤ ម៉ឺនយោជន៍ ដែលនៅខាងក្រោមនីលមហាសមុទ្រ នោះ រមែងកម្រើកញាប់ញ័រ ព្រោះហ្វូងត្រី ទឹកមានប្រមាណ ប៉ុណ្ណោះដែលនៅខាងលើ រមែងកម្រើកញាប់ញ័រ ព្រោះខ្យល់ (ចំណែក)ទឹកក្នុងទីប្រមាណ ៤ ពាន់យោជន៍ ដែលនៅត្រង់ កណ្តាល (នីលមហាសមុទ្រនោះ) រមែងមិនកម្រើកញាប់ញ័រ តាំងនៅនឹងថ្កល់ អន្លង់ទឹកនេះ ឈ្មោះថា អន្លង់ទឹកដ៏ជ្រៅ ។

បទថា ធម្មានិ បានដល់ ទេសនាធម៌ទាំងឡាយ ។ ព្រះ ដ៏មានព្រះភាគ ត្រាស់អត្ថាធិប្បាយទុកថា អន្លង់ទឹកនោះ ឈ្មោះ ថាថ្លា ព្រោះជាទឹកមិនប្រឡូកប្រឡំ ឈ្មោះថា មិនកករល្អក់ ព្រោះ ជាទឹកមិនកំរើកញាប់ញ័រយ៉ាងណា បណ្ឌិតទាំងឡាយស្តាប់ទេសនា ធម៌របស់តថាគតហើយ រមែងប្រាសចាកឧបក្កិលេស ដោយ អំណាចនៃមគ្គ មានសោតាបត្តិមគ្គជាដើម ឈ្មោះថា ថ្លាដូច្នេះ ដែរ ។ ចំណែកបុគ្គលអ្នកសម្រេច ព្រះអរហត្តហើយ រមែងជា អ្នកមានចិត្តថ្លាផូរផង់ ដោយប្រការទាំងពួង ។

## ព្រះគាថាប្រារព្ធចំពោះភិក្ខុ៥០០រូប

សព្វត្ថ វេ សប្បុរិសា វជន្តិ
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុក្ខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

*ពួកសប្បុរស តែងលះ(ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូវ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិត បើសេចក្តីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។*

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សព្វត្ថ បានដល់ ក្នុងធម៌ទាំងពួង ផ្សេងដោយធម៌មានខន្ធ[១]៥ ជាដើម ។ បុរសល្អ ឈ្មោះថា សប្បុរិសា ។

---

១. ខន្ធ ៥ រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណក្ខន្ធ ។

បទថា វជន្តិ សេចក្តីថា សប្បុរសកាលកំចាត់ឆន្ទរាគៈចេញដោយអរហត្តមគ្គញ្ញាណ ឈ្មោះថា លះបង់ឆន្ទរាគៈ ។

បទថា ន កាមកាមា បានដល់ អ្នកប្រាថ្នាកាម មួយ៉ាងទៀត បានដល់ ព្រោះហេតុនៃកាម គឺព្រោះកាមជាហេតុ ។

ពីរបទថា លបយន្តិ សន្តោ សេចក្តីថា សប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម រមែងមិនចរចាដោយខ្លួនឯងឡើយ ( ទាំង ) មិនញុំាំងអ្នកដទៃឱ្យរវើរវាយ ព្រោះហេតុនៃកាម ។ ពិតណាស់ ភិក្ខុពួកណាចូលទៅដើម្បីភិក្ខាតាំងនៅក្នុងឥដ្ឋាចារ ពោលពាក្យជាដើមថា ម្នាលឧបាសក បុត្រកិរិយារបស់អ្នកសុខសប្បាយជាទេ ? ឧបទ្រវៈណា ៗ ដោយអំណាចនៃរាជភ័យនិងចោរភ័យជាដើមមិនបានមានក្នុងសត្វជើង២និងសត្វជើង៤របស់អ្នកទេឬ ? ភិក្ខុទាំងនោះ ឈ្មោះថា រមែងចរចាដោយខ្លួនឯង ។ លុះពោលយ៉ាងនោះហើយ ( និយាយ )ឱ្យគេនិមន្តខ្លួនថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាគ្រប់គ្នាមានសេចក្តីសុខសប្បាយជាទេ ឧបទ្រវៈណា ៗមិនដែលមានឡើយ ឥឡូវនេះផ្ទះរបស់ពួកខ្ញុំមានបាយនិងទឹកដ៏ច្រើន និមន្តលោកម្ចាស់នៅទីនេះហើយ ដូច្នេះ

ឈ្មោះថា ញ៉ាំងអ្នកដទៃឱ្យចរចា ។ ចំណែកសប្បុរសទាំងឡាយ រមែង មិនធ្វើនូវការចរចា សូម្បីទាំងពីរយ៉ាងនោះ ។

ពាក្យថា សុខេន ផុដ្ឋា អថ វា ទុក្ខេន ត្រឹមតែជាប្រធាននៃទេសនា ។

អធិប្បាយថា បណ្ឌិតទាំងឡាយដែលលោកធម៌ទាំង៨[១] ពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះ ដោយអំណាចនៃសេចក្តីត្រេកអរ និងសេចក្តីជាអ្នកអៀនខ្មាស ឬដោយអំណាចនៃការពោលគុណនិងទោសឡើយ ។

## ព្រះគាថាប្រារព្ធចំពោះព្រះធម្មិកត្ថេរ

ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

បណ្ឌិតមិនគួរធ្វើអាក្រក់ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់

---

១. លាភ វិនាសលាភ យស វិនាសយស និន្ទា សរសើរ សុខ ទុក្ខ ។

ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ន អត្តហេតុ សេចក្ដីថា ធម្មតាបណ្ឌិត រមែងមិនធ្វើបាប ព្រោះហេតុនៃខ្លួន ឬព្រោះហេតុនៃអ្នកដទៃ ។

បទថា ន បុត្តមិច្ឆេ សេចក្ដីថា បណ្ឌិតមិនគួរប្រាថ្នានូវបុត្រ ឬទ្រព្យ ឬដែន ដោយអំណាចកម្មដ៏លាមកឡើយ បណ្ឌិតមិនគប្បីប្រាថ្នានូវវត្ថុទាំងនោះ ហើយរមែងមិនធ្វើកម្មដ៏លាមកឡើយ ។

បទថា សមិទ្ធិមត្តនោ សេចក្ដីថា បណ្ឌិតមិនគប្បីប្រាថ្នាសិទ្ធិដើម្បីខ្លួនដោយហាតុដែលមិនមែនជាធម៌ ។ អធិប្បាយថា បណ្ឌិត រមែងមិនធ្វើបាប ព្រោះហេតុនៃសេចក្ដីសំរេចឡើយ ។

បទថា ស សីលវា សេចក្ដីថា បុគ្គលបែបនេះគប្បីជាអ្នកមានសីល មានបញ្ញា និងតាំងនៅក្នុងធម៌ ។ អធិប្បាយថា មិនគប្បីជាយ៉ាងដទៃ ។

## ព្រះគាថាប្រារព្ធចំពោះការស្ដាប់ធម៌

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណាដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះមានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។ ជនទាំងឡាយណាប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតទ្រង់សំដែងទុកហើយដោយប្រពៃជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបានហើយដល់នូវព្រះនិព្វាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អប្បកា គឺតិចតួច បានដល់ មិនច្រើន ។ បទថា **បារគាមិនោ** គឺសម្រេចព្រះនិព្វាន ។ បាទព្រះគាថាថា **អថាយំ ឥតរា បជា** សេចក្ដីថា ចំណែកឯ ប្រជាដ៏សេស រមែងស្ទុះទៅកាន់ត្រើយគឺសក្កាយទិដ្ឋិរឿយ ៗ ។

បទថា **សម្មទក្ខាតេ** គឺទ្រង់ត្រាស់សម្ដែងដោយប្រពៃ បានដល់ ទ្រង់ត្រាស់សំដែងយ៉ាងត្រឹមត្រូវ ។

បទថា **ធម្មេ** គឺក្នុងទេសនាធម៌ ។ បទថា **ធម្មានុវត្តិនោ** សេចក្ដីថា ប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ គឺស្ដាប់ធម៌នោះហើយ បំពេញបដិបទាដ៏សមគួរ ដល់ធម៌នោះហើយ ធ្វើមគ្គផលឱ្យជាក់ច្បាស់ ។

បទថា **បារមេស្សន្តិ** សេចក្ដីថាជនទាំងនោះ គឺបែបនោះ ដល់ត្រើយ គឺព្រះនិព្វាន ។

បទថា **មច្ចុធេយ្យំ** បានដល់ វដ្ដៈដែលប្រព្រឹត្តទៅក្នុង ភូមិ ៣ ដែលជាលំនៅរបស់មច្ចុ ពោលគឺ កិលេសមារ ។

បទថា សឧត្តរំ សេចក្ដីថា ជនទាំងឡាយណាប្រព្រឹត្តធម៌ ជនទាំងនោះរមែងឆ្លង គឺឋាកន្លងនូវអន្លង់នៃមារ ( ទីលំនៅនៃមារ ) ដែលបុគ្គលឆ្លងបាន ដោយក្រៃក្រៃពេកហើយ ដល់នូវត្រើយ គឺព្រះនិព្វាន ។

## ព្រះគាថាប្រារព្ធចំពោះភិក្ខុអាគន្តុក

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌សឱ្យចំរើនឡើង ( ដោយវិធី ) ចេញចាកអាល័យ គឺកាមគុណហើយឈមទៅរកព្រះនិព្វាន ជាធម្មជាតិមិនមានអាល័យ គប្បីលះបង់កាមទាំង

ឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុំាងខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយក្នុងអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះ ៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿងបរិនិព្វានក្នុងលោក ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះពីរបទថា កណ្ហំ ធម្មំ សេចក្តីថា លះគឺលះបង់អកុសលធម៌ផ្សេង ៗមានកាយទុច្ចរិតជាដើម ។

ពីរបទថា សុក្កំ ភាវេថ សេចក្តីថា ភិក្ខុដែលជាបណ្ឌិតគួរចម្រើនធម៌ស មានកាយសុចរិតជាដើម តាំងអំពីចេញបួសរហូតដល់អរហត្តមគ្គ ។ ចម្រើនយ៉ាងណា ?គឺចេញចាកអាល័យប្រារព្ធធម៌ដែលមិនមានអាល័យ ។

អធិប្បាយថា ធម៌ដែលជាហេតុធ្វើឱ្យអាល័យ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ហៅថា **ឱកៈ** ធម៌ដែលជាហេតុធ្វើមិនឱ្យ

មានអាល័យ ទ្រង់ត្រាស់ហៅថា **អនោកៈ** បណ្ឌិតចេញចាកធម៌ដែលជាហេតុធ្វើឱ្យមានអាល័យ ហើយឈមទៅរក គឺប្រារព្ធព្រះនិព្វាន ពោលគឺធម៌ដែលមិនមានអាល័យ កាលប្រាថ្នាព្រះនិព្វាននោះ គួរចម្រើនធម៌ស ។

បាទព្រះគាថាថា **តត្រាភិរតិមិច្ឆេយ្យ** សេចក្តីថា គប្បីប្រាថ្នានូវសេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងវិវេក ដែលរាប់ជាធម៌មិនមានអាល័យ គឺព្រះនិព្វានដែលសត្វទាំងនោះអភិរម្យ បានដោយលំបាក ។

ពីរបទថា **ហិត្វា កាមេ** សេចក្តីថា លះវត្ថុកាម និងកិលេសកាមហើយ ជាអ្នកអស់សេចក្តីកង្វល់ គប្បីប្រាថ្នាសេចក្តីត្រេកអរក្រៃលែងក្នុងវិវេក ។

បទថា **ចិត្តក្លេសេហិ** សេចក្តីថា គប្បីធ្វើខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្តគឺឱ្យបរិសុទ្ធិចាកអំពីនីវរណ៍ទាំង ៥ ។

បទថា **សម្ពោធិយង្គេសុ** បានដល់ ក្នុងអង្គធម៌ជាគ្រឿងត្រាស់ដឹង ។

បទព្រះគាថាថា សម្មា ចិត្តំ សុភាវិតំ សេចក្ដីថា ( ជនទាំងឡាយណា ) អប់រំ គឺចម្រើនចិត្តដោយល្អហើយ តាមហេតុ គឺតាមន័យ ។

បទព្រះគាថាថា អាទានប្បដិនិស្សគ្គេ សេចក្ដីថា ការប្រកាន់មាំត្រាស់ហៅថា អាទាន បណ្ឌិតទាំងឡាយណាមិនប្រកាន់មាំនូវអ្វី ? ដោយឧបាទាន ៤ ត្រេកអរក្នុងកាលៈនូវសេចក្ដីប្រកាន់មាំ ពោលគឺការលះបង់នូវសេចក្ដីប្រកាន់មាំនោះ ។

បទថា ជុតិមន្តោ សេចក្ដីថា អ្នកមានអានុភាព គឺ អ្នកញុំាងធម៌ទាំងឡាយ មានខន្ធជាដើមឱ្យរុងរឿង ហើយតាំងនៅយ៉ាងមាំដោយពន្លឺ គឺអរហត្តមគ្គញ្ញាណ ។

ពីរបទថា តេ លោកេ ជាដើម សេចក្ដីថា បណ្ឌិតទាំងឡាយនោះ ៗ រមែងជាអ្នកអស់អាសវៈហើយ រុងរឿងក្នុងខន្ធាទិ-លោកនេះ គឺ បរិនិព្វាន ដោយបរិនិព្វាន ២ យ៉ាង គឺដោយបរិនិព្វានដែលមានឈ្មោះថា សឧបាទិសេសនិព្វាន ព្រោះកិលេសវដ្តៈដែលខ្លួនធ្វើឱ្យអស់ហើយ តាំងអំពីវេលាដែលបានសម្រេច

ព្រះអរហត្តនិងដោយបរិនិព្វានដែលមានឈ្មោះថា អនុបាទិសេសនិព្វាន ព្រោះខន្ធវដ្ដៈ ដែលខ្វះនធ្វើឱ្យអស់ហើយ ដោយរលត់ចរិមចិត្ត ( ចិត្តចុងក្រោយ ) គឺដល់ការបញ្ញត្តិមិនបាន ដូចប្រទីបមានប្រេងអស់ដូច្នោះ ។

## អានិសង្សការសេពគប់បណ្ឌិត

បុគ្គលណា មិនសេពគប់នូវពួកបុគ្គលពាល, បុគ្គលនោះឈ្មោះថា សេពគប់បណ្ឌិត ។ ការសេពគប់នូវបុគ្គលជាបណ្ឌិតនេះ រមែងធ្វើឱ្យកើតនូវអរិយទ្រព្យទាំង ៧ មាន **សទ្ធា** ការជឿទៅលើអ្វីដែលត្រឹមត្រូវតាមគន្លងនៃព្រះពុទ្ធសាសនា ដូចជាជឿថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន, សត្វទាំងឡាយប្រព្រឹត្តទៅតាមកម្ម, មានកម្មជារបស់ខ្លួន ឬ ក៏ជឿទៅលើព្រះគុណនៃព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គគឺជាសាស្ដានៃទេវតានិងមនុស្សទាំងឡាយជាដើម ។ **សីល** ការសង្រួមទៅតាមផ្លូវកាយ វាចា ចិត្ត ពោលគឺមាននូវសីល ៥ សីល ៨ ឬសីល ១០ ជាដើម ។ **សុតៈ** គឺរមែងចម្រើនដោយការស្ដាប់ មានការស្ដាប់ព្រះធម៌ជាដើម ដែលជាសមុដ្ឋានធ្វើឱ្យកើតបញ្ញា ។ **ចាគៈ** រមែងជាអ្នកមិន

មានសេចក្តីកំណាញ់ បេះលះបង់ទ្រព្យសម្បត្តិធ្វើទាន ទៅតាមសទ្ធា ទៅតាមកម្លាំងទ្រព្យជាដើម ។ **បញ្ញា** បុគ្គលដែលចូលទៅសេពគប់បណ្ឌិតរមែងចំរើននូវបញ្ញា ព្រោះរមែងធ្វើបុគ្គលដែលចូលទៅសេពគប់នោះ ឱ្យចំរើនទាំងក្នុងបច្ចុប្បន្ននិងទៅបរលោកនាយយ៉ាងពិតប្រាដក ។ **នត្ថិ បញ្ញា សមា អាភា** ពន្លឺអ្វីស្មើដោយបញ្ញាមិនមានឡើយ ។ **សុស្សូសំ លភតេ បញ្ញំ** ការស្តាប់ដោយល្អ រមែងបាននូវបញ្ញា ។ **ហិរិ** រមែងមានសេចក្តីខ្មាសបាប ។ **ឱត្តប្ប** រមែងមានសេចក្តីខ្លាចបាប ។ មិនត្រឹមតែប៉ុណ្ណោះ ការសេពគប់បណ្ឌិតជាសប្បុរសនេះ រមែងធ្វើឱ្យកើតនូវអដ្ឋង្គិកមគ្គទាំង ៨ ទៀតផង ដូចមានសម្តែងជាហូរហែងខាងក្រោមនេះ ។

## សាលសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨៦ ព្រះអង្គទ្រង់ត្រាស់ [**អំពីសេចក្តីចម្រើន៥ ប្រការ**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ដើមឈើ ចម្រើនឡើងដោយសេចក្តីចម្រើន៥ យ៉ាង ព្រោះអាស្រ័យស្តេចភ្នំឈ្មោះ ហិមវន្ត ។ **៥ យ៉ាង ដូចម្តេចខ្លះ?**

១- សាខាបត្តបលាសេន វឌ្ឍន្តិ ចម្រើនដោយមែក ស្លឹក ត្រួយ

២- តចេន វឌ្ឍន្តិ ចម្រើនដោយសម្បក

៣- បប្បដិកាយ វឌ្ឍន្តិ ចម្រើនដោយក្រមរ

៤- ផេគ្គុណា វឌ្ឍន្តិ ចម្រើនដោយស្រាយ

៥- សារេន វឌ្ឍន្តិ ចម្រើនដោយខ្លឹម ។

ម្នាលភិក្ខុទាំងឡាយ ដើមឈើធំចម្រើនឡើងដោយសេចក្តីចម្រើន ៥ យ៉ាងនេះ ព្រោះអាស្រ័យស្តេចភ្នំឈ្មោះ ហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុងរមែងចម្រើន ដោយសេចក្តីចម្រើន៥ យ៉ាង ព្រោះអាស្រ័យជនជាម្ចាស់ ត្រកូលមានសទ្ធាដូច្នោះដែរ ។ **៥ យ៉ាងដូចម្តេចខ្លះ៖**

១- សទ្ធា វឌ្ឍន្តិ គឺចម្រើនដោយសទ្ធា

២- សីលេន វឌ្ឍន្តិ ចម្រើនដោយសីល

៣- សុតេន វឌ្ឍន្តិ ចម្រេនដោយសុតៈ

៤- ចាគេន វឌ្ឍន្តិ ចម្រើនដោយចាគៈ

៥- បញ្ញា វឌ្ឍន្តិ ចម្រើនដោយបញ្ញា ។

ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចម្រើនដោយសេចក្ដីចម្រើន ៥ យ៉ាងនេះ ព្រោះអាស្រ័យជនជាម្ចាស់ត្រកូលមានសទ្ធា ។

យថា ហិ បព្វតោ សេលោ អរញ្ញស្មឹ ព្រហាវនេ
តំ រុក្ខា ឧបនិស្សាយ វឌ្ឍន្តេតេ វនប្បតី
តថេវ សីលសម្បន្នំ សទ្ធំ កុលបុត្តំ ឥធ
ឧបនិស្សាយ វឌ្ឍន្តិ បុត្តទារា ច ពន្ធវា
អមច្ចា ញាតិសង្ឃា ច យេ ចស្ស អនុជីវិនោ
ត្យស្ស សីលវតោ សីលំ ចាគំ សុចរិតានិ ច
បស្សមានានុកុព្វន្តិ យេ ភវន្តិ វិចក្ខណា
ឥធ ធម្មំ ចរិត្វាន សគ្គំ សុគតិគាមិនំ
នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោ ។

ភ្នំថ្មក្នុងដងព្រៃធំ ដើមឈើធំ ៗទាំងនោះរមែងចម្រើនឡើង ព្រោះអាស្រ័យភ្នំថ្មនោះយ៉ាងណាមិញ កូនប្រពន្ធទាំងឡាយ ផៅ

ពង្សទាំងឡាយ អាមាត្យទាំងឡាយ ពួកញាតិទាំងឡាយ ពួកជនអ្នកចិញ្ចឹមជីវិតដោយសារបុគ្គលនោះ រមែងចម្រើនឡើង ព្រោះអាស្រ័យនឹងកុលបុត្រអ្នកមានសទ្ធា បរិបូណ៌ដោយសីលក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។ ពួកជនមានកូននិងប្រពន្ធជាដើមនោះឃើញសីលផង ចាគៈផង និងសុចរិតទាំងឡាយផង របស់កុលបុត្រអ្នកមានសីលនោះហើយ រមែងធ្វើតាម ។ ក្នុងលោកនេះ ពួកអ្នកប្រាជ្ញណាជាអ្នកប្រព្រឹត្តធម៌ ជាអ្នកមានដំណើរទៅកាន់សុគតិសួគ៌ ពួកអ្នកប្រាជ្ញនោះ ជាអ្នកត្រេកអររីករាយសម្រេចដូចសេចក្តីប្រាថ្នានៅក្នុងទេវលោក ។

### អដ្ឋកថា

បទថា អរញ្ញស្មឹ គឺក្នុងទីដែលមិនមែនភូមិស្រុក ។

បទថា ព្រហារនេ បានដល់ ក្នុងព្រៃស្រោង ។

## ទុតិយអប្បមាទសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ២៣៦ ព្រះអង្គទ្រង់ត្រាស់នូវ [ការគប់រកកល្យាណមិត្តញុំាងប្រយោជន៍ ឱ្យសម្រេចដល់

ព្រហ្មចរិយ ] ដោយមានសេចក្ដីថា ៖

ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... គង់នៅក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គពួនសម្ងំនៅក្នុងទីស្ងាត់ឯណោះ មានសេចក្ដីត្រិះរិះក្នុងចិត្ត កើតឡើងយ៉ាងនេះថា ធម៌ដែលព្រះមានព្រះភាគត្រាស់ហើយដោយប្រពៃ ធម៌នោះឯង ជារបស់បុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន មិនមិនមែនជារបស់បុគ្គលអ្នកមានមិត្តអាក្រក់ អ្នកមានសម្លាញ់អាក្រក់ អ្នកបង្អោនទៅរកបាបជនឡើយ ។

បពិត្រមហារាជ នុ៎ះ យ៉ាងនេះមែនហើយ បពិត្រមហារាជ នុ៎ះ យ៉ាងនេះមែនហើយ បពិត្រមហារាជ ធម៌ដែលតថាគតត្រាស់ហើយដោយប្រពៃ ធម៌នោះឯងជារបស់បុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន មិនមែនជារបស់បុគ្គលអ្នកមានមិត្តអាក្រក់ អ្នកមានសម្លាញ់អាក្រក់ អ្នកបង្អោនទៅរកបាបជនឡើយ ។

បពិត្រមហារាជ សម័យមួយ តថាគតនៅក្នុងនិគម ឈ្មោះនគរកៈរបស់ពួកសក្យជនក្នុងសក្កជនបទឯណោះ ។

បពិត្រមហារាជ លំដាប់នោះឯង ភិក្ខុឈ្មោះអានន្ទបានចូលទៅរកតថាគត លុះចូលទៅដល់ថ្វាយបង្គំតថាគតហើយ អង្គុយក្នុងទីសមគួរ ។ បពិត្រមហារាជ លុះអានន្ទភិក្ខុអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាគុណពាក់កណ្ដាលរបស់មគ្គព្រហ្មចរិយៈ ។ បពិត្រមហារាជ កាលអានន្ទភិក្ខុក្រាបទូលយ៉ាងនេះហើយ តថាគតបានត្រាស់នឹងអានន្ទភិក្ខុ ដូច្នេះថា ៖

✶.**ម្នាលអានន្ទ** ! អ្នកកុំនិយាយយ៉ាងនេះឡើយ ឯភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះចាត់ជាមគ្គព្រហ្មចរិយៈទាំងមូល ម្នាលអានន្ទ មគ្គព្រហ្មចរិយៈនុ៎ះ កើតប្រាកដដល់ភិក្ខុដែលជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ភិក្ខុនោះនឹងចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នឹងធ្វើឱ្យរឿយ ៗនូវ

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

✷.**ម្នាលអានន្ទ**! ចុះភិក្ខុអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឱ្យរឿយ ៗនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូចម្ដេច ។

✷. **ម្នាលអានន្ទ** ! ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិដែលអាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ មានកិរិយាបង្អោនចិត្តទៅដើម្បីលះកិលេស ចម្រើននូវសម្មាសង្កប្បៈ ( សេចក្ដីត្រិះរិះត្រូវ )ចម្រើននូវសម្មាវាចា ( សម្ដីត្រូវ )ចម្រើននូវសម្មាកម្មន្ត ( ការងារត្រូវ ) ចម្រើននូវសម្មាអាជីវៈ ( ចិញ្ចឹមជីវិតត្រូវ )ចម្រើននូវសម្មាវាយាម ( សេចក្ដីព្យាយាមត្រូវ )ចម្រើននូវសម្មាសតិ ( សេចក្ដីរលឹកត្រូវ )ចម្រើននូវសម្មាសមាធិ ( សេចក្ដីដម្កល់ចិត្តក្នុងអារម្មណ៍ដែលត្រូវ ) ដែលប្រកបអាស្រ័យវិវេក, អាស្រ័យវិរាគ អាស្រ័យនិរោធ មានកិរិយាបង្អោនចិត្តទៅដើម្បីលះកិលេស ។

✷.**ម្នាលអានន្ទ** !ភិក្ខុអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ

អ្នកបង្អោនទៅរកកល្យាណជន តែងចម្រើននូវមគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ តែងធ្វើឱ្យរឿយ ៗ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយប្រការដូច្នេះឯង ។

✶.**ម្នាលអានន្ទ** ! ភាពនៃបុគ្គលអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាតួមគ្គព្រហ្មចរិយៈទាំងមូលដោយហេតុណា ហេតុនោះ បុគ្គលត្រូវដឹងដោយបរិយានេះឯង ។

✶.**ម្នាលអានន្ទ**! សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិ សត្វទាំងឡាយ មានជរាជាធម្មតា រមែងរួចចាកជរា សត្វទាំងឡាយ មានព្យាធិជាធម្មតា រមែងរួចចាកព្យាធិ សត្វទាំងឡាយ មានមរណៈជាធម្មតា រមែងរួចចាកមរណៈ សត្វទាំងឡាយ មានសោកៈ បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសជាធម្មតា រមែងរួចចាកសោក បរិទេវ ទុក្ខទោមនស្សនិងឧបាយាសទាំងឡាយបាន ក៏ព្រោះអាស្រ័យតថាគតជាមិត្តល្អ ។

✶.**ម្នាលអានន្ទ** ! ភាពនៃបុគ្គលអ្នកមានមិត្តល្អ ជាអ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន នេះជាមគ្គ-

ព្រហ្មចរិយៈទាំងមូលដោយហេតុណា ហេតុនោះបុគ្គលត្រូវដឹងដោយបរិយាយនេះឯង ។

៦. **បពិត្រមហារាជ** ព្រោះហេតុនោះ ក្នុងសាសនានេះ ព្រះអង្គគប្បីសិក្សាយ៉ាងនេះថា អាត្មាអញជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន ។

បពិត្រមហារាជ ព្រះអង្គគប្បីសិក្សាយ៉ាងនេះឯង

៦. **បពិត្រមហារាជ** ធម៌មួយនេះគឺសេចក្តីមិនប្រមាទក្នុងធម៌ជាកុសលទាំងឡាយ ព្រះអង្គជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជន គួរតែអាស្រ័យនៅកុំខាន ។

៦. **បពិត្រមហារាជ** កាលបើព្រះអង្គ ជាអ្នកមិនប្រមាទអាស្រ័យសេចក្តីមិនប្រមាទហើយ សូម្បីស្រីស្នំដែលដើរហែតាមក៏គង់មានសេចក្តីត្រិះរិះថា ព្រះរាជាមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយជាអ្នកមិនប្រមាទ បើដូច្នោះមានតែយើងទាំងឡាយជាអ្នកមិនប្រមាទ អាស្រ័យសេចក្តីមិនប្រមាទដែរ ។

⮡. **បពិត្រមហារាជ** កាលបើព្រះអង្គជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីក្សត្រទាំងឡាយ ដែលជាចំណុះគង់មានសេចក្ដីត្រិះរិះយ៉ាងថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។

⮡. **បពិត្រមហារាជ** កាលបើព្រះអង្គ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីពួកពលគង់មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទ បើដូច្នោះមានតែយើងទាំងឡាយជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។

⮡. **បពិត្រមហារាជ** កាលបើព្រះអង្គ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីអ្នកនិគមនិងអ្នកជនបទគង់មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះរាជាជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ បើដូច្នោះ មានតែយើងទាំងឡាយ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទដែរ ។

⮡. **បពិត្រមហារាជ** កាលបើព្រះអង្គ ជាអ្នកមិនប្រមាទ អាស្រ័យសេចក្ដីមិនប្រមាទហើយ សូម្បីខ្លួនក្ដីក៏នឹងឈ្មោះថា ព្រះ

អង្គបានគ្រប់គ្រងរក្សាស្រីស្នំក្តី ក៏នឹងឈ្មោះថា ព្រះអង្គបានគ្រប់គ្រងរក្សាព្រះឃ្លាំងនិងជម្រុកក្តី ក៏នឹងឈ្មោះថា ព្រះអង្គបានគ្រប់គ្រងរក្សា ។

ព្រះមានព្រះភាគ បានត្រាស់នូវគាថានេះចប់ហើយ ទើបបានត្រាស់គាថាតទៅទៀតថា ៖

ភោគេ បត្ថយមានេន ឧឡារេ អបរាបរេ
អប្បមាទំ បសំសន្តិ បុញ្ញក្រិយាសុ បណ្ឌិតា
អប្បមត្តោ ឧភោ អត្ថេ អធិគណ្ហាតិ បណ្ឌិតា
ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

បុគ្គលកាលប្រាថ្នានូវភោគៈទាំងឡាយ ឱ្យច្រើនលើសលុប ត ៗទៅ គួរតែធ្វើសេចក្តីមិនប្រមាទ បណ្ឌិតទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ បណ្ឌិតអ្នកមិនប្រមាទ តែងបានសម្រេចប្រយោជន៍ទាំងពីរគឺប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងបរលោកក្តី ធីរជន ឈ្មោះថាបណ្ឌិត ព្រោះបាននូវប្រយោជន៍នោះ ៗ ។

## អដ្ឋកថា

បទថា សោ ច ខោ កល្យាណមិត្តស្ស សេចក្ដីថាក៏ធម៌នេះ រមែងឈ្មោះថា ស្វាក្ខាតធម៌របស់អ្នកមានមិត្តល្អប៉ុណ្ណោះ មិនមែនស្វាក្ខាតធម៌របស់អ្នកមានមិត្តអាក្រក់ទេ ពិតមែន ធម៌ជាស្វាក្ខាតធម៌ សូម្បីរបស់គ្រប់គ្នាក៏ពិត ប៉ុន្តែរមែងធ្វើប្រយោជន៍ឱ្យពេញដល់អ្នកមានមិត្តល្អ អ្នកតាំងចិត្តស្ដាប់ដោយល្អ អ្នកព្រមជឿ ដូចថ្នាំជាប្រយោជន៍ដល់អ្នកប្រើ មិនជាប្រយោជន៍ដល់អ្នក មិនប្រើទេ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះ គប្បីជ្រាបថា ទេសនាធម៌ក្នុងពាក្យថា ធម្មោ នេះ ។

បទថា ឧបឌ្ឍមិទំ សេចក្ដីថា បានឮថា ព្រះថេរៈទៅក្នុងទីកំបាំងគិតថា កាលមិត្តល្អអ្នកឱវាទទូន្មានមាន សមណធម៌នេះរមែងសម្រេចប្រយោជន៍ ដល់អ្នកតាំងនៅក្នុងសេចក្ដីព្យាយាមចំពោះខ្លួន ដូច្នោះ ព្រហ្មចរិយពាក់កណ្ដាលមកពីមិត្តល្អ ពាក់កណ្ដាល មកពីសេចក្ដីព្យាយាមចំពោះខ្លួន ។ គ្រានោះ ព្រះ

ថេរៈត្រិះរិះថា យើងនៅក្នុងបទេសញាណ (ញាណក្នុងធម៌ចំណែកខ្លះ) ដឹងចំណែកខ្លះមិនអាចគិតបានគ្រប់ចំណែកទាំងអស់ ចាំបាច់ត្រូវទូលសួរព្រះសាស្តា ទើបនឹងអស់សង្ស័យ ព្រោះដូច្នោះ ទើប លោកចូលទៅគាល់ព្រះសាស្តាហើយពោលយ៉ាងនោះ ។

បទថា **ព្រហ្មចរិយស្ស** បានដល់ អរិយមគ្គ ។

បទថា **យទិទំ កល្យាណមិត្តតា** សេចក្តីថា ភាពជាអ្នកមានមិត្តល្អដែលបាន រមែងមកកាន់ព្រហ្មចរិយពាក់កណ្តាលអំពីព្រហ្មចរិយពាក់កណ្តាល ។ ដូច្នោះ ព្រះថេរៈទើបពោលថា អរិយមគ្គមានសម្មាទិដ្ឋិជាដើមពាក់កណ្តាល រមែងមកពីភាពជាអ្នកមានមិត្តល្អ, ពាក់កណ្តាលទៀត រមែងមកពីសេចក្តីព្យាយាមចំពោះខ្លួន ។ ក៏ពិតមែន នេះជាសេចក្តីប្រាថ្នារបស់ព្រះថេរៈ ពិតមែនសូម្បីក្នុងទីនេះធម៌ដែលបែងចែកចំណែកមិនបាននេះក៏មិនអាចបែងចែកចំណែកបានថា បណ្តាអរិយមគ្គមានសម្មាទិដ្ឋិជាដើម ប៉ុណ្ណោះកើតអំពីសេចក្តីមានមិត្តល្អ ប៉ុណ្ណោះកើតអំពីសេចក្តីព្យា-

យាមចំពោះខន្ធ ប្រៀបដូចកាលមនុស្សច្រើនអ្នកលើកសសរថ្ម ក៏បែងចែកចំណែកមិនបានថាប៉ុណ្ណោះអ្នកឯណោះលើក ប៉ុណ្ណោះអ្នកឯណោះលើក និងដូចយ៉ាងថា កាលបុត្រអាស្រ័យមាតាបិតាកើតឡើង ក៏បែងចែកចំណែកមិនបានថា កើតអំពីមាតាប៉ុណ្ណោះ កើតអំពីបិតាប៉ុណ្ណោះ ដូច្នោះ ។ ទោះជាយ៉ាងនោះក៏ដោយ ព្រហ្មចរិយឈ្មោះថា ពាក់កណ្ដាល តាមអធ្យាស្រ័យរបស់ព្រះថេរៈថា ព្រោះជាអ្នកមានមិត្តល្អ ក៏បានគុណពាក់កណ្ដាល, ព្រហ្មចរិយឈ្មោះថាទាំងអស់ តាមអធ្យាស្រ័យរបស់ព្រះមានព្រះភាគថាក៏បានគុណទាំងអស់ ។ ក៏ពាក្យថា កល្យាណមិត្តតា នេះលោកកាន់ថា ឈ្មោះថា បានគុណដែលជាចំណែកខាងដើម ពោលដោយសេចក្ដីក៏បានដល់ខន្ធ៤គឺសីលខន្ធសមាធិខន្ធ វិបស្សនាខន្ធដែលអាស្រ័យកល្យាណមិត្តបានមក អាចារ្យពួកខ្លះ ពោលថាសង្ខារក្ខន្ធក៏មាន ។

បទថា មាហេវំ អានន្ទ សេចក្ដីថា កុំនិយាយយ៉ាងនេះលោកជាពហុស្សូតសម្រេចបដិសម្ភិទាចំណែកសេក្ខៈ ទទួលពរ ៨

ប្រការ ហើយឧបដ្ឋាកតថាគត លោកអ្នកប្រកបដោយអច្ឆរិយព្ភូតធម៌ ៤ ប្រការ មិនគួរពោលយ៉ាងនេះដល់បុគ្គល ដូច្នោះ ។

ព្រះមានព្រះភាគត្រាស់ពាក្យនេះថា ម្នាលអានន្ទ ការមានមិត្តល្អជាព្រហ្មចរិយទាំងអស់ដូច្នេះទ្រង់សំដៅថា មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ទាំងអស់ មានមិត្តល្អជាមូលទាំងនោះ ។ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងហេតុ ដោយការថ្លែងព្រះវាចាន្ទុះឯង ទើបត្រាស់ពាក្យថា **កល្យាណមិត្តស្សេតំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **បាដិកង្ខំ** សេចក្ដីថា គប្បីប្រាថ្នា គឺគប្បីប្រាថ្នាថា មាននៅពិត ។

បទថា **ឥធ** ប្រែថា ក្នុងសាសនានេះ ។ មុនដទៃ អាទិបទទាំង ៨ ក្នុងពាក្យថា **សម្មាទិដ្ឋឹ ភាវេតិ** ជាដើម មានពណ៌នាសង្ខេបដូច្នេះ ។ សម្មាទិដ្ឋិមានលក្ខណៈឃើញប្រពៃ សម្មាសង្កប្បៈមានលក្ខណៈលើកសហជាតធម៌ឡើងកាន់អារម្មណ៍ប្រពៃ សម្មាវាចា មានលក្ខណៈកំណត់អារម្មណ៍ប្រពៃ សម្មាកម្មន្តៈ មានលក្ខណៈតាំងខ្លួនទុកប្រពៃ សម្មាអាជីវៈ មានលក្ខណៈធ្វើ

អារម្មណ៍ឱ្យផូរផង់ប្រពៃ សម្មាវាយាមៈ មានលក្ខណៈផ្គងប្រពៃ សម្មាសតិ មានលក្ខណៈប្រាកដប្រពៃ សម្មាសមាធិមានលក្ខណៈតាំងមាំប្រពៃ ។ បណ្ដាមគ្គមានអង្គ៨នោះ មគ្គមួយ ៗ មានកិច្ច ៣ គឺមុនដំបូងសម្មាទិដ្ឋិ រមែងលះមិច្ឆាទិដ្ឋិ ព្រមទឹងពួកកិលេសដែលជាសត្រូវរបស់ខ្លួនយ៉ាងដទៃ ៗ ១ ធ្វើនិរោធឱ្យជាអារម្មណ៍១និងឃើញសម្បយុត្តធម៌ ព្រោះមិនឈ្លក់វង្វេងដោយកម្ចាត់មោហៈដែលបិទបាំងសម្បយុត្តធម៌នោះ១សូម្បីសម្មាសង្កប្បៈជាដើមក៏លះមិច្ឆាសង្កប្បៈជាដើមនិងធ្វើនិរោធឱ្យជាអារម្មណ៍យ៉ាងនោះដូចគ្នាតែដោយចំពោះយ៉ាងក្រៃលែងក្នុងមគ្គមានអង្គ ៨ នោះ សម្មាសង្កប្បៈ រមែងលើកអារម្មណ៍ឡើងកាន់សហជាតធម៌ សម្មាវាចារមែងកំណត់កាន់យកប្រពៃ,សម្មាកម្មន្តៈ រមែងតាំងខ្លួនទុកប្រពៃ, សម្មាអាជីវៈរមែងផូរផង់ប្រពៃ សម្មាវាយាមៈ រមែងផ្គងសេចក្ដីព្យាយាមប្រពៃសម្មាសតិ រមែងតាំងទុកប្រពៃ សម្មាសមាធិ រមែងតាំងមាំប្រពៃ ។

មួយទៀត ធម្មតាសម្មាទិដ្ឋិនេះ ក្នុងចំណែកខាងដើម រមែងមានខណៈផ្សេង ៗ មានអារម្មណ៍ផ្សេង ៗ តែក្នុងខណៈមគ្គចិត្តមានខណៈតែមួយ មានអារម្មណ៍តែមយ៉ាង ។ តែពោលអំពីកិច្ច

រមែងបានឈ្មោះ៤ មាន ទុក្ខេ ញាណំ ដឹងក្នុងទុក្ខដូច្នេះជាដើម សម្មាសង្កប្បៈជាដើម ក្នុងចំណែកខាងដើម ក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា តែក្នុងខណៈនៃមគ្គចិត្ត រមែងមានខណៈតែមួយ មានអារម្មណ៍តែម្យ៉ាង ។ ក្នុងមគ្គមានអង្គ ៨ នេះ សម្មាសង្កប្បៈ ពោលអំពីកិច្ច រមែងបានឈ្មោះ ៣ មាន នេក្ខម្មសង្កប្បៈជាដើម ។ សម្មាវាចាជាដើមរមែងជាវិរតិ ៣ ខ្លះជាចេតនាជាដើមខ្លះ តែក្នុងខណៈនៃមគ្គចិត្ត ក៏ជាវិរតិប៉ុណ្ណោះ ។ សម្មាវាយាមៈនិងសម្មាសតិទាំងពីរដូចពោលមកនេះ ពោលអំពីកិច្ច ក៏បានឈ្មោះ ៤ ដោយសម្មប្បធាន ៤ សតិប្បដ្ឋាន ៤ ។ ចំណែកសម្មាសមាធិ ទាំងក្នុងចំណែកខាងដើម ទាំងក្នុងខណៈនៃមគ្គចិត្ត ក៏សមាធិតែម្យ៉ាង ។ គ្រាជ្រាបការពណ៌នាអាទិបទទាំង ៨ ដែលលោកពោលដោយន័យថា សម្មាទិដ្ឋិ ដូច្នេះជាដើម យ៉ាងនេះមុនហើយ ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងពាក្យថា ភាវេតិ វិវេកនិស្សិតំ ជាដើម ដូច្នេះ ។

បទថា ភាវេតិ ប្រែថា ចម្រើន អធិប្បាយថា ធ្វើឱ្យកើត គឺកើតក្នុងចិត្តសន្តានរបស់ខ្លួន ។

បទថា វិវេកនិស្សិតំ ប្រែថា អាស្រ័យវិវេក ។

បទថា វិវេកោ បានដល់ ភាពជាអ្នកស្ងាត់ ។

គប្បីជ្រាបសេចក្ដីដូច្នេះថា ភាពជាអ្នកស្ងាត់នេះ បានដល់វិវេក ៥ យ៉ាង គឺ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិប-ស្សទ្ធិវិវេក និស្សរណវិវេក ។ វិវេកមាន ៥ យ៉ាងដូច្នេះ ។

បទថា វិវេកនិស្សិតំ ក៏បានដល់ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យតទង្គវិវេក អាស្រ័យសមុច្ឆេទវិវេកនិងអាស្រ័យនិស្សរ-ណវិវេក មួយទៀត ព្រះយោគី ( យោគាវចរ ) អ្នកប្រកបរឿយ ៗ ដែលអរិយមគ្គភាវនានេះ ក្នុងខណៈចម្រើនវិបស្សនា រមែងចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យតទង្គវិវេក ដោយកិច្ចដែលអាស្រ័យនិស្សរណវិវេកដោយអជ្ឈាស្រ័យ តែក្នុងខណៈនៃមគ្គចិត្ត រមែងចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យសមុច្ឆេទវិវេកដោយកិច្ច ដែលអាស្រ័យនិស្សរណវិវេកដោយអារម្មណ៍ ក្នុងបទថា ដែលអាស្រ័យ វិរាគៈជាដើម ក៏ន័យនេះ ។

ក៏វិរាគៈជាដើម ក៏មានវិវេកសេចក្ដីស្ងាត់ជាអត្ថទុំះឯង ក៏

ក្នុងទីនេះតែម្យ៉ាង វោសសគ្គៈមាន២យ៉ាងគឺ បរិចាគវោសសគ្គៈ និងបក្ខន្ទនវោសសគ្គៈ ។

បណ្ដាវោសសគ្គៈ ២ យ៉ាងនោះ ការលះកិលេសដោយអំណាចតទង្គបហាន ក្នុងខណៈចម្រើនវិបស្សនា និងការលះកិលេសដោយអំណាចសមុច្ឆេទបហានក្នុងខណៈនៃមគ្គចិត្តឈ្មោះថាបរិចាគវោសសគ្គៈ ។ ក្នុងខណៈចម្រើនវិបស្សនា ក៏ត្រាច់ទៅកាន់ព្រះនិព្វានជាអ្នកបង្អោនទៅក្នុងព្រះនិព្វាននោះ តែក្នុងខណៈនៃមគ្គចិត្ត ក៏ត្រាច់ទៅកាន់ព្រះនិព្វាន ដោយការធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ ឈ្មោះថា បក្ខន្ទនវោសសគ្គៈ ។ វោសសគ្គៈសូម្បីទាំងពីរនោះ រមែងគួរក្នុងអដ្ឋកថាន័យ ដែលផ្សំទាំងលោកិយៈនិងលោកុត្តរៈនេះ ។ ពិតមែន សម្មាទិដ្ឋិនេះ រមែងលះបង់កិលេស និងត្រាច់ទៅកាន់ព្រះនិព្វាន ដោយប្រការតាមដែលពោលហើយ ដោយពាក្យទាំងអស់នេះថា វោស្សគ្គបរិណាមី លោកអធិប្បាយទុកដូច្នេះថា កំពុងបង្អោនទៅនិងបង្អោនទៅហើយកំពុង បន្ទុំ និងបន្ទុំផ្អិនហើយ ដើម្បីវោសសគ្គៈ ។

ពិតមែន ភិក្ខុដែលប្រកបរឿយ ៗ នូវអរិយមគ្គភាវនានេះ

រមែងចម្រើនសម្មាទិដ្ឋិដោយអាការដែលសម្មាទិដ្ឋិនោះ កំពុងបន្ទំ ដើម្បីវោសសគ្គៈ គឺការលះបង់កិលេស និងដើម្បីវោសគ្គៈ គឺការត្រាច់ទៅកាន់ព្រះនិព្វាន និងដោយអាការដែលសម្មាទិដ្ឋិនោះបន្ទំទុំហើយ ។ ក្នុងអដ្ឋមគ្គដែលសល់ក៏ន័យនេះ ។

បទថា អាគម្ម បានដល់ ប្រារព្ធសំដៅដល់ អាស្រ័យហើយ ។

បទថា ជាតិធម្មា បានដល់ មានការកើតជាសភាវៈគឺ មានការកើតជាប្រក្រតី ( ធម្មតា ) ។

បទថា តស្មា សេចក្ដីថា ព្រោះហេតុដែលសូម្បីអរិយមគ្គទាំងអស់អាស្រ័យកល្យាណមិត្តទើបបាន ដូច្នោះស័ព្ទថា ហន្ទជានិបាតចុះក្នុងអត្ថថា គោរពអញ្ជើញ ។

បទថា អប្បមាទំ បសំសន្តិ បានដល់ បណ្ឌិតទាំងឡាយរមែងសរសើរសេចក្ដីមិនប្រមាទ ព្រោះដូច្នោះ ទើបគួរធ្វើសេចក្ដីមិនប្រមាទ ។

បទថា អត្ថាភិសមយា ប្រែថា ព្រោះបានប្រយោជន៍ ។

# សត្តិសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ៤៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងអំពី [**ការចូលទៅសេពគប់ជាមួយសប្បុរស**] មានសេចក្ដីថា ៖

ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

គ្រានោះឯង កាលរាត្រីបឋមយាមកន្លងទៅហើយមានពួកតុល្លប្បកាយិកាទេវតាជាច្រើន មានរស្មីរុងរឿងញ៉ាំងវត្តជេតពនទាំងមូលឱ្យភ្លឺរុងរឿងចូលទៅគាល់ព្រះមានព្រះភាគលុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

**លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖**

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំសទ្ធម្មមញ្ញាយ សេយ្យោ ហោតិន បាបិយោ ។

បុគ្គលគួរអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរសរមែងបានជាបុគ្គលប្រសើរ មិនអាក្រក់ឡើយ ។

**លំដាប់នោះឯង ទេវតាមួយអង្គទៀតបានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖**

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ បញ្ញំ លភតិ នាញ្ញតោ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលបានប្រាជ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនបានអំពីទីដទៃឡើយ ។

**លំដាប់នោះឯង ទេវតាមួយអង្គទៀត ពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖**

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំសទ្ធម្ម មញ្ញាយបញ្ញំ លភតិ នាញ្ញតោ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលបានដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងមិនសោកសៅក្នុងកណ្តាលពួកជនអ្នកសោកសៅឡើយ ។

លំដាប់នោះទេវតាមួយអង្គទៀត ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះគួរធ្វើសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរុងរឿងក្នុងកណ្តាលនៃញាតិ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតិំ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរសហើយរមែងទៅកាន់សុគតិបាន ។

លំដាប់នោះឯងទេវតាមួយទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាតតំ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស សត្វទាំងឡាយដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងឋិតនៅជាសុខអស់កាលយូរ ។

លំដាប់នោះឯងទេវតាមួយអង្គទៀត បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគភាសិតអ្នកណាហ្ន៎ ជាសុភាសិត ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ភាសិតរបស់អ្នកទាំងអស់ជាសុភាសិតដោយបរិយាយដែរហើយ តែអ្នកទាំងឡាយចូរស្ដាប់

ពាក្យរបស់តថាគតវិញថា ៖

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរស រមែងរួចចាកទុក្ខទាំងអស់បាន ។

## អដ្ឋកថា

បទថា សតុល្លបកាយិកា មានវិគ្រោះថា ទេវតាទាំងឡាយដែលឈ្មោះថា **សតុល្លបកាយិកា** ព្រោះលើកតម្កើង ដោយអំណាចនៃការសមាទានធម៌របស់សប្បុរសហើយ កើតឡើងក្នុងសួគ៌ ។ ក្នុងសេចក្ដីនោះ មានរឿងដូចតទៅនេះ ៖

## រឿងអ្នកសរសើរធម៌សប្បុរស

បានឮថា ជនច្រើននាក់បានធ្វើការលក់ដូរតាមសមុទ្រ ប្រើទូកទៅកាន់សមុទ្រ ។ កាលទូកនៃជនទាំងនោះទៅដោយរហ័សដូចកូនធ្នូដែលបុគ្គលបោះទៅហើយក្នុងថ្ងៃទី ៧ ទើបកើតហេតុ

ប្រទូស្តធំត្រង់កណ្តាលសមុទ្រគឺរលកធំតាំងឡើង ហើយក៏ញ៉ាំងទូកឱ្យពេញទៅដោយទឹក ។ កាលទូកកំពុងនឹងលិចចុះ មហាជនទើបនឹកដល់ ឈ្មោះទេវតារបស់ខ្លួន ៗ ហើយធ្វើកិច្ចដែលមានការអង្វរជាដើម ទួញយំហើយ ។ នៅកណ្តាលនៃជនទាំងនោះ បុរសម្នាក់នឹកថា យើងត្រូវប្រសព្វភ័យដ៏សាហាវបែបនេះពិត ទើបនឹកដល់ធម៌របស់ខ្លួនឃើញ ហើយនូវសរណៈទាំងឡាយ និងសីលទាំងឡាយក៏បរិសុទ្ធិហើយ ទើបអង្គុយចម្រើនសមាធិដូចព្រះយោគី ។ ពួកជនទាំងឡាយទើបសួរគាត់ដល់ហេតុដែលមិនខ្លាចនោះ ។ បុរសជាបណ្ឌិតនោះទើបពោលថា "ម្នាលលោកដ៏ចម្រើនទាំងឡាយ មែនហើយយើងមិនខ្លាចភ័យបែបនេះ ព្រោះយើងថ្វាយទានដល់ពួកភិក្ខុក្នុងថ្ងៃដែលឡើងទូក យើងបានទទួលសរណៈទាំងឡាយ និងសីលទាំងឡាយ ព្រោះហេតុនោះ យើងទើបមិនខ្លាច"ដូច្នេះ ។ ជនទាំងនោះទើបពោលថា "បពិត្រលោកដ៏ចម្រើនក៏សរណៈ និងសីលទាំងនេះសមគួរដល់ជនពួកដទៃខ្លះឬទេ" ។ បណ្ឌិតនោះ ឆ្លើយថា "មែនហើយ ធម៌ទាំងនេះរមែងសមគួរសូម្បីដល់ពួកលោក" ។ ជនទាំងនោះទើបពោលថា "បើយ៉ាងនោះសូម

លោកបណ្ឌិត ចូរឱ្យដល់ពួកយើងខ្លះ” ។

ជនអ្នកជាបណ្ឌិតនោះ ទើបចាត់ធ្វើពួកមនុស្សទាំងនោះឱ្យជាពួកមួយរយ ៗ រួមជា ៧ ពួករួមគ្នា ។ បន្ទាប់ពីនោះក៏ឱ្យសីល ៥ ។ ក្នុងបណ្ដាជន៧ ទាំងនោះ ជនចំនួនមួយរយនាក់ដំបូងតាំងនៅក្នុងទឹកត្រឹមកជើង ទើបបានទទួលសីល ។ ពួកទី ២ តាំងនៅក្នុងទឹកត្រឹមជង្គង់... ពួកទី ៣ តាំងនៅក្នុងទឹកត្រឹមចង្កេះ... ពួកទី ៤ តាំងនៅក្នុងទឹកត្រឹមផ្ចិត...ជនពួកទី ៥តាំងនៅក្នុងទឹកត្រឹមដោះ... ពួកទី៦ តាំងនៅក្នុងទឹកត្រឹមក...ពួកទី៧ ទឹកសមុទ្រកំពុងនឹងហូរចូលមាត់ ទើបបានទទួលសីល ៥ ហើយ ។ ជនជាបណ្ឌិតនោះ គ្រាឱ្យសីល ៥ ដល់ជនទាំងនោះហើយ ទើបប្រកាសសំឡេងគឹកកងថា វត្ថុដទៃជាទីពឹងចំពោះរបស់ពួកលោក មិនមាន ពួកលោកចូររក្សាសីលប៉ុណ្ណោះ ដូច្នេះ ។ ជនទាំង៧០០ នាក់នោះ ធ្វើកាលៈក្នុងសមុទ្រនោះហើយ ទៅកើតឡើងក្នុងភពតាវត្តិង្ស ព្រោះអាស្រ័យសីលដែលខ្លួនទទួលយកក្នុងវេលាជិតស្លាប់ ។ វិមានទាំងឡាយរបស់ទេវតាទាំងនោះ ក៏កើតឡើងជាពួកតែមួយ ។ វិមានមាសរបស់អាចារ្យ មានប្រមាណមួយរយយោជន៍ កើតនៅត្រង់

កណ្តាលនៃវិមានទាំងអស់ ។ ទេវតាដែលសល់ ជាបរិវាររបស់ទេវដែលជាអាចារ្យនោះ វិមានដែលទាបជាង វិមានទាំងអស់នោះក៏នៅ មាន ប្រមាណដល់ ១២ យោជន៍ ។ ទេវតាទាំងនោះ បានពិចារណាផលកម្មក្នុងខណៈដែលខ្លួនកើតហើយ ជ្រាបហើយនូវការបានសម្បត្តិ នោះ ព្រោះអាស្រ័យអាចារ្យ ទើបពោលគ្នាថា ពួកយើងនឹងទៅ ពួកយើងនឹងពោលសរសើរគុណនៃអាចារ្យរបស់ពួកយើងក្នុងសំណាក់ នៃព្រះទសពលដូច្នេះ ហើយចូលទៅគាល់ព្រះមានព្រះភាគក្នុងវេលាចន្លោះមជ្ឈិមយាម ។

ក្នុងបណ្តាទេវតាទាំងនោះ ទេវតា ៦ អង្គ បានពោលគាថាមួយអង្គមួយគាថា ដើម្បីពណ៌នាគុណអាចារ្យរបស់ខ្លួនដោយពាក្យថា ៖

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស គួរធ្វើសេចក្តីស្និទ្ធនឹងពួកសប្បុរស បុគ្គលជ្រាបព្រះសទ្ធម្មរបស់ពួកសប្បុរស ហើយមានតែគុណដ៏ប្រសើរមិនមានទោសលាមកឡើយ ។

បណ្តាបទទាំងនោះ បទថា សត្ថិ ប្រែថា ពួកបណ្ឌិតគឺ ពួកសប្បុរស ។ រ អក្សរធ្វើនាទីសន្ធិ ។

បទថា សមាសេថ ប្រែថា គួរអន្តុយរួមក៏ពាក្យថា សមា-សេថ នេះ ជាគោលនៃទេសនាប៉ុណ្ណោះ ។ អធិប្បាយថា គប្បីសម្រេចឥរិយាបថទាំងពួងរួមនឹងសប្បុរសទាំងឡាយតែម្តង ។

បទថា កុព្វេថ ប្រែថា គួរធ្វើ ។

បទថា សន្ថវំ ប្រែថា សេចក្តីស្និទ្ធ បានដល់ សេចក្តីស្និទ្ធដោយមេត្រី តែសេចក្តីស្និទ្ធដោយតណ្ហាដែលអ្នកណា ៗ មិនគួរធ្វើ ។ សេចក្តីនេះ ព្រះមានព្រះភាគត្រាស់សំដៅយកពាក្យថា បុគ្គលគប្បីធ្វើសេចក្តីស្និទ្ធ មេត្រីចំពោះព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះសាវកទាំងឡាយ ដូច្នេះ ។

បទថា សតំ ប្រែថា របស់ពួកសប្បុរស ។

បទថា សទ្ធម្មំ បានដល់ សទ្ធម្មផ្សេង ៗមានសីល ៥ សីល ១០និងសតិប្បដ្ឋាន ៤ជាដើម ។ តែក្នុងសូត្រនេះ លោកប្រាថ្នាយកសីល ៥ ។

បទថា សេយ្យោហោតិ ប្រែថា មានតែគុណដ៏ប្រសើរ គឺមានតែសេចក្ដីចម្រើន ។

បទថា ន បាបិយោ បានដល់ សេចក្ដីលាមក( សេចក្ដីក្រោមឃើត )អ្វី ៗ រមែងមិនមាន ។

លំដាប់នោះ ទេវតាដទៃទៀតបានពោលគាថានេះក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស ។ល ។ រមែងបានបញ្ញាមិនបានបញ្ញាពីអ្នកដទៃ ( ជនពាល )ទេដូច្នេះ ។

បទថា នាញ្ញតោ ប្រែថា មិនបានពីអ្នកដទៃទេ គឺឈ្មោះថាបញ្ញា ដែលបុគ្គលមិនបានពីអ្នកដទៃជាពាល ដូចប្រេងល្ងជាដើម ដែលបុគ្គលមិនគប្បីបានដោយគ្រួស ខ្សាច់ ជាដើម ។ ក៏បុគ្គលជ្រាបធម៌របស់សប្បុរសទាំងឡាយ ហើយសេពគប់រកនូវបណ្ឌិតប៉ុណ្ណោះ ទើបបានបញ្ញាដូចប្រេងទាំងឡាយ មានប្រេងល្ង ជាដើម ដែលបុគ្គលបានដោយគ្រាប់ល្ង ជាដើម ។

លំដាប់នោះឯង ទេវតាដទៃទៀតបានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស ។ល ។ រមែងមិនសោកសៅត្រង់កណ្ដាលនៃរឿងដែលជា

ទីតាំងនៃសេចក្ដីសោកសៅ ដូច្នេះ ។

បទថា សោកមជ្ឈេ អធិប្បាយថា បុគ្គលដែលទៅហើយត្រង់កណ្ដាលនៃរឿងដែលជាទីតាំងនៃសេចក្ដីសោកសៅ ឬថា ទៅហើយត្រង់កណ្ដាលនៃសត្វទាំងឡាយ ដែលមានសេចក្ដីសោកសៅ ដូចឧបាសិកា (មល្លិកា)របស់ពន្ធុលសេនាបតី និងដូចសង្កិច្ចសាមណេរអ្នកជាសទ្ធិវិហារិក របស់ព្រះធម្មសេនាបតី អ្នកទៅត្រង់កណ្ដាលនៃចោរ ៥០០ រមែងមិនសោកសៅ ។

លំដាប់នោះឯង ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស ។ល ។ រមែងរុងរឿងនៅកណ្ដាលនៃញាតិដូច្នេះ ។

បទថា ញាតិមជ្ឈេ វិរោចតិ ប្រែថា រមែងរុងរឿងនៅកណ្ដាលនៃពួកញាតិ គឺថា រមែងល្អដូចសាមណេរឈ្មោះថា អធិមុត្តកៈ អ្នកជាសទ្ធិវិហារិករបស់ព្រះសង្កិច្ចត្ថេរ ។

## រឿងអធិមុត្តកៈសាមណេរ

បានឮថា សាមណេរនោះជាក្មួយរបស់ព្រះសង្កិច្ចត្ថេរនោះ ។ ក្នុងកាលគ្រានោះ ព្រះថេរៈពោលនឹងសាមណេរថា ម្នាលសាម-

ណេរ លោកជាអ្នកធំហើយ លោកចូរទៅសួរដល់អាយុរបស់លោកហើយ ចូរមកយើងនឹងឧបសម្បទាឱ្យដូច្នេះ សាមណេរទទួលពាក្យថា ល្អហើយករុណា សំពះព្រះថេរៈហើយកាន់បាត្រនិងចីវរទៅស្រុកប្អូនស្រី ដែលតាំងនៅជិតព្រៃដែលជាទីអាស្រ័យនៅរបស់ពួកចោរ ហើយត្រាច់ទៅបិណ្ឌបាត ។ ប្អូនស្រីឃើញលោកហើយសំពះហើយ ទើបនិមន្តឱ្យទៅអង្គុយក្នុងស្រុក ឱ្យឆាន់ភត្តាហារហើយ ។ សាមណេរធ្វើកិច្ចវត្តរួចស្រេចហើយ ទើបសួរដល់អាយុរបស់ខ្លួន ។ នាងឆ្លើយថា ខ្ញុំម្ចាស់មិនជ្រាប ម្ដាយរមែងជ្រាប ។ សាមណេរពោលថា នាងចូរនៅត្រង់នេះ យើងនឹងទៅស្រុកញោមមាតា ហើយក៏ឈានចូលទៅកាន់ព្រៃ ។ បុរសជាចោរឃើញសាមណេរពីចម្ងាយ ទើបបញ្ជូនសញ្ញាដល់ពួកចោរ ។ ពួកចោរឱ្យសញ្ញាណដោយពាក្យថា បានឮថាសាមណេរមួយអង្គចូលក្នុងព្រៃពួកលោកចូរទៅនាំសាមណេរនោះមកដូច្នេះ ។ ចោរពួកខ្លះពោលថាយើងនឹងសម្លាប់ពួកខ្លះពោលថាយើងនឹងលែង ។ សូម្បីសាមណេរក៏គិតថា យើងជាព្រះសេក្ខៈនៅមានកិច្ចដែលគួរធ្វើដល់ខ្លួន យើងប្រឹក្សានឹងពួកចោរទាំងនេះហើយនឹង ធ្វើសេចក្ដី

សួស្តីជាប្រមាណ ទើបហៅប្រធានចោរមកពោលថា ម្នាល លោកអ្នកមានអាយុ យើងនឹងធ្វើសេចក្តីឧបមា ( ប្រៀបធៀប ) ដល់លោកដូច្នេះ ហើយបានពោលគាថាទាំងនេះថា ៖

ក្នុងអតីតកាលដ៏យូរអង្វែង ដែលពួកឈើក្នុងព្រៃធំ ខ្លា ដំបងមួយគ្រាប់ស្ទាក់ចាប់ចំណីតាមផ្លូវកោង ក្នុងកាលនោះ វាបានសម្លាប់សត្វទន្សាយមួយ ម្រឹគ និង បក្សីទាំងឡាយឃើញទន្សាយស្លាប់ហើយ ស្លុតចិត្តខ្លាច នាំគ្នាគេចជៀសទៅក្នុងវេលារាត្រី ទើបមិនកើតប្រយោជន៍ដល់វាយ៉ាងណា លោកសម្លាប់សមណៈឈ្មោះ អធិមុត្តកអ្នកមិនមានកិលេសជាគ្រឿងកង្វល់ចិត្ត ក៏ដូចគ្នានោះឯង ជនទាំងឡាយអ្នកធ្វើដំណើរនឹងមិនមក ពួកលោក ក៏នឹងដាច់ទ្រព្យ សមណៈឈ្មោះថា អធិមុត្តកៈអ្នកមិនមានកិលេស គ្រឿងកង្វល់ចិត្តពោល ពាក្យពិតប្រាកដ ជនទាំងឡាយអ្នកធ្វើដំណើរនឹងមិនមកសេចក្តីសាបសូន្យនៃទ្រព្យនឹងមាន ។

នាយចោរពោលថា **បើលោកឃើញអ្នកធ្វើដំណើរមក ហើយនឹងមិនប្រាប់ដល់អ្នកណា ៗ បពិត្រលោកដ៏ចម្រើន កាលលោកតាមរក្សាសច្ចៈនេះបាន ក៏ចូរទៅតាមសប្បាយចុះ ។**

សាមណេរនោះ អ្នកដែលពួកចោរទាំងនោះដោះលែងទៅ សូម្បីឃើញញាតិទាំងឡាយក៏មិនបានប្រាប់ ពេលនោះ កាល ញាតិរបស់សាមណេរនោះមកដល់ហើយ ពួកចោរក៏បាននាំគ្នា ចាប់ ហើយពួកចោរបានពោលនឹងមាតារបស់សាមណេរដែល នាងកំពុងខូចចិត្ត គត់ទ្រូង ទួញយំថា ៖

**អធិមុត្តកៈ នឹងសួរលោកថា អធិមុត្តកៈឥឡូវនេះ មាន កាលភ្លៀងប៉ុន្មានមេ ខ្ញុំសួរហើយសូមប្រាប់ពួកយើង ៗ នឹងដឹង បានយ៉ាងណា ។**

មាតារបស់អធិមុត្តកៈពោលនឹងពួកចោរថា ៖

**យើងនេះឯងជាមាតារបស់អធិមុត្តក អ្នកនេះឯងជាបិតា អ្នកនេះជាប្អូនស្រី អ្នកនេះជាបងប្អូនប្រុស ជនទាំងអស់ក្នុងទីនេះ ជាញាតិរបស់អធិមុត្តកៈ ។ អធិមុត្តកៈមានប្រក្រតីធ្វើកិច្ចដែលមិន សមគួរឡើយ ឃើញញាតិអ្នកណាមកហើយក៏មិនហាមនេះជាវត្ត បដិបត្តិរបស់សមណៈទាំងឡាយ អ្នកជាព្រះអរិយៈអ្នកមានធម៌ ជាជីវិតឬហ្ន៎ ។**

នាយចោរពោលថា ៖

អធិមុត្តកៈមានប្រក្រតីពោលពាក្យពិត ឃើញញាតិ អ្នកណា ហើយក៏មិនហាម ព្រោះសេចក្តីប្រព្រឹត្តល្អរបស់អធិមុត្តកៈអ្នកជាភិក្ខុ អ្នកមានប្រក្រតីពោលពាក្យពិត ។ ជនទាំងអស់អ្នកជាញាតិ របស់អធិមុត្តកៈរួចផុតភ័យហើយ សូមទៅកាន់សេចក្តីសួស្តីចុះ ។

ញាតិទាំងនោះ ដែលចោរទាំងឡាយដោះលែងឱ្យរួច ខ្លួនហើយដោយអាការយ៉ាងនេះទៅហើយពោលនឹងអធិមុត្តកៈថាកូនជនទាំងអស់រួចផុតភ័យហើយ ត្រឡប់មកកាន់សេចក្តីសួស្តី ព្រោះការប្រព្រឹត្តល្អរបស់លោកជាភិក្ខុដែលពោលវាចាសត្យៈ ។

ពួកចោរទាំង៥វរយជ្រះថ្លាហើយ ទើបសូមបួសក្នុងសំណាក់របស់សាមណេរឈ្មោះ អធិមុត្តកៈ ។ សាមណេរទើបនាំសិស្សទាំងនោះទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ហើយ ខ្លួនក៏ឧបសម្បទាមុនខាងក្រោយទើបធ្វើការឧបសម្បទឱ្យអន្តេវាសិករបស់ខ្លួន មានប្រមាណ ៥០០ ទាំងនោះ ។ អន្តេវាសិកទាំងអស់នោះតាំងនៅក្នុងឱវាទរបស់អធិមុត្តកត្ថេរហើយ ក៏សម្រេចនូវព្រះអរហត្តមានផលដ៏ប្រសើរ ដូច្នេះ ។ ទេវតាកាន់យកសេចក្តីនេះហើយ ក្រាប

ទូលព្រះមានព្រះភាគថា សតំសទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោ-ចតិ ប្រែថា បុគ្គលដឹងសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងរុងរឿងនៅកណ្តាលនៃញាតិ ដូច្នេះ ។

ក្នុងលំដាប់នោះឯង ទេវតាដទៃទៀត បានពោលគាថា នេះក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស ។ល ។ រមែងតាំងនៅសប្បាយរឿយ ៗ ។

ពាក្យថា សាតតំ នេះ ប្រែថា រឿយ ៗគឺទេវតារមែងពោលថា ជនទាំងឡាយរមែងតាំងនៅសប្បាយរឿយ ៗ ឬថាមានសេចក្តីសុខដែលយឺនយូរ ។

លំដាប់នោះឯង ទេវតាដទៃទៀតបានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគពាក្យរបស់អ្នកណាហ្ន៎ជាសុភាសិត ។

ព្រះមានព្រះភាគត្រាស់ថា ពាក្យរបស់ពួកលោកទាំងអស់ជាសុភាសិតដោយបរិយាយ ក៏ប៉ុន្តែពួកលោកចូរស្តាប់ពាក្យរបស់យើងខ្លះថា ៖

បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលជ្រាបសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងផុតពីទុក្ខទាំងពួង ។

បទថា សព្វាសំ វោ ប្រែថា របស់ពួកលោកទាំងអស់ ។

បទថា បរិយាយេន បានដល់ ដោយការណៈ ។

បទថា សព្វទុក្ខា បមុចតិ ប្រែថា រមែងផុតពីទុក្ខទាំងពួង អធិប្បាយថា មិនមែនមានហេតុពីគុណដ៏ប្រសើរតែម៉្យាងប៉ុណ្ណោះ រមែងមិនបានបញ្ញាតែម៉្យាង រមែងមិនសោកសៅនៅកណ្ដាលនៃរឿងជាទីតាំងនៃសេចក្ដីសោកតែម៉្យាង រមែងរុងរឿងនៅកណ្ដាលនៃញាតិ... រមែងកើតក្នុងសុគតិ... រមែងតាំងនៅសប្បាយអស់កាលយូរតែម៉្យាង ក៏បុគ្គលនោះឯង រមែងផុតស្ទើរអំពីវដ្ដទុក្ខទាំងអស់ ដូច្នេះឯង ។

## សារីបុត្តសូត្រ

នៅក្នុងបិដកលេខ ៣៧, ទំព័រ ៦ ព្រះអង្គទ្រង់ត្រាស់នូវ [**ភាពជាអ្នកមានមិត្តល្អ**] ដោយមានសេចក្ដីថា ៖

សារត្ថិនិទាន ។ គ្រានោះព្រះសារីបុត្រដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន នេះជាព្រហ្មចរិយធម៌ទាំងមូលគឺការមានមិត្តល្អ ការមានសំឡាញ់ល្អ នឹងការមានក្លើល្អ ។

៤. ម្នាលសារីបុត្រ ប្រពៃណាស់ហើយ ម្នាលសារីបុត្រនេះហើយជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ មានសំឡាញ់ល្អ នឹងការមានក្លើល្អ ។ ម្នាលសារីបុត្រ ព្រហ្មចរិយធម៌នេះប្រាកដដល់ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានក្លើល្អ នឹងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

៥. ម្នាលសារីបុត្រ ចុះភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានក្លើល្អ តែងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។

៦. ម្នាលសារីបុត្រ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ

ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ (ចម្រើននូវសម្មាសង្កប្បៈ... ចម្រើននូវសម្មាវាចា... ចម្រើននូវសម្មាកម្មន្ត... ចម្រើននូវសម្មាអាជីវៈ... ចម្រើននូវសម្មាវាយាម...ចម្រើននូវសម្មាសតិ...) ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្ដីស្ងបស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយអាស្រ័យនូវសេចក្ដីរលត់មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលសារីបុត្រ ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានក្លើល្អ តែងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

ម្នាលសារីបុត្រ អ្នកគប្បីដឹងនូវសេចក្ដីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានក្លើល្អ ។ ម្នាលសារីបុត្រ ព្រោះអាស្រ័យនូវតថាគតជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា

រូបស្រឡះចាកមរណៈទៅបានពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្តនឹងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្តនឹងសេចក្តីចង្អៀតចង្អល់ទៅបាន ។ ម្នាលសារីបុត្រ អ្នកគប្បីដឹងសេចក្តីនុ៎ះដោយបរិយាយនេះចុះថា នេះហើយជាព្រហ្មចរិយធម៌ទាំងមូល គឺ ការមានមិត្តល្អ ការមានសំឡាញ់ល្អ នឹងការមានក្បែរល្អ ។

## អដ្ឋកថា

បទថា សកលមិទំ ភន្តេ សេចក្តីថា ព្រះអានន្ទត្ថេរមិនដឹងថា មគ្គព្រហ្មចរិយសូម្បីទាំងអស់ ដែលខ្លួនបាន ព្រោះអាស្រ័យកល្យាណមិត្រដូច្នេះ ព្រោះនៅមិនទាន់ដល់ទីបំផុតនៃសាវកបារមី-ញាណ ។ ចំណែកព្រះធម្មសេនាបតីបានដឹងហើយ ព្រោះតាំងនៅក្នុងទីបំផុតនៃសាវកបារមីញាណ ។ ព្រោះដូច្នោះ ទើបលោកក្រាបទូលយ៉ាងនេះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគបានប្រទានសាធុការដល់ព្រះថេរៈនោះថា **សាធុ សាធុ** ដូច្នេះ ។

# កល្យាណមិត្តតាទិវគ្គទី៨

នៅក្នុងបិដកលេខ ៤០, ទំព័រ ២៦ ព្រះអង្គទ្រង់ត្រាស់នូវ [ភាពជាអ្នកមានកល្យាណមិត្ត ជាហេតុឱ្យកុសលធម៌កើតឡើងជាដើម] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ១ ដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើងឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឱ្យសាបសូន្យទៅក្តី ដូចការមានកល្យាណមិត្ត នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានកល្យាណមិត្ត ពួកអកុសលធម៌ ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

បទថា **កល្យាណមិត្តតា** សេចក្តីថា ឈ្មោះថា កល្យាណ-មិត្ត ព្រោះមានមិត្តល្អ ភាវៈនៃបុគ្គលជាអ្នកមានមិត្តនោះ ឈ្មោះថា **កល្យាណមិត្តតា** សេចក្តីជាអ្នកមានមិត្តល្អ ។

# រឿងនាងចូឡសុភទ្ទា

នៅក្នុងអដ្ឋកថាលេខ ៤៣, ទំព័ ១៨២ ព្រះអង្គទ្រង់ត្រាស់នូវ [**អំពីការអានិសង្សនៃការសេពគប់បណ្ឌិត**]មានសេចក្ដីថា

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធីតារបស់អនាថបិណ្ឌិកសេដ្ឋី ឈ្មោះចូឡសុភទ្ទា ត្រាស់ព្រះធម៌ទេសនានេះថា "ទូរេ សន្តោ បកាសេន្តិ" ជាដើម ។

## [សេដ្ឋីពីរនាក់ធ្វើកតិកាចំពោះគ្នា]

បានឮមកថា សេដ្ឋីបុត្រឈ្មោះឧគ្គៈ អ្នកស្រុកឧគ្គនគរជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី តាំងពីវេលាដែលនៅជាកម្លោះ ។

សម្លាញ់ទាំងពីរនោះ រៀនសិល្បៈនៅក្នុងត្រកូលអាចារ្យជាមួយគ្នា ធ្វើកតិកាចំពោះគ្នាថា ក្នុងវេលាដែលយើងទាំងពីរចម្រើនវ័យ កាលបុត្រនិងធីតាកើតហើយ អ្នកណាសូមធីតាដើម្បីប្រយោជន៍ដល់បុត្រ អ្នកនោះត្រូវឱ្យធីតាដល់អ្នកនោះ គេទាំងពីរចម្រើនវ័យហើយ តាំងនៅក្នុងតំណែងសេដ្ឋីក្នុងនគររបស់ខ្លួន ៗ ។ សម័យមួយ ឧគ្គសេដ្ឋីប្រកបការធ្វើជំនួញ បានទៅកាន់

ក្រុងសាវត្ថីដោយរទេះ ៥០០ ។ អនាថបិណ្ឌិកសេដ្ឋី ហៅនាងចូឡសុភទ្ទាធីតារបស់ខ្លួនមកបង្គាប់ថា "មេ បិតារបស់អ្នកឯងឈ្មោះឧគ្គសេដ្ឋីមកហើយ, កិច្ចដែលគួរធ្វើដល់បិតា ចូរជាភារៈរបស់កូន" ។

## [ឧគ្គសេដ្ឋីសូមចូឡសុភទ្ទាដើម្បីបុត្រ]

នាងទទួលថា "ល្អណាស់" ទើបចាត់កោជនមានសម្លរ និងម្ហូបក្រៀមជាដើម ដោយដៃរបស់ខ្លួនឯង ចាប់តាំងពីថ្ងៃឧគ្គសេដ្ឋីនោះមក, ត្រៀមវត្ថុផ្សេង ៗមានរបៀបផ្កាឈើ របស់ក្រអូបនិងគ្រឿងលាបស្រឡាបជាដើមទុក, ក្នុងវេលាបរិភោគ ក៏ចាត់ទឹកសម្រាប់ងូតទុក ( រង់ចាំ )លោកសេដ្ឋីនោះ តាំងពីវេលាងូតទឹកទៅរមែងធ្វើកិច្ចគ្រប់យ៉ាងសម្រេចរៀបរយ ឧគ្គសេដ្ឋីឃើញអាចារៈសម្បត្តិរបស់នាងសុភទ្ទានោះហើយ មានចិត្តជ្រះថ្លាក្នុងថ្ងៃមួយអង្គុយជាមួយអនាថបិណ្ឌិកសេដ្ឋី ដោយកថាប្រារព្ធសេចក្ដីសុខហើយ នឹកបានថា"ក្នុងវេលានៅជាកម្លោះ យើងទាំងពីរធ្វើកតិកាឈ្មោះយ៉ាងនេះទុកហើយ" ទើបសូមនាងចូឡសុភទ្ទា ដើម្បី

ប្រយោជន៍ដល់បុត្ររបស់ខ្លួន ៗ តែឧគ្គសេដ្ឋីនោះដោយប្រក្រតីជាមិច្ឆាទិដ្ឋិ ព្រោះដូច្នោះ អនាថបិណ្ឌិកសេដ្ឋីទើបក្រាបទូលសេចក្តីនោះចំពោះព្រះទសពល ដែលព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់ឧគ្គសេដ្ឋី ហើយទ្រង់អនុញ្ញាត សេដ្ឋីទើបប្រឹក្សានិងភរិយាហើយទទួលពាក្យរបស់ឧគ្គសេដ្ឋីនោះ កំណត់ថ្ងៃ ( តែងការងារ ) ហើយធ្វើសក្ការៈជាច្រើនដូចយ៉ាងធនញ្ជ័យសេដ្ឋីធ្វើឱ្យនាងវិសា-ខាជាធីតា ហើយបញ្ជូនទៅដូច្នោះ, ហៅនាងសុភទ្ទាមកហើយ ឱ្យឱវាទ ១០ ប្រការជាដើមថា " ធម្មតាស្ត្រីអ្នកនៅក្នុងត្រកូលឪពុកក្មេក មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ" តាមន័យដូចដែលធនញ្ជ័យសេដ្ឋីឱ្យដល់នាងវិសាខាទុំ៎ះឯងកាលនឹងបញ្ជូនទៅចាត់កុដុម្ពី ៨ នាក់ឱ្យជាអ្នកទទួលខុសត្រូវថា "បើទោសរបស់ធីតាខ្ញុំកើតឡើងក្នុងទីទៅហើយ,ពួកលោកត្រូវជម្រះ"ក្នុងថ្ងៃជាទីបញ្ជូនធីតានោះទៅថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រមុខ, ហើយបញ្ជូនធីតាទៅដោយសក្ការៈជាច្រើន ដូចជានឹងសម្តែងសេចក្តីចម្រើននៃផលសុចរិតទាំងឡាយ ដែលធីតាធ្វើទុកហើយក្នុងកាលមុនឱ្យប្រាកដដល់សត្វលោក ៗ ក្នុងវេលាដែលនាងទៅ

ដល់ឧត្តនគរដោយលំដាប់ មហាជនព្រមទាំងត្រកូលឪពុកក្មេក បានធ្វើការទទួល ។ អន្តុយសន្ទនាគ្នាតាមសប្បាយនឹងអនាថ-បិណ្ឌិកសេដ្ឋី ។

ចំណែកនាងចូឡសុភទ្ទានោះ សម្តែងខ្លួនចំពោះអ្នកនគរទាំងអស់ ដូចនាងវិសាខា ដើម្បីធ្វើសិរីសម្បត្តិរបស់ខ្លួនឱ្យប្រាកដ ឈរលើរថចូលទៅកាន់នគរ ទទួលគ្រឿងបណ្ណាការដែលអ្នកនគរបញ្ជូនមកហើយ បញ្ជូនតបទៅដល់ជនពួកនោះ ៗ ដោយអំណាចនៃវត្តតាមសមគួរ បានធ្វើអ្នកនគរទាំងអស់ ឱ្យជាប់ជាការតែមួយនឹងដោយគុណរបស់ខ្លួន ។

## [ឪពុកក្មេកឱ្យនាងចូឡសុភទ្ទាសំពះអ្នកបួសអាក្រាត]

ក៏ក្នុងថ្ងៃមង្គលជាដើម ឪពុកក្មេករបស់នាង កាលនឹងធ្វើសក្ការៈដល់ពួកអ្នកបួសអាក្រាត បញ្ជូនទៅដោយពាក្យថា "នាងចូរមកសំពះព្រះសមណៈទាំងឡាយរបស់ពួកយើង" ។ នាងមិនអាចដើម្បីនឹងមើលអ្នកបួសអាក្រាតទាំងឡាយ ព្រោះខ្មាស មិនប្រាថ្នានឹងទៅ ។ ឪពុកក្មេកនោះសូម្បីបញ្ជូនដំណឹងទៅរឿយ ៗ

ត្រូវនាងហាមហើយ ទើបក្រោធនិយាយថា ពួកលោកចូរបណ្ដេញវាចេញទៅ ។ នាងគិតថា ឪពុកក្មេកមិនអាចលើកទោសដល់យើង ព្រោះហេតុមិនសមគួរបាន ឱ្យគេហៅកុដុម្ពីមកហើយ ប្រាប់សេចក្ដីនោះ ។ កុដុម្ពីទាំងនោះ ជ្រាបសេចក្ដីដែលនាងមិនមានទោស ទើបឱ្យសេដ្ឋីយល់ព្រមហើយ ។ គេប្រាប់ដល់ភរិយាថា កូនប្រសារនេះមិនសំពះព្រះសមណៈទាំងឡាយរបស់យើង ដោយ យល់ថា "ជាអ្នកមិនមានសេចក្ដីខ្មាស" ។

ភរិយាសេដ្ឋីនោះគិតថាពួកសមណៈរបស់កូនប្រសារនេះដូចម្ដេចទៅហ្ន៎ ? នាងសរសើរព្រះសមណៈទាំងនោះហួសប្រមាណ ឱ្យគេហៅនាងមកហើយនិយាយថា ៖

**"ពួកព្រះសមណៈរបស់នាង ប្រាកដយ៉ាងណា ? នាងទើបសរសើរព្រះសមណៈទាំងនោះ ក្លាំងខ្លាម្ល៉េះ ។ ព្រះសមណៈទាំងនោះ មានប្រក្រតីយ៉ាងណា ? មានសមាចារយ៉ាងណា ? នាងដែលយើងសួរហើយ ចូរប្រាប់រឿងនោះដល់យើង" ។**

លំដាប់នោះ នាងសុភទ្ទាប្រកាសគុណទាំងឡាយរបស់ព្រះពុទ្ធនិងព្រះសាវករបស់ព្រះពុទ្ធ ដល់ម្ដាយក្មេករបស់នាងញ៉ាំង

ម្តាយក្មេកឱ្យត្រេកអរហើយ ដោយពាក្យទាំងឡាយមានជាដើម យ៉ាងនេះថា ៖

## [កូនប្រសារប្រាប់សមណភាពដល់ម្តាយក្មេក]

"លោកអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ លោកដើរឈរ រៀបរយ, មានចក្ខុទតចុះ និយាយល្មមប្រមាណ, ពួកសមណៈ របស់ខ្ញុំជាដូច្នោះ ។ កាយកម្មរបស់លោកស្អាត ។ វចីកម្មមិន កករល្អក់, មនោកម្មស្អាតស្អំល្អ ។

ពួកសមណៈរបស់ខ្ញុំជាដូច្នោះ ។ លោកមិនមានមន្ទិល មានរស្មីដូចស័ង្ខនិងមុក្តា បរិសុទ្ធិទាំងខាងក្នុង ខាងក្រៅពេញ ហើយដោយធម៌ដែលហ្មត់ចត់ទាំងឡាយ ។ ពួកសមណៈរបស់ ខ្ញុំជាដូច្នោះ ។ លោកខ្ពស់ឡើងព្រោះលាភ និងទាបចុះ ព្រោះការ សាបសូន្យលាភ, លោកអ្នកតាំងនៅតែម្យ៉ាងព្រោះលាភនិងសាប សូន្យលាភ ។ ពួកសមណៈរបស់ខ្ញុំជាដូច្នោះ ។ លោកខ្ពស់ឡើង ព្រោះយស និងទាបចុះព្រោះសាបសូន្យយស, លោកអ្នកតាំងនៅ តែម្យ៉ាង ព្រោះយសនិងសាបសូន្យយស, ពួកសមណៈរបស់ខ្ញុំ ជាដូច្នោះ ។ លោកខ្ពស់ឡើង ព្រោះការសរសើរ និងទាបចុះ

សូម្បី ព្រោះនិន្ទា, លោកជាអ្នកស្មើព្រោះនិន្ទានិងសរសើរ, ពួកសមណៈ របស់ខ្ញុំជាដូច្នោះ ។ លោកខ្ពស់ឡើងព្រោះសុខ និងទាបចុះសូម្បីព្រោះទុក្ខ, លោកមិនញាប់ញ័រព្រោះសុខនិងទុក្ខ, ពួកសមណៈរបស់ខ្ញុំជាដូច្នោះ” ។

## [នាងចូឡសុភទ្ទានិមន្តភិក្ខុសង្ឃឆាន់អាហារ]

លំដាប់នោះម្តាយក្មេកពោលនឹងនាងថា“នាងអាចសម្តែងសមណៈទាំងឡាយរបស់នាងឯង សូម្បីដល់ពួកខ្ញុំបានឬ”កាលនាងឆ្លើយថា“អាច” ទើបនិយាយថា“បើដូច្នោះ នាងឯង ចូរធ្វើដោយប្រការដែលពួកខ្ញុំនឹងឃើញសមណៈទាំងនោះ” ។ នាងទទួលថា “ល្អណាស់” ត្រៀមមហាទានដើម្បីភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ហើយឈរលើផែនដី ប្រាសាទជាន់លើ បែរមុខទៅចំពោះវត្តជេតពន ថ្វាយបង្គំដោយគោរព ដោយបញ្ចង្គប្រតិស្ឋានរឭកដល់ព្រះពុទ្ធគុណទាំងឡាយ ធ្វើការបូជាដោយរបស់ក្រអូបគ្រឿងអប់ផ្កាឈើនិងធូប ពោល(និមន្ត)ថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ដើម្បីឆាន់ក្នុងព្រឹកថ្ងៃស្អែក ដោយសញ្ញាណរបស់ខ្ញុំនេះ សូមព្រះសាស្តាចូរ

ជ្រាបថា ជាអ្នកដែលខ្ញុំនិមន្តហើយ" ដូច្នេះហើយ ទើបបោះផ្កាម្លិះ ៨ ក្តាប់ ទៅក្នុងអាកាស ។ ផ្កាឈើអណ្តែតទៅជាពិតានដែលសម្រេច ដោយរបៀងផ្កាឈើ បានតាំងនៅខាងលើព្រះសាស្តាដែលទ្រង់សម្តែងធម៌នៅត្រង់កណ្តាលបរិស័ទ ៤

## [សប្បុរសរមែងប្រាកដក្នុងទីឆ្ងាយ]

ក្នុងខណៈនោះ សូម្បីអនាថបិណ្ឌិកសេដ្ឋីស្តាប់ធម្មកថាហើយនិមន្តព្រះសាស្តា ដើម្បីសោយភត្តក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្តាត្រាស់ថា "គហបតី តថាគតទទួលការនិមន្តហើយ ?" កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកដទៃដែលមកមុនខ្ញុំព្រះអង្គមិនមាន តើព្រះអង្គទទួលការនិមន្តរបស់បុគ្គលណា ត្រាស់ថា "គហបតីនាងចូឡសុភទ្ទានិមន្តទុកហើយ" ។ កាលលោកសេដ្ឋីពោលថា "នាងសុភទ្ទានៅក្នុងទីឆ្ងាយ ទីបំផុតប្រមាណ ១២០ យោជន៍ អំពីទីនេះមិនមែនឬ ? ព្រះអង្គ" ត្រាស់ថា "អើ គហបតីក៏សប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ រមែងប្រាកដដូចឈរចំពោះមុខ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថា ថា ៖

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួកអសប្បុរស (ទុកជាឋិតនៅ)ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូច ព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

## **អធិប្បាយគាថា**

បណ្តាបទទាំងនោះ បទថា សន្តោ ជាដើម សេចក្តីថា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា សប្បុរស ព្រោះការដែលកិលេសទាំងឡាយ មានរាគៈជាដើមស្ងប់ហើយ, តែក្នុងទីនេះ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាសត្វអ្នកមានអធិការ (បុណ្យ) ដែលធ្វើទុកហើយ ក្នុងព្រះពុទ្ធជាម្ចាស់ក្នុងកាលមុន មានកុសលមូលសន្សំទុកហើយ (និង) អប់រំភាវនាហើយថា "សប្បុរស" ។

បទថា បកាសេន្តិ សេចក្តីថា សូម្បីឈរនៅទីឆ្ងាយ កាលមកកាន់គន្លងព្រះញាណនៃព្រះពុទ្ធទាំងឡាយ ឈ្មោះថា រមែងប្រាកដបាន ។

បទថា ហិមវន្តោវ សេចក្តីថាដូចយ៉ាងថាភ្នំហិមពាន្តទទឹង

៣០០០ យោជន៍ កំពស់ ៥០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤,០០០ រមែងប្រាកដ សូម្បីដល់ជនទាំងឡាយ អ្នកឈរក្នុងទីឆ្ងាយ ដូចតាំងនៅចំពោះមុខយ៉ាងណា, សប្បុរសទាំងឡាយរមែង ប្រាកដ ដូច្នោះ ។

បទថា អសន្តេត្ថ សេចក្តីថា បុគ្គលពាល ធ្ងន់ក្នុងទិដ្ឋធម៌មានបរលោកដែលកន្លងទៅហើយ ឃើញតែអាមិស បួសដើម្បីប្រយោជន៍ដល់ជីវិត ឈ្មោះថា អសប្បុរស, អសប្បុរសទាំងនោះសូម្បីអង្គុយក្នុងទីនេះ គឺ ក្នុងទីជិតមណ្ឌលនៃព្រះជានុខាងស្តាំរបស់ព្រះពុទ្ធទាំងឡាយរមែងមិនប្រាកដ គឺរមែងមិនច្បាស់ ។

ពីរបទថា **រត្តឹ ខិត្តា** គឺដូចកូនសរដែលបាញ់ទៅក្នុងរាត្រីគឺក្នុងទីងងឹតប្រកបដោយអង្គ ៤ ។

អធិប្បាយថា អសប្បុរសទាំងនោះ រមែងមិនប្រាកដព្រោះការមិនមាននៃបុព្វហេតុ ដែលជាឧបនិស្ស័យមានសភាពបែបនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

## [ វិស្សកម្មនិមិត្តផ្ទះកំពូល៥០០ខ្នង ]

សូម្បីស្ដេចសក្កទេវរាជ ទ្រង់ជ្រាបថា “ព្រះសាស្ដាទ្រង់ទទួលនិមន្ត របស់នាងចូឡសុភទ្ទាហើយ” ទ្រង់បង្គាប់វិស្សកម្មទេវបុត្រថា “អ្នកចូរនិម្មិតផ្ទះកំពូល ៥០០ ខ្នង ហើយ នាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ទៅកាន់ឧគ្គនគរ ក្នុងថ្ងៃស្អែកនេះ” ។

ក្នុងថ្ងៃស្អែក វិស្សកម្មទេវបុត្រនោះ និម្មិតផ្ទះកំពូល ៥០០ ខ្នងហើយ បានឈរត្រង់ទ្វារនៃវត្តជេតពន ។ ព្រះសាស្ដាទ្រង់ជ្រើសរើសហើយ នាំភិក្ខុខីណាស្រពអ្នកបរិសុទ្ធទាំងនោះ ៥០០ រូប ព្រមដោយបរិវារប្រថាប់អង្គុយក្នុងផ្ទះកំពូលហើយ បានស្ដេចទៅកាន់ឧគ្គនគរ ។

## [ ឧគ្គសេដ្ឋីត្រឡប់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ]

សូម្បីឧគ្គសេដ្ឋីព្រមដោយបរិវារ ក្រឡេកមើលផ្លូវស្ដេចយាងមកនៃព្រះតថាគត ដោយន័យដែលនាងសុភទ្ទាឱ្យហើយ ឃើញព្រះសាស្ដាស្ដេចមកដោយសិរីសម្បត្តិធំ ជាអ្នកមានចិត្តជ្រះថ្លាហើយ ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានផ្កាឈើជាដើម

ទទួលហើយថ្វាយបង្គំថ្វាយមហាទាន និមន្តព្រះសាស្តាម្តងទៀត បានថ្វាយមហាទានអស់ ៧ ថ្ងៃ ។

សូម្បីព្រះសាស្តា ទ្រង់កំណត់ធម៌ជាទីសប្បាយរបស់សេដ្ឋីនោះហើយ ទ្រង់សម្តែងធម៌ ។ សត្វ៨៤,០០០ ធ្វើសេដ្ឋីនោះជាដើម ឱ្យបានត្រាស់ដឹងធម៌ ។

ព្រះសាស្តា ដើម្បីទ្រង់អនុគ្រោះនាងសុភទ្ទា ទើបត្រាស់បង្គាប់ឱ្យព្រះអនុរុទ្ធត្ថេរៈត្រឡប់ ដោយព្រះតម្រាស់ថា "អ្នកចូរសម្រាកក្នុងទីនេះ" ហើយបានស្តេចទៅកាន់ក្រុងសាវត្ថីតែម្តង ។ តាំងពីនោះមក ( អ្នក )នគរនោះមានសទ្ធាជ្រះថ្លាដូច្នេះឯង ៕

## សង្ខេបខ្លីៗ

១-ធ្វើឱ្យមានចិត្តផូរផង់អាចធ្វើសេចក្តីល្អបានដោយងាយ

២-ធ្វើឱ្យមាននូវបញ្ញាបន្ថែមឡើង ជាមនុស្សម៉ឺងម៉ាត់ មានហេតុផល

៣-ធ្វើឱ្យមានការយល់ឃើញត្រូវ ជាសម្មាទិដ្ឋិ

៤-ធ្វើឱ្យមិនត្រូវមានការសោកសៅ ក្តៅក្រហាយព្រោះធ្វើខុស

៥-ពួកមនុស្សទាំងឡាយតែងលើកសរសើរជានិច្ច
៦-ធ្វើឱ្យមានសេចក្ដីសុខ ផុតចាកភ័យអន្តរាយផ្សេង ៗ
៧-ធ្វើឱ្យមានការរីកចម្រើនទៅមុខយ៉ាងរហ័ស
៨-នៅពេលលះលោកនេះទៅរមែងចូលដល់សុគតិ
៩-អាចធ្វើឱ្យសម្រេចមគ្គផលនិព្វានបានដោយងាយជាដើម ។

## លទ្ធផលនៃការសេពគប់

អស់លោកសប្បុរសទាំងក្មេងចាស់ ត្រូវចាំឱ្យច្បាស់កុំសង្ស័យ
មុននឹងសេពគប់អ្នកដទៃ គួរតែកែច្នៃឱ្យហ្មត់ហ្មង ។
គប់ប្រាជ្ញនាំប្រាណឱ្យបានសុខ គប់ពាលនាំស្អុកទុក្ខមកសង
គប់ប្រាជ្ញនាំឱ្យឃ្លាតចាកបាបផង គប់ពាលជួជងជាប្រក្រតី ។
គប់ប្រាជ្ញនាំប្រាណបានស្ថានសួគ៌ គប់ពាលនាំតួទៅអវិចី
គប់ប្រាជ្ញនាំប្រាណឱ្យបានថ្លៃ គប់ពាលចង្រៃនាំថោកទាប ។
គប់ប្រាជ្ញនាំប្រាណបានធ្វើបុណ្យ គប់ពាលទុរជននាំធ្វើបាប
គប់ប្រាជ្ញនាំប្រាណបានសុភាព គប់ពាលថោកទាបនាំហិនហោច
គប់ប្រាជ្ញនាំប្រាណរក្សាសីល គប់ពាលខូចខិតនាំផឹកស្រា
គប់ប្រាជ្ញនាំប្រាណបានអាចារ្យ គប់ពាលមោហាកើតអាចោរ ។
គប់ប្រាជ្ញនាំប្រាណបានយសស័ក្តិ គប់ពាលអបលក្ខណ៍ប្រើទោសោ

គប់ប្រាជ្ញនាំប្រាណខ្ពស់ដូចខ្លែង គប់ពាលឯកឯងអន្តរធាន ។
គប់ប្រាជ្ញនាំប្រាណបានញាតិមិត្ត គប់ពាលទុច្ចរិតតសន្តាន
គប់ប្រាជ្ញនាំប្រាណបានសុខសាន្ត គប់ពាលសាមាន្យបានទុក្ខសោក ។
គប់ប្រាជ្ញនាំប្រាណបានខ្ពង់ខ្ពស់ គប់ពាលទូរយសនាំអព្ភមុខ
គប់ប្រាជ្ញដូចយើងបានកុយពុក គប់ពាលតត្រកស្អុយពូជពង្ស ។
គប់ប្រាជ្ញនាំប្រាណបានសិក្សា គប់ពាលដូចខ្លាហិតគំរុង
គប់ប្រាជ្ញនាំប្រាណបានផ្លូវផង់ គប់ពាលល្វឹតល្វង់ដើរបោះខ្សៀ ។
គប់ប្រាជ្ញកេរ្តិ៍ឈ្មោះពីរោះល្បី គប់ពាលអប្រិយ៍ដូចឆ្នាំង្កែ
គប់ប្រាជ្ញនាំប្រាណបានស្និទ្ធស្នេហ៍ គប់ពាលបានតែក្សយសង្ខារ
គប់ប្រាជ្ញនាំប្រាណបាននិព្វាន ទុក្ខសោកលែងមានចិត្តល្ហើយល្ហែ ។
ទានសីលភាវនាបានហូរហៃ គួរតែបដិបត្តិតាមភាសិត ។

( សមណសិស្សភិក្ខុតិដ្ឋិតោទឹម វណ្ណៈ )

## បទពិចារណា

ពិតមែន បុគ្គលដែលមានប្រក្រតីសេពគប់បុគ្គលពាល រមែងសោកសៅអស់កាលយូរ ព្រោះការនៅរួមជាមួយ បុគ្គលជាហេតុនាំទុក្ខមកឱ្យគ្រប់កាល ដូចជាការនៅរួមជាមួយសត្រូវ ចំណែកការនៅរួមជាមួយបណ្ឌិត រមែងមានតែសេចក្ដីសុខដូចជាការនៅរួមជាមួយពួកញាតិ ព្រោះហេតុនោះ នរជនគប្បីសេពគប់បណ្ឌិត

អ្នកមានបញ្ញា ជាពហុស្សូត មានសីល មានវត្តបដិបត្តិល្អឆ្ងាយចាកពីកិលេសនឹងជាសប្បុរសប្រៀបដូចព្រះច័ន្ទសេពគប់អាកាសដែលជាផ្លូវ គោរពនៃដួងផ្កាយដូច្នោះ ។

- **សត្វស្វាស៊ីស្វាយ មិនស្អាយគ្រាប់ ត្មាតស៊ីសាកសព្វមិនខ្ពើមនាយ ជនពាលមិនឆ្អែតនឹងបាបទាំងឡាយ បណ្ឌិតពិតមិនឆ្អែតនឹងធម្មា ។**

បណ្ឌិតានញ្ច សេវនា ឯតម្មង្គលមុត្តមំ

**☝..កិរិយាសេពគប់បណ្ឌិតទាំងឡាយ**

**នេះជាមង្គលដ៏ឧត្តម។**

# មង្គលកថាមង្គលទី ២ ចប់

## គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស.២៥៥៧
-អដ្ឋកថាពន្យល់សេចក្ដីនៃគម្ពីរព្រះត្រៃបិដក.ស.២៥២២
-មង្គលត្ថទីបនីភាគ ១ របស់ព្រះមហាឃិន នឿន ព.ស.២៥៣៨
-គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥៥៧
-គម្ពីរធម្មាវលី របស់ភិក្ខុធម្មវរាចារ្យ
-មង្គលជីវិត របស់ព្រះភិក្ខុ វជិរប្បញ្ញោ គូ សុភាព ព.ស.២៥៥៥
-មិត្តល្អ របស់ព្រះភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ ព.ស.២៥៥៥
-សង្គាលកសូត្ររបស់ព្រះភិក្ខុវជិរប្បញ្ញោ សាន សុជា ព.ស.២៥៥២
-វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១
-ព្រមទាំងឯកសាមួយចំនួនទៀត។

# ថ្ងៃល្អនៃជីវិត

*នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណាប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាព្រឹក វេលាថ្ងៃ វេលាល្ងាច សត្វទាំងនោះឈ្មោះថា មានវេលាព្រឹកដ៏ល្អ វេលាថ្ងៃដ៏ល្អ វេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖*

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។**

*ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃភ្លឺស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថាជាគ្រឿងបូជាល្អ។*